# ក្រមប្រតិបត្តិ

# ប្រកបដោយភាពទទួលខុសត្រូវ

# វិស័យជលផល

# ក្រមប្រតិបត្តិ
# ប្រកបដោយភាពទទួលខុសត្រូវ
# វិស័យជលផល

ម.ព.ឯ.ក AIDOC
Code: 139-044
Date:
Donated by:

សហការផលិតដោយ
នាយកដ្ឋានជលផល និង JICA ខែ ធ្នូ ២០០៣

JICA

# ក្រមប្រតិបត្តិ
# ប្រកបដោយភាពទទួលខុសត្រូវ
# វិស័យផលផល

បកប្រែសម្រួលចេញពីសៀវភៅរបស់ FAO ស្តីពី

**Code of Conduct for Responsible Fisheries**

ទីក្រុងរ៉ូម ឆ្នាំ ១៩៩៥ ដែលមានចំនួន ៤១ ទំព័រ

ឧបត្ថម្ភថវិកាដោយ JICA


| បកប្រែសម្រួល និង រចនា | ពិនិត្យ និង កែសម្រួល |
|---|---|
| - លោក ម៉ៅ សំអុន | -លោក ណៅ ធួក |
| - លោក ហាវ វិសិដ្ឋ | - លោក សម នៅ |



អង្គការស្បៀងអាហារ និង កសិកម្មនៃសហប្រជាជាតិ

ទីក្រុង រ៉ូម ១៩៩៥

ការរៀបចំដែលបានធ្វើឡើង និង អត្ថន័យនៃអត្ថបទទាំងមូលដែលបានបោះពុម្ពផ្សាយនេះពុំមែនឆ្លុះបញ្ចាំងទស្សនៈ ទោះជានៅក្នុងផ្នែកណាមួយរបស់អង្គការស្បៀងអាហារ និង កសិកម្មនៃសហប្រជាជាតិលើការងារច្បាប់របស់ប្រទេស ដែនដី ទីក្រុង តំបន់ ឬ លើការងារគ្រប់គ្រងនៃអាជ្ញាធរផ្ទាល់ ឬ ពាក់ព័ន្ធទៅនឹងការកំណត់តំបន់ដែលត្រូវគ្រប់គ្រងឡើយ ។

រក្សាសិទ្ធិគ្រប់យ៉ាងដោយនាយកដ្ឋានផលផល ។

គ្មានផ្នែកណាមួយនៃការបោះពុម្ពនេះត្រូវបានផលិតឡើងវិញ រក្សាទុកនៅក្នុងប្រព័ន្ធដែលអាចយកមកប្រើវិញបាន ឬ បំប្លែងទៅជាទម្រង់ណាមួយ ឬ ដោយមធ្យោបាយណាមួយ ដូចជាអេឡិចត្រូនិច មេកានិច ថតចំលង។ ល។ ដោយមិនបានសុំការអនុញ្ញាតជាមុនពីម្ចាស់រក្សាសិទ្ធិ ។ រាល់ពាក្យស្នើសុំការអនុញ្ញាតដែលភ្ជាប់គោលបំណង និងវិសាលភាពនៃការផលិតឡើងវិញត្រូវតែផ្ញើមកនាយកដ្ឋានផលផល លេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៥៨២ ។

@ ជ.ផ ២០០៣

ទំព័រ


| | | | |
|---|---|---|---|
| **មាតិកា** | | | i |
| **អារម្ភកថា** | | | iii |
| **សេចក្តីផ្តើម** | | | ១ |
| **មាត្រា** | **១** | **សារជាតិ និង វិសាលភាពរបស់ក្រមប្រតិបត្តិ** | ១ |
| **មាត្រា** | **២** | **គោលបំណងរបស់ក្រមប្រតិបត្តិ** | ២ |
| **មាត្រា** | **៣** | **ទំនាក់ទំនងជាមួយនិងឯកសារអន្តរជាតិផ្សេងទៀត** | ៣ |
| **មាត្រា** | **៤** | **ការអនុវត្ត ត្រួតពិនិត្យ និង ការកែសម្រួលសមស្រប** | ៤ |
| **មាត្រា** | **៥** | **សំណូមពរពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍ** | ៥ |
| **មាត្រា** | **៦** | **គោលការណ៍ទូទៅ** | ៦ |
| **មាត្រា** | **៧** | **ការគ្រប់គ្រងជលផល** | ១១ |
| **មាត្រា** | **៨** | **ការធ្វើអាជីវកម្មនេសាទ** | ២៣ |
| **មាត្រា** | **៩** | **ការអភិវឌ្ឍវារីវប្បកម្ម** | ៣៣ |
| **មាត្រា** | **១០** | **ការធ្វើសមាហរណកម្មវិស័យជលផលនៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ** | ៣៧ |
| **មាត្រា** | **១១** | **ការកែច្នៃបន្ទាប់ពីការប្រមូលផលនេសាទ និងការធ្វើពាណិជ្ជកម្ម** | ៣៩ |
| **មាត្រា** | **១២** | **ការស្រាវជ្រាវជលផល** | ៤៥ |
| **ឧបសម្ព័ន្ធ** | **១** | **សាវតាដើម និង វិវឌ្ឍនាការរបស់ក្រមប្រតិបត្តិ** | ៥០ |
| **ឧបសម្ព័ន្ធ** | **២** | **ដំណោះស្រាយ** | ៥៨ |

ក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវវិស័យជលផលដែលឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ប្អូនៗសិស្សានុសិស្ស និង មិត្តរួមអាជីពទាំងអស់កំពុងកាន់អាននៅក្នុងដៃនេះត្រូវបានបកប្រែសម្រួល រៀបរៀង ចងក្រង ហើយបោះពុម្ពយ៉ាងសម្រិតសម្រាំងចេញពីសៀវភៅជាភាសា អង់គ្លេសដែលមានចំណងជើងថា " Code of Conduct for Responsible Fisheries " ក្នុងគោលបំណង ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍរបស់ប្រទេសជាតិ ។

ក្រមប្រតិបត្តិនេះត្រូវបានបកប្រែមកជាភាសាជាតិ ការប្រើពាក្យពេចន៍ទាំងអស់ដែលមាននៅក្នុងសៀវភៅនេះគឺផ្អែកទៅតាមវចនានុក្រមខ្មែរដែលជាការចេញផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១១ គ.ស. ១៩៦៧ ។

ចំពោះខ្លឹមសារបច្ចេកទេសដែលមាននៅក្នុងសៀវភៅទាំងមូល យើងខ្ញុំបានពិនិត្យកែសម្រួលផ្ទៀងផ្ទាត់ សាចុះសាឡើងជាច្រើនលើក ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយយើងខ្ញុំជឿជាក់ថាពិតជានៅមានខ្វះចន្លោះ ខ្លះៗជាមិនខាន ទោះបីដោយចេតនា ឬ អចេតនាក្តី ។

យើងខ្ញុំទាំងអស់គ្នារង់ចាំទទួលរាល់ការរិះគន់ ស្ថាបនាពីសំណាក់អ្នកអានគ្រប់មជ្ឈដ្ឋានដោយសេចក្តីសោមនស្សរីករាយ ។

រាល់មតិ យោបល់រិះគន់កែលំអដើម្បីស្ថាបនាទាំងអស់ សូមផ្ញើមកនាយកដ្ឋានជលផល លេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៥៨២ ឬ តាមរយៈ e-mail: nuov@mobitel.com.kh ។

## អារម្ភកថា

តាំងពីបុរាណកាល ផលដែលបានមកពីការធ្វើអាជីវកម្មនេសាទគឺជាប្រភពធនធានម្ហូបអាហារយ៉ាងសំខាន់សំរាប់មនុស្សជាតិ ហើយជាប្រភពផ្តល់ការងារ និង ចំណូលសេដ្ឋកិច្ចដល់អ្នកដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពនេះ ។ ទ្រព្យសម្បត្តិនៃធនធានវារីជាតត្រូវបានសន្មតថាជាអំណោយគ្មានដែនកំណត់របស់ធម្មជាតិ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីសង្គ្រាមលោកលើកទី ២ ជាមួយនឹងការរីកចំរើននៃចំណេះដឹង និង ការអភិវឌ្ឍវិស័យជលផលបានប្រឈមមុខទៅនឹងការពិតដែលធនធានវារីជាត ទោះបីបានកែលំអឱ្យប្រសើរឡើងវិញក្តីចាំបាច់ត្រូវតែគ្រប់គ្រងឱ្យបានត្រឹមត្រូវ ប្រសិនបើការចូលរួមចំណែករបស់វាទៅក្នុងអាហារូបត្ថម្ភ សេដ្ឋកិច្ច សង្គម និង សុខុមាលភាពនៃការរីកចំរើនប្រជាពលរដ្ឋលើពិភពលោកត្រូវតែមាននិរន្តរភាព ។

ការបើកចូលហត្ថលេខាយបុព្វកថាក្នុងពាក់កណ្តាលកិច្ចប្រជុំលើកទី ៧០ នៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ និង ការអនុម័តិក្នុងឆ្នាំ១៩៨២បន្ទាប់ពីមានការពិភាក្សាយ៉ាងយូរនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្របានផ្តល់នូវក្រោងការណ៍ថ្មីសំរាប់ការគ្រប់គ្រងធនធានសមុទ្រឱ្យប្រសើរឡើង ។ របបដែលពេញលក្ខណៈច្បាប់ថ្មីនៃមហាសាគរបានផ្តល់ដល់បណ្តាប្រទេសជាប់ឆ្នេរនូវសិទ្ធិ និង ការទទួលខុសត្រូវសំរាប់ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានវិស័យជលផលនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់គេ ៩០ ភាគរយនៃជលផលសមុទ្រកាន់កាប់ដោយពិភពលោក ។ បណ្តាវិសាលភាពនៃយុត្តាធិការជាតិគឺជាការចាំបាច់ ប៉ុន្តែខ្វះសមត្ថភាពឈានទៅរកការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព និង ការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់វិស័យជលផល ។ ប្រទេសដែលនៅតាមឆ្នេរជាច្រើនបានបន្តប្រឈមមុខនឹងបញ្ហាជាច្រើន ដូចជាខ្វះខាតបទពិសោធន៍ ថវិកា និង ធនធានរូបសាស្ត្រ គេគិតថានឹងដកហូតយកប្រយោជន៍ឱ្យបានច្រើនពីជលផលដែលនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់គេ ។ ប៉ុន្មានឆ្នាំចុងក្រោយនេះជលផលពិភពលោកបានប្រែក្លាយទៅជារត់តាមទីផ្សារឧស្សាហកម្មម្ហូបអាហារដែលកំពុងអភិវឌ្ឍទៅមុខយ៉ាងស្វាហាប់ ហើយបណ្តាប្រទេសតំបន់ឆ្នេរបានខិតខំយ៉ាងខ្លាំងដើម្បីទទួលយកនូវសារ

ប្រយោជន៍ពីឱកាសថ្មីរបស់ពួកគេដោយវិនិយោគទៅលើនាវានេសាទដែលមានលក្ខណៈទំនើប និង រោងចក្រកែច្នៃ ដើម្បីឆ្លើយតបទៅនឹងការរីកចំរើននៃតំរូវការត្រី និងផលិតផលត្រីនៅលើទីផ្សារអន្តរជាតិ

ទោះបីជាយ៉ាងនេះក្ដី នៅចុងឆ្នាំ ១៩៨០ បញ្ហានេះបានបង្ហាញកាន់តែច្បាស់ថាធនធានជលផលមិនអាចទ្រាំទ្របានទៅនឹងការរីកចំរើននៃការធ្វើអាជីវកម្មនេសាទដែលកើនឡើងយ៉ាងឆាប់រហ័សដោយគ្មានការត្រួតពិនិត្យ និង របៀបគ្រប់គ្រងជលផលថ្មីបានប្រកាន់យកជាបន្ទាន់ដើម្បីបំពេញនូវលក្ខខណ្ឌអភិរក្ស និង ការគ្រប់គ្រង ។ ស្ថានភាពកាន់តែធ្ងន់ធ្ងរឡើងដោយយល់ច្បាស់ថា ជលផលដែលគ្មានរបៀបរៀបរយនៅក្នុងលំហសមុទ្រក្រៅ ករណីខ្លះរួមបញ្ចូលទាំងពូជត្រីដែលធ្វើចរាចរឆ្លាយ និង ច្រកតាវដែលកើតឡើងនៅក្នុង និង នៅក្រៅតំបន់សេដ្ឋកិច្ចផ្ដាច់មុខក្លាយជាកំនើនបញ្ហាពាក់ព័ន្ធ ។

នៅក្នុងសម័យប្រជុំលើកទី១៩ ខែមីនា ឆ្នាំ ១៩៩១ គណៈកម្មាធិការស្ដីពីជលផល(COFI) បានអំពាវនាវឱ្យរៀបចំទស្សនៈថ្មីដែលអាចជួយគាំទ្រវិស័យជលផលប្រកបដោយភាពទទួលខុសត្រូវ ។ ក្រោយមកសន្និសីទអន្តរជាតិស្ដីពីភាពទទួលខុសត្រូវលើការធ្វើអាជីវកម្មនេសាទបានប្រព្រឹត្តិឡើងក្នុងឆ្នាំ ១៩៩២ ទៅ Cancun ប្រទេសម៉ិចសិកកូបានជួយជ្រោមជ្រែងស្នើ FAO ឱ្យរៀបចំក្រមប្រតិបត្តិអន្តរជាតិដើម្បីឆ្លើយតបទៅនឹងការពាក់ព័ន្ធទាំងនោះ ។ លទ្ធផលនៃសន្និសីទនេះ ជាពិសេស សេចក្ដីប្រកាសទៅ Cancun គឺជាការរួមចំណែកយ៉ាងសំខាន់ទៅដល់សន្និសីទអង្គការសហប្រជាជាតិឆ្នាំ ១៩៩២ ស្ដីពីបរិស្ថាន និង ការអភិវឌ្ឍ ជាពិសេសនៅក្នុងរបៀបវារៈទី ២១ របស់វា ។បន្ទាប់មកសន្និសីទអង្គការសហប្រជាជាតិស្ដីពីសន្និធិត្រីច្រកតាវ និង សន្និធិត្រីធ្វើចរាចរឆ្លាយបានកោះប្រជុំដែលក្នុងនោះ FAO ជាអ្នកផ្ដល់ការជួយគាំទ្របច្ចេកទេសយ៉ាងសំខាន់ ។ នៅវិច្ឆិកា ឆ្នាំ១៩៩៣ កិច្ចព្រមព្រៀងដើម្បីជំរុញឱ្យនាវាធ្វើអាជីវកម្មនេសាទធ្វើតាមវិធានការអភិរក្ស និង គ្រប់គ្រងនៅសមុទ្រក្រៅត្រូវបានអនុម័តិនៅក្នុងសម័យប្រជុំលើកទី ២៧ នៃសន្និសីទFAO ។

កំណត់ត្រានានា និង ការអភិវឌ្ឍសំខាន់ក្នុងជលផលពិភពលោក អង្គរដ្ឋបាល FA បានស្នើឱ្យរៀបចំក្រមប្រតិបត្តិភាពទទួលខុសត្រូវលើវិស័យជលផលថ្នាក់ពិភពលោកមួយដែលវានឹងរលូនទៅនឹងឧបករណ៍នានាក្នុងបរិយាបថមួយមិនចាំបាច់សំរាប់បង្កើតគោលការណ៍ និង បទដ្ឋាននានាឱ្យសមស្របទៅនឹងការអភិរក្ស ការគ្រប់គ្រង និង ការអភិវឌ្ឍនៃគ្រប់ជលផល ។ ក្រមប្រតិបត្តិដែលបានអនុម័តិជាឯកច្ឆន្ទ

នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៥ដោយសន្និសីទ FAO បានផ្តល់នូវគ្រោងការណ៍ចាំបាច់សំរាប់កិច្ចខិតខំរបស់ប្រទេសទាំងអស់ និង អន្តរជាតិ ដើម្បីធានានិរន្តរភាពការធ្វើអាជីវកម្មធនធានវារិជាតឱ្យស្របទៅនឹងបរិស្ថាន ។

FAO ដោយអនុលោមទៅតាមអាណត្តិរបស់ខ្លួនបានសន្យាយ៉ាងពេញទំហឹងជួយដល់បណ្តាប្រទេសសមាជិក ជាពិសេសបណ្តាប្រទេសកំពុងអភិវឌ្ឍក្នុងការអនុវត្តឱ្យមានប្រសិទ្ធិភាពនូវក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវវិស័យជលផល ហើយរាយការណ៍ជូនទៅសហគមន៍សហប្រជាជាតិស្តីពីជោគជ័យរីកចំរើន និង សកម្មភាពចាំបាច់នៅពេលអនាគត ។

## <u>សេចក្ដីផ្ដើម</u>

ជលផលរាប់បញ្ចូលទាំងវារីវប្បកម្មជាប្រភពផ្ដល់នូវម្ហូបអាហារ ការងារ ការបង្កើតថវិកាពាណិជ្ជកម្ម សេដ្ឋកិច្ច និង សុខុមាលភាពរបស់ប្រជាពលរដ្ឋនៅលើពិភពលោកសំរាប់ជំនាន់បច្ចុប្បន្ន និង អនាគត ហើយគួរតែត្រូវបានដំណើរការក្នុងតរិយាបថមួយប្រកបដោយភាពទទួលខុសត្រូវ ។ ក្រមប្រតិបត្តិនេះរៀបចំ គ្រប់គ្រងនូវចង្កោមគោលការណ៍ និង បទដ្ឋានអន្តរជាតិនៃតរិយាបថសំរាប់ការអនុវត្តប្រកបដោយភាពទទួលខុសត្រូវជាមួយនឹងទស្សនៈ ដើម្បីធានានូវប្រសិទ្ធិភាពអភិរក្ស គ្រប់គ្រង និង អភិវឌ្ឍនៃធនធានវារីសត្វមានជីវិតដោយគោរពទៅដល់ប្រព័ន្ធអេកូឡូស៊ី និង ជីវៈចម្រុះ ។ ក្រមប្រតិបត្តិកត់សំគាល់នូវសារៈសំខាន់របស់វារិជាត និង សារៈប្រយោជន៍របស់សារធាតុចិញ្ចឹម សេដ្ឋកិច្ច សង្គម បរិស្ថាន និង ប្រពៃណីដែលពាក់ព័ន្ធជាមួយនឹងវិស័យជលផល ។ ក្រមប្រតិបត្តិយកចិត្តទុកដាក់ដល់លក្ខណៈសម្បត្តិរបស់ធនធាន បរិស្ថានរស់នៅរបស់វា និង សារៈប្រយោជន៍នៃអ្នកហូបចុក និង អ្នកប្រើប្រាស់ផ្សេងទៀត ។ បណ្ដាប្រទេស និង គ្រប់អាជ្ញាធរដែលចូលរួមក្នុងជលផលត្រូវបានលើកទឹកចិត្ត ក្នុងការប្រតិបត្តិក្រមប្រតិបត្តិ ហើយផ្ដល់ប្រសិទ្ធិភាពទៅលើវា ។

## មាត្រា ១ សារជាតិ និង វិសាលភាពរបស់ក្រមប្រតិបត្តិ

១.១ ក្រមប្រតិបត្តិនេះគឺជាការស្ម័គ្រចិត្ត ។ ប៉ុន្តែផ្នែកខ្លះរបស់វាត្រូវបានផ្អែកលើវិធាននៃច្បាប់អន្តរជាតិ គិតទាំងច្បាប់ទាំងឡាយដែលឆ្លុះបញ្ចាំងនៅក្នុងអនុសញ្ញាស្ដីពីច្បាប់សមុទ្ររបស់អង្គការសហប្រជាជាតិ ចុះថ្ងៃ ទី ១០ ធ្នូ ឆ្នាំ ១៩៨២ ។ ក្រមប្រតិបត្តិក៏មានផ្ទុកផងដែរនូវកិច្ចសន្យានានាដែលអាច ឬ ដែលមានស្រាប់ចងបញ្ចូលគ្នាដោយមធ្យោបាយ កាតព្វកិច្ច ឧបករណ៍ច្បាប់ផ្សេងៗក្នុងចំណោមភាគីនៃកិច្ចសន្យា ដើម្បីជំរុញការអនុវត្តជាមួយនឹងអនុសញ្ញាអន្តរជាតិនិងវិធានការ

គ្រប់គ្រងនាវានេសាទនៅក្នុងសមុទ្រក្រៅ ឆ្នាំ ១៩៩៣ ដែលផ្អែកលើដំណោះស្រាយរបស់សន្និសីទ FAO ១៥/៩៣ កថាខណ្ឌទី ៣ ជាទំរង់នៃផ្នែកមួយរបស់ក្រមប្រតិបត្តិ ។

១.២ ក្រមប្រតិបត្តិមានទំហំគ្របដណ្តប់លើពិភពលោក ហើយផ្តោតដោយផ្ទាល់ទៅលើប្រទេសជាសមាជិក និង មិនមែនជាសមាជិករបស់ FAO អង្គភាពនេសាទ អនុតំបន់ តំបន់និងស្ថាប័នពិភពលោកនានា ទោះបីរដ្ឋាភិបាល ឬ មិនមែនរដ្ឋាភិបាល និង មនុស្សគ្រប់រូបដែលពាក់ព័ន្ធជាមួយនឹងធនធានជលផល និង ការគ្រប់គ្រង និង អភិវឌ្ឍន៍របស់វិស័យជលផលដូចជាប្រជានេសាទអ្នកទាំងឡាយដែលជាប់ពាក់ព័ន្ធក្នុងការងារកែច្នៃ និង ម៉ាឈ្មួញផលិតផលត្រី និង អ្នកប្រើប្រាស់បរិស្ថានវារីជាតផ្សេងទៀតដែលជាប់ទាក់ទងដល់វិស័យជលផល ។

១.៣ ក្រមប្រតិបត្តិផ្តល់នូវគោលការណ៍និងបទដ្ឋាននានាដែលអាចអនុវត្តបានដើម្បីការអភិរក្ស ការគ្រប់គ្រង និងការអភិវឌ្ឍគ្រប់ប្រភេទនៃជលផល ។ វាក៏គ្របដណ្តប់ផងដែរនូវការធ្វើអាជីវកម្ម ការកែច្នៃ និង ការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលត្រី ដំណើរការនេសាទ វារីវប្បកម្ម ការស្រាវជ្រាវ ជលផល និង ការធ្វើសមាហរណកម្មជលផលទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ។

១.៤ នៅក្នុងក្រមប្រតិបត្តិនេះ យោងទៅតាមប្រទេសនានារួមមានសហគមន៍អឺរ៉ុបក្នុងបណ្តាបញ្ហានានាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់វានិងការអនុវត្តប្រើពាក្យជលផលឱ្យឯកភាពគ្នាទៅលើការធ្វើអាជីវកម្ម និង វារីវប្បកម្ម ។

## មាត្រា ២ . គោលបំណងរបស់ក្រមប្រតិបត្តិ

គោលបំណងនៃក្រមប្រតិបត្តិគឺដើម្បីៈ

ក) បង្កើតគោលការណ៍ដោយផ្អែកលើវិធានដែលពាក់ព័ន្ធច្បាប់អន្តរជាតិនានា ដើម្បីភាពទទួលខុសត្រូវលើការធ្វើនេសាទ និង សកម្មភាពនេសាទនានា យកចិត្តទុកដាក់នូវរាល់ទំនាក់ទំនងទិដ្ឋភាព ជីវសាស្ត្រ បច្ចេកទេស សេដ្ឋកិច្ច សង្គម បរិស្ថាន និង ពាណិជ្ជកម្ម ។

ខ) បង្កើតគោលការណ៍ និង លក្ខណៈសម្បត្តិដើម្បីសហប្រតិបត្តិការ និង ការអនុវត្តនយោបាយជាតិសំរាប់ការអភិរក្សធនធានប្រកបដោយភាពទទួលខុសត្រូវ និង ការគ្រប់គ្រង និង អភិវឌ្ឍន៍វិស័យជលផល ។

គ) បំរើដូចជាឧបករណ៍នៃឯកសារបង្អែកដើម្បីជួយប្រទេសនានាឱ្យបង្កើត ឬ ធ្វើឱ្យកាន់តែស្របច្បាប់ឡើងនិងតំរោងលំហាត់ចាំបាច់របស់ស្ថាប័នសំរាប់អនុវត្តក្នុងវិស័យជលផលប្រកបដោយភាពទទួលខុសត្រូវ និង នៅក្នុងការរៀបចំ និង អនុវត្តវិធានការសមស្របនានា ។

ឃ) ផ្តល់ការណែនាំសមស្របដែលអាចប្រើប្រាស់បានក្នុងការបង្កើត និង ការអនុវត្តកិច្ចសន្យាអន្តរជាតិ និង ឧបករណ៍នយោបាយ ច្បាប់នានាទាំងចងក្រងហើយ និង ដោយស្ម័គ្រចិត្ត ។

ង) សម្របសម្រួល និង ជំរុញបច្ចេកទេស ហិរញ្ញវត្ថុ និង កិច្ចសហការផ្សេងទៀតក្នុងការអភិរក្សធនធានជលផល ការគ្រប់គ្រង និង ការអភិវឌ្ឍជលផល ។

ច) ជំរុញការចូលរួមចំណែករបស់វិស័យជលផលទៅក្នុងសុវត្ថិភាពស្បៀងអាហារ និង គុណភាពចំណីអាហារផ្តល់អត្ថិភាពតំរូវការអាហារូបត្ថម្ភដល់សហគមន៍មូលដ្ឋាន ។ ជំរុញការការពារធនធានវារិជាតបរិស្ថានរបស់វា និង តំបន់ឆ្នេរ ។

ឆ) ជំរុញការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាតដោយបញ្ជាក់ពីទំនាក់ទំនងជាមួយវិធានការអន្តរជាតិ ហើយចៀសវាងការប្រើប្រាស់វិធានការរួមគ្នាលាក់បំបាំងរារាំងដល់ការធ្វើពាណិជ្ជកម្ម ។

ជ) ជំរុញការស្រាវជ្រាវលើវិស័យជលផលដែលមានទំនាក់ទំនងជិតស្និទ្ធទៅនឹងប្រព័ន្ធអេកូឡូស៊ី និង កត្តាពាក់ព័ន្ធបរិស្ថាននានា ។

ឈ) ផ្តល់បទដ្ឋានប្រតិបត្តិនានាសំរាប់ប្រជាពលរដ្ឋគ្រប់រូបដែលបានចូលរួមក្នុងវិស័យជលផល ។

## មាត្រា ៣ ទំនាក់ទំនងជាមួយនិងឯកសារអន្តរជាតិផ្សេងទៀត

៣.១ ក្រមប្រតិបត្តិត្រូវបានបកប្រែ និង អនុវត្តស្មើងផ្ទាត់ជាមួយនឹងវិធានច្បាប់អន្តរជាតិ ដូច

ជាការផ្ទុះបញ្ចាំងនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ ។ ក្រមប្រតិបត្តិនេះគ្មានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ យុត្តាធិការនិងករណីយកិច្ចរបស់ប្រទេសដែលស្ថិតក្រោមច្បាប់អន្តរជាតិដូចបានផ្ទុះបញ្ចាំងនៅក្នុងអនុសញ្ញា ។

៣.២ ការបកប្រែពន្យល់ និង អនុវត្តក្រមប្រតិបត្តិ

ក) នៅក្នុងសរិយាបថមួយរលូនជាមួយកថាខណ្ឌពាក់ព័ន្ធនានារបស់កិច្ចព្រមព្រៀងសំរាប់អនុវត្តរបស់អនុសញ្ញាស្តីពីច្បាប់សមុទ្រចុះថ្ងៃទី ១០ ធ្នូ ឆ្នាំ ១៩៨២ ទាក់ទងទៅនឹងការអភិរក្ស និងការគ្រប់គ្រងសន្និធិត្រី និង សន្និធិត្រីដែលបំលាស់ទីឆ្ងាយ ។

ខ) នៅក្នុងការអនុញ្ញាតជាមួយនឹងវិធាននៃច្បាប់អន្តរជាតិដែលអាចអនុវត្តបានរួមបញ្ចូលទាំងកាតព្វកិច្ចជាទីគោរពរបស់ប្រទេសនានាដោយអនុលោមទៅតាមកិច្ចព្រមព្រៀងអន្តរជាតិដែលគេជាភាគី ។

គ) នៅក្នុងពន្លឺមួយរបស់សេចក្តីប្រកាសនៅ Cancun ឆ្នាំ ១៩៩២ សេចក្តីប្រកាស Rio ឆ្នាំ ១៩៩២ ស្តីពីបរិស្ថាន និង ការអភិវឌ្ឍក្នុងរបៀបវារៈទី ២១ត្រូវបានអនុម័តដោយសន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និង ការអភិវឌ្ឍនៅក្នុងជំពូកពិសេសទី ១៧ របៀបវារៈទី២១សេចក្តីសំរេចពាក់ព័ន្ធផ្សេងៗ និង ឧបករណ៍អន្តរជាតិនានា ។

## មាត្រា ៤ ការអនុវត្ត ការត្រួតពិនិត្យ និង កែសម្រួលសមស្រប

៤.១ គ្រប់សមាជិក និង មិនមែនសមាជិករបស់ FAO ទាំងអស់ អង្គភាពនេសាទ និង ស្ថាប័នអនុតំបន់ តំបន់ និង អន្តរជាតិនានា ទោះបីជារដ្ឋាភិបាល ឬ មិនមែនរដ្ឋាភិបាល និង ប្រជាពលរដ្ឋដែលពាក់ព័ន្ធជាមួយការអភិរក្ស ការគ្រប់គ្រង ការប្រើប្រាស់ធនធានជលផល ការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលត្រីគួរតែសហការគ្នាក្នុងការបំពេញអនុវត្តនូវគោលបំណង និង គោលការណ៍នានាដែលមាននៅក្នុងក្រមប្រតិបត្តិនេះ ។

៤.២ FAO អនុលោមទៅតាមតួនាទីព្រមទាំងប្រព័ន្ធអង្គការសហប្រជាជាតិនឹងត្រួតពិនិត្យការអនុវត្ត ការគ្រប់គ្រងក្រមប្រតិបត្តិ និង ឥទ្ធិពលលើវិស័យជលផល ហើយអគ្គលេខាធិការដ្ឋាននឹងធ្វើរបាយការណ៍ដោយផ្អែកទៅតាមគណៈកម្មការ ស្តីពីវិស័យជលផល(COFI) ។ គ្រប់ប្រទេសទាំងអស់ ទោះបីជាសមាជិក ឬ មិនមែនជាសមាជិករបស់ FAO ដូចជាស្ថាប័ន អន្តរជាតិពាក់ព័ន្ធ ទោះបីជារដ្ឋាភិបាល ឬ មិនមែនរដ្ឋាភិបាលគួរតែសហការជាមួយ FAO ក្នុងកិច្ចការនេះ ។

៤.៣ FAO តាមរយៈសមត្ថកិច្ចរបស់ខ្លួនអាចកែសំរួលក្រមប្រតិបត្តិដោយយកចិត្តទុកដាក់ដល់ការអភិវឌ្ឍនៅក្នុងជលផលដូចមានក្នុងរបាយការណ៍នានារបស់ COFI ស្តីពីការអនុវត្តរបស់ក្រមប្រតិបត្តិ ។

៤.៤ ស្ថាប័នជាតិ និង អន្តរជាតិនានាទោះបីរដ្ឋាភិបាល ឬ មិនមែនរដ្ឋាភិបាលគួរតែជំរុញអ្នកដែលចូលរួមក្នុងជលផលឱ្យបានយល់ពីក្រមប្រតិបត្តិ រួមមាន នៅទីណាដែលអាចអនុវត្តបានដោយណែនាំនូវគ្រោងការណ៍ដែលគួរតែឱ្យមានការទទួលស្គាល់ក្រមប្រតិបត្តិដោយស្ម័គ្រចិត្ត និង អនុវត្តប្រកបដោយប្រសិទ្ធិភាព។

## មាត្រា ៥ សំណូមពរពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍ

៥.១ ដើម្បីអនុវត្តទៅតាមអនុសាសន៏នានារបស់ក្រមប្រតិបត្តិនេះ ការពង្រឹងសមត្ថភាពរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍគួរតែត្រូវបានយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវ ។

៥.២ ដើម្បីសំរេចបាននូវគោលបំណងរបស់ក្រមប្រតិបត្តិនេះ ត្រូវមានការគាំទ្រយ៉ាងពេញទំហឹងក្នុងការអនុវត្ត បណ្តាប្រទេសពាក់ព័ន្ធ និង ស្ថាប័នអន្តរជាតិនានា ទោះបីជារដ្ឋាភិបាល ឬ មិនមែនរដ្ឋាភិបាល និង ស្ថាប័នហិរញ្ញវត្ថុនានាគួរតែផ្តល់ការកត់សំគាល់យ៉ាងមានប្រសិទ្ធិភាពចំពោះស្ថានភាពពិសេស និង អនុសាសន៏របស់បណ្តាប្រទេសកំពុងអភិវឌ្ឍ ។ ក្នុងនោះត្រូវចាប់អារម្មណ៍ជាពិសេសចំពោះបណ្តាប្រទេសអភិវឌ្ឍយឺត និង ប្រទេសកំពុងអភិវឌ្ឍដែលស្ថិតនៅលើកោះតូចៗ។

វិទ្យាសាស្ត្រដែលមានស្រាប់ល្អបំផុតអាចរកបាន ហើយក៏ត្រូវយកចិត្តទុកដាក់លើចំណេះដឹងដែលមានលក្ខណៈប្រពៃណីនៃធនធាន និង ទីជំរករបស់វា ដូចជា បរិស្ថានពាក់ព័ន្ធ កត្តាសេដ្ឋកិច្ចនិងសង្គមនានា ។បណ្តាប្រទេសគួរតែរៀបចំអត្ថិភាពដើម្បីធ្វើការស្រាវជ្រាវនិងប្រមូលទិន្នន័យ ដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងបច្ចេកទេស និង វិទ្យាសាស្ត្ររបស់ជលផលរួមទាំង អន្តរអំពើជាមួយនឹងប្រព័ន្ធអេកូឡូស៊ី ។ក្នុងការកត់សំគាល់ការឆ្លងកាត់ព្រំប្រទល់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិរបស់វារីជាតជាច្រើន បណ្តាប្រទេសគួរតែជំរុញកិច្ចសហការទ្វេភាគី និង ពហុភាគីក្នុងការងារស្រាវជ្រាវសមស្រប ។

៦.៥ បណ្តាស្ថាប័នគ្រប់គ្រងជលផលថ្នាក់ជាតិ អនុតំបន់ និង តំបន់គួរតែអនុវត្តឱ្យបានទូលំទូលាយនូវវិធីការពារទុកជាមុន សំរាប់ការអភិរក្ស ការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានវារីសត្វមានជីវិត ដើម្បីការពារវា និង រក្សាបរិស្ថានវារីជាត យកចិត្តទុកដាក់ទៅលើទឡ្ហីករណ៍វិទ្យាសាស្ត្រដែលមានស្រាប់ ។ អវត្តមាននៃព័ត៌មានវិទ្យាសាស្ត្រមិនគួរត្រូវបានប្រើប្រាស់ជាមូលហេតុសំរាប់អូសបន្លាយ ឬ ធ្វើឱ្យបរាជ័យក្នុងការចាត់វិធានការណ៍ដើម្បីអភិរក្សពូជមុខសញ្ញាជិតស្និទ្ធ ឬ ពឹងផ្អែក និង មិនមែនជាមុខសញ្ញា និង បរិស្ថានរបស់វា ។

៦.៦ សុវត្ថិភាពឧបករណ៍នេសាទ និង ការប្រតិបត្តិដោយមានការជ្រើសរើសនិងជិតស្និទ្ធទៅនឹងបរិស្ថានគួរតែត្រូវបានអភិវឌ្ឍ អនុវត្តឱ្យបានចំរើនទៅមុខ ដើម្បីពង្រីកវិសាលភាពប្រតិបត្តិផែទាំបរិស្ថានចំរុះអភិរក្សរចនាសម្ព័ន្ធប្រជាពល ប្រព័ន្ធអេកូឡូស៊ីវារីជាត និង ការពារគុណភាពត្រី ។ នៅទីណាដែលសុវត្ថិភាពឧបករណ៍នេសាទ ការអនុវត្តដោយមានការជ្រើសរើសស្និទ្ធទៅនឹងបរិស្ថានកើតឡើងគេគួរតែបានកត់សំគាល់ ហើយអនុញ្ញាតឱ្យមានជាអត្ថិភាពមួយក្នុងការស្ថាបនាការអភិរក្ស និង វិធានការសំរាប់ជលផល ។ បណ្តាប្រទេស និង អ្នកប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីវារីជាតគួរកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវកាកសំណល់ ផលចាប់មិនមែនជាមុខសញ្ញាទាំងពូជត្រី និង មិនមែនត្រី និង ឥទ្ធិពលលើពូជជិតស្និទ្ធ ឬ ពឹងផ្អែក ។

៦.៧ ការធ្វើអាជីវកម្ម ការថែរក្សា ការកែច្នៃ និង ការបែងចែកត្រី និង ផលិតផលត្រីគួរតែត្រូវបានអនុវត្តក្នុងឥរិយាបថមួយដែលនឹងរក្សាតំលៃចំណីអាហារគុណភាព និង សុវត្ថិភាព

របស់ផលិតផល កាត់បន្ថយកាកសំណល់ និង កាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវផលប៉ះពាល់វិជ្ជមាននានាលើបរិស្ថាន ។

៦.៨ ទីជំរកសំខាន់របស់ជលផលទាំងអស់នៅក្នុងប្រព័ន្ធបរិស្ថានសមុទ្រ និង ទឹកសាប ដូចជា ដីសើម ព្រៃកោងកាង ផ្កាថ្ម បឹងទឹកប្រៃក្បែរមាត់សមុទ្រ តំបន់បង្កាត់ភ្ញាស់នានាគួរតែត្រូវបានការពារ និង កសាងឡើងវិញតាមដែលអាចធ្វើទៅបាន ហើយសមស្របទៅតាមពេលវេលា ។ កិច្ចខិតខំពិសេសគួរតែត្រូវបានធ្វើដើម្បីការពារការបំផ្លាញ ការខូចខាតទីជំរក ការបំពុល និង ការជះឥទ្ធិពលសំខាន់ផ្សេងទៀតដែលជាលទ្ធផលបណ្តាលមកពីសកម្មភាពមនុស្សគំរាមកំហែងដល់សុខភាព និង សមត្ថភាពរបស់ធនធានជលផល ។

៦.៩ បណ្តាប្រទេសទាំងអស់គួរតែធានាថាផលប្រយោជន៍ជលផលរួមទាំងសេចក្តីត្រូវការសំរាប់ការអភិរក្សធនធានត្រូវបានយកចិត្តទុកដាក់នៅក្នុងការប្រើប្រាស់រួមនៃតំបន់ឆ្នេរ ហើយត្រូវបានធ្វើសមាហរណកម្មទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ដូចជា ការធ្វើផែនការ និង ការអភិវឌ្ឍ ។

៦.១០ ដោយគោរពដល់សមត្ថកិច្ច និង ការអនុញ្ញាតដោយច្បាប់អន្តរជាតិរាប់បញ្ចូលទាំងគ្រោងការណ៍របស់អនុតំបន់ ឬ តំបន់អភិរក្សជលផល និង ស្ថាប័នគ្រប់គ្រងឬការរៀបចំផ្សេងៗ បណ្តាប្រទេសគួរតែធានាការអនុវត្តជាមួយនឹងការបង្ខំឱ្យអភិរក្សតាម និង មានវិធានការគ្រប់គ្រងហើយបង្កើតយន្តការប្រសិទ្ធិភាពសមស្រប ដើម្បីឈ្លបមើល និង ត្រួតពិនិត្យសកម្មភាពរបស់នាវានេសាទ និង នាវាជួយគាំទ្រការនេសាទទាំងនោះ ។

៦.១១ បណ្តាប្រទេស អាជ្ញាធរនេសាទ និង នាវានេសាទគាំទ្រដែលបង្ហូតទង់ជាតិរបស់ខ្លួនគួរតែធ្វើលំហាត់ត្រួតពិនិត្យឱ្យមានប្រសិទ្ធិភាពលើនាវានេសាទទាំងនោះ ដើម្បីធានាការអនុវត្តឱ្យស្របទៅតាមក្រមប្រតិបត្តិនេះ ។ គេគួរតែធានាថា សកម្មភាពរបស់នាវានេសាទទាំងអស់មិនធ្វើឱ្យអន្តរាយដល់ប្រសិទ្ធិភាពនៃវិធានការអភិរក្ស និង គ្រប់គ្រងស្របទៅនឹងច្បាប់អន្តរជាតិហើយដែលត្រូវបានអនុម័តនៅថ្នាក់ជាតិ អនុតំបន់ តំបន់ និង ពិភពលោក ។ បណ្តា

ប្រទេសគួរតែធានាថា នាវាដែលបង្ហូតទង់ជាតិរបស់គេនឹងបំពេញកាតព្វកិច្ចពាក់ព័ន្ធដល់ការជ្រើសរើស និង ផ្តល់ចិទ្ធន័យទាក់ទងទៅនឹងសកម្មភាពនេសាទនានារបស់គេ ។

៦.១២ បណ្តាប្រទេសគួរតែគោរពដល់សមត្ថកិច្ចដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ ដើម្បីសហការនៅថ្នាក់អនុតំបន់ តំបន់ និង ពិភពលោកតាមរយៈស្ថាប័នគ្រប់គ្រងជលផលនានា កិច្ចព្រមព្រៀងអន្តរជាតិ ឬ ការរៀបចំផ្សេងទៀត ដើម្បីជំរុញការអភិរក្ស និង គ្រប់គ្រងធានាការនេសាទប្រកបដោយភាពទទួលខុសត្រូវ និង ធានាប្រសិទ្ធិភាពការអភិរក្ស និង ការការពារធនធានវារីជាតមានជីវិតក្នុងចន្លោះនៃរបាយរបស់វាយកចិត្តទុកដាក់នូវតម្រូវការដោយវិធានសំរុះសំរួលគ្នានៅក្នុងតំបន់ជាមួយនឹង ឬ ក្រៅពីនិតិប្បញ្ញត្តិ ។

៦.១៣ បណ្តាប្រទេសគួរតែពង្រីកវិសាលភាពអនុញ្ញាតដោយច្បាប់ និង បទបញ្ជាផ្សេងៗថ្នាក់ជាតិ ធានាដល់ដំណើរការធ្វើសេចក្តីសម្រេចចិត្តដោយតម្លាភាពត្រឹមត្រូវច្បាស់លាស់ហើយសំរេចបានទៅតាមពេលវេលាកំណត់នូវរាល់ដំណោះស្រាយបញ្ហាបន្ទាន់នានា ។ បណ្តាប្រទេសដោយអនុលោមទៅតាមដំណើរការសមស្របនានាគួរតែបានសម្របសម្រួល និង ពិភាក្សា និង ប្រសិទ្ធិភាពចូលរួមរបស់ឧស្សាហកម្ម ពលករនេសាទ បរិស្ថាន និង ស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយគោរពទៅដល់ការអភិវឌ្ឍច្បាប់ និង គោលនយោបាយពាក់ព័ន្ធការគ្រប់គ្រងជលផល ការអភិវឌ្ឍ ការឱ្យខ្ចី និង ជំនួយអន្តរជាតិនានា ។

៦.១៤ ការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលមានដើមកំណើតពីវារីជាតគួរតែត្រូវបានអនុវត្តដោយអនុលោមតាមគោលការណ៍សិទ្ធិ និង កាតព្វកិច្ចដែលបានបង្កើតឡើងនៅក្នុងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មអន្តរជាតិ(WTO) និងកិច្ចសន្យាអន្តរជាតិពាក់ព័ន្ធផ្សេងទៀត។ បណ្តាប្រទេសគួរតែធានានូវគោលនយោបាយ កម្មវិធីការងារប្រតិបត្តិពាក់ព័ន្ធរបស់គេដល់ការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារីជាតមិនធ្វើឱ្យរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មនេះ ការខូចខាតបរិស្ថាន ឬ ឥទ្ធិពលអវិជ្ជមានដល់សង្គមរួមទាំងអាហារូបត្ថម្ភផង។

៦.១៥ បណ្តាប្រទេសគួរតែសហការដើម្បីទប់ស្កាត់រាល់ទំនាស់។ រាល់ទំនាស់ដែលពាក់ព័ន្ធទៅ

និងសកម្មភាព និង ប្រតិបត្តិអាជីវកម្មនេសាទគួរតែត្រូវបានដោះស្រាយក្នុងពេលវេលាមួយ ដោយសន្តិវិធី និង ដោយតំរិយាបថសហប្រតិបត្តិការដោយអនុលោមទៅតាមកិច្ចព្រមព្រៀងអន្តរជាតិដែលអាចអនុវត្តបាន ឬ ដូចដែលបានឯកភាពរវាងភាគីទាំងអស់ ។ ក្នុងអំឡុងពេលសម្រុះសម្រួលទំនាស់មួយបណ្តាប្រទេសដែលពាក់ព័ន្ធគួរតែខិតខំ ដើម្បីចូលទៅក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងជាក់ស្តែងនៃធម្មជាតិលទ្ធផលដែលបានពីវិធានការសម្រុះសម្រួលទំនាស់ដែលគួរតែគ្មានការលំអៀង និង ប្រកាន់ពូជសាសន៍ ។

៦.១៦ បណ្តាប្រទេស គួរកត់សំគាល់ដល់សារៈសំខាន់ដ៏ឧត្តុងឧត្តមរបស់ប្រជានេសាទ និង វារីវប្បករយល់ពីការអភិរក្ស និង ការគ្រប់គ្រងធនធានជលផលដែលគេពឹងអាស្រ័យលើ គួរតែជំរុញការចាប់អារម្មណ៍ពីភាពទទួលខុសត្រូវជលផលតាមរយៈការអប់រំ និង វគ្គបំពាក់បំប៉នខ្លីៗ។ គេគួរតែធានាថា ប្រជានេសាទ និង វារីវប្បករបានចូលរួមចំណែកក្នុងការរៀបចំគោលនយោបាយ និង ដំណើការអនុវត្ត ហើយក៏សម្របសម្រួលឱ្យស្របទៅនឹងការអនុវត្តរបស់ក្រមប្រតិបត្តិ ។

៦.១៧ បណ្តាប្រទេសគួរតែធានាសុវត្ថិភាពក្នុងការប្រើប្រាស់ឧបករណ៍ សំភារៈនេសាទ សុខុមាលភាព ធ្វើការស្មើភាពគ្រប់សកម្មភាពជលផល និង លក្ខខណ្ឌរស់នៅនានា ហើយឆ្លើយតបទៅនឹងបទដ្ឋានដែលបានឯកភាពជាអន្តរជាតិអនុម័តដោយស្ថាប័នអន្តរជាតិនានាពាក់ព័ន្ធ ។

៦.១៨ កត់សំគាល់ដល់សារៈសំខាន់ទូវការចូលរួមរបស់ជលផលដែលមានលក្ខណៈសិប្បកម្ម និង លក្ខណៈគ្រួសារចំពោះការងារធ្វើ ចំណូលប្រចាំថ្ងៃ និង សុវត្ថិភាពស្បៀងអាហារ បណ្តាប្រទេសគួរ តែការពារឱ្យបានសមស្របនូវសិទ្ធិរបស់ប្រជានេសាទ និង ពលករនេសាទជាពិសេសអ្នកទាំង ឡាយណាដែលជាប់នៅក្នុងជលផលគ្រាន់តែចិញ្ចឹមជីវិត លក្ខណៈគ្រួសារ និង លក្ខណៈសិប្បកម្ម ដើម្បីគ្រាន់តែត្រៀមបំរុង និង សំរាប់ចិញ្ចឹមជីវិតរាល់ថ្ងៃដូចដែលចូលចិត្តធ្វើទៅពេលណាដែលសមស្របចំពោះបរិវេណនេសាទប្រពៃណី និង ធនធានក្នុងទឹកស្ថិតក្រោមនិតិប្បញ្ញត្តិរបស់ប្រទេសគេ ។

៦.១៩ បណ្តាប្រទេសគួរតែយកចិត្តទុកដាក់ដល់វារីវប្បកម្ម រួមទាំងផលផលដែលពឹងផ្អែកលើវារីវប្បកម្មជាមូលដ្ឋានជាមធ្យោបាយដើម្បីជំរុញឱ្យមានភាពផ្សេងគ្នារបស់ចំណូល និង របបអាហារ ។ ធ្វើបែបនេះ បណ្តាប្រទេសគួរតែធានាថាធនធានត្រូវបានប្រើប្រាស់ប្រកបដោយភាពទទួលខុសត្រូវ និង ផលប៉ះពាល់លើបរិស្ថាន និង លើសហគមន៍មូលដ្ឋានត្រូវបានកាត់បន្ថយដល់កំរិតអប្បបរមា ។

## មាត្រា ៧ ការគ្រប់គ្រងផលផល

### ៧.១ ទូទៅ

៧.១.១ បណ្តាប្រទេស និង អ្នកទាំងឡាយណាដែលជាប់ពាក់ព័ន្ធក្នុងការគ្រប់គ្រងផលផលគួរតែតាមរយៈគោលនយោបាយសមស្របច្បាប់ និង គ្រោងការណ៍ស្ថាប័នអនុម័តវិធានការណ៍សំរាប់ការអភិរក្ស និង ការប្រើប្រាស់ធនធានផលផលប្រកបដោយនិរន្តរភាពរយៈពេលយូរអង្វែង ។ វិធានការអភិរក្ស និង គ្រប់គ្រងទោះបីនៅថ្នាក់មូលដ្ឋាន ជាតិ អនុតំបន់ ឬ តំបន់ត្រូវតែផ្អែកលើទន្និករណ៍មូលដ្ឋានវិទ្យាសាស្ត្រដែលមានស្រាប់អាចរកបានហើយត្រូវរៀបចំដើម្បីធានានូវនិរន្តរភាពធនធានរបស់វិស័យផលផលឱ្យនៅកំរិតមួយដែលអាចជំរុញទៅតាមគោលបំណងនៃការប្រើប្រាស់នៅកំរិតអតិបរមាសមស្របបំផុត ហើយថែរក្សាសំរាប់ជំនាន់បច្ចុប្បន្ននិងអនាគត ការយកចិត្តទុកដាក់បែបនេះសមស្របតែទៅនឹងគោលបំណងសំរាប់រយៈពេលខ្លីប៉ុណ្ណោះ ។

៧.១.២ ចំពោះតំបន់ដែលស្ថិតនៅក្រោមនិតិប្បញ្ញត្តិជាតិបណ្តាប្រទេសគួរតែស្វែងរកដើម្បីកំណត់ភាគីក្នុងស្រុកដែលពាក់ព័ន្ធមានសារប្រយោជន៍ស្របច្បាប់ក្នុងការប្រើប្រាស់ និង ការគ្រប់គ្រងធនធានផលផល ហើយរៀបចំដើម្បីប្រឹក្សាយោបល់ជាមួយពួកគេ ដើម្បីបង្កើនកិច្ចសហការរបស់គាត់ឱ្យទទួលបានជោគជ័យប្រកបដោយភាពទទួលខុសត្រូវវិស័យផលផល ។

៧.១.៣ ចំពោះសន្ធិសញ្ញាដែលឆ្លងកាត់ព្រំប្រទល់ សន្ធិសញ្ញាច្រកតាវ សន្ធិសញ្ញាដែលធ្វើចរាចរឆ្ងាយ និង សន្ធិសញ្ញាសមុទ្រក្រៅ នៅទីណាដែលសន្ធិសញ្ញាទាំងនេះត្រូវបានបំផ្លាញដោយប្រទេសពីរ ឬ ច្រើន បណ្តាប្រទេសដែលពាក់ព័ន្ធព្រមទាំងបណ្តាឆ្នេរប្រទេសពាក់ព័ន្ធ ក្នុងករណីដែលសន្ធិសញ្ញាច្រកតាវសន្ធិសញ្ញាដែលធ្វើចរាចរឆ្ងាយគួរតែសហការគ្នាដើម្បីធានានូវប្រសិទ្ធិភាពអភិរក្ស និង ការគ្រប់គ្រងធនធាន។ ការងារនេះគួរតែត្រូវបានសំរេចនៅពេលសមស្របណាមួយតាមរយៈការបង្កើត ឬ រៀបចំស្ថាប័នជលផលទ្វេភាគី អនុតំបន់ ឬ តំបន់ ។

៧.១.៤ ការរៀបចំ ឬ ស្ថាប័នគ្រប់គ្រងជលផលថ្នាក់អនុតំបន់ ឬ តំបន់គួរតែរាប់បញ្ចូលទាំងតំណាងប្រទេសនានាក្នុងយុត្តាធិការធនធានដែលកើតឡើង ដូចជាតំណាងពីបណ្តាប្រទេសដែលមានប្រយោជន៍ពិតប្រាកដនៅក្នុងជលផល ឬ ធនធាននៅក្រៅយុត្តាធិការជាតិ ។ នៅទីណាដែលស្ថាប័ន ឬ ការរៀបចំគ្រប់គ្រងជលផល អនុតំបន់ ឬ តំបន់កើតមាន ហើយមានសមត្ថភាព ដើម្បីរៀបចំវិធានការអភិរក្ស និង ការគ្រប់គ្រង បណ្តាប្រទេសទាំងនោះគួរតែសហការគ្នាដោយប្រែក្លាយប្រទេសផ្សេងទៀតឱ្យទៅជាសមាជិករបស់ស្ថាប័នទាំងនោះ ឬ ចូលរួមក្នុង និង ចូលរួមយ៉ាងសកម្មក្នុងការងាររបស់គេ ។

៧.១.៥ ប្រទេសណាដែលមិនមែនជាសមាជិកនៃស្ថាប័នគ្រប់គ្រងជលផលថ្នាក់អនុតំបន់ ឬ តំបន់ ឬ មិនបានចូលរួមក្នុងការរៀបចំគ្រប់គ្រងជលផលថ្នាក់អនុតំបន់ ឬ តំបន់គួរតែសហការផ្អែកលើកិច្ចព្រមព្រៀងអន្តរជាតិ ឬ ច្បាប់អន្តរជាតិក្នុងការអភិរក្ស និង គ្រប់គ្រងពាក់ព័ន្ធទៅនឹងធនធានជលផលដោយផ្តល់ប្រសិទ្ធិភាពទៅលើវិធានការអភិរក្ស និង គ្រប់គ្រងដែលបានអនុម័តដោយបណ្តាស្ថាប័ន និង ការរៀបចំទាំងនោះ ។

៧.១.៦ អ្នកតំណាងមកពីស្ថាប័នពាក់ព័ន្ធទាំងរដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធជាមួយជលផលគួរតែត្រូវបានលៃលកឱកាសដើម្បីទទួលយកចំណែកក្នុងកិច្ចប្រជុំរបស់ស្ថាប័ន និង ការរៀបចំគ្រប់គ្រងជលផលក្នុងអនុតំបន់ និង តំបន់ដូចជាអ្នកសង្កេតការណ៍ ឬ បើមិនដូច្នោះទេអនុញ្ញាតទៅតាមវិធានការសមស្របនានារបស់ស្ថាប័ន ឬការរៀបចំពាក់ព័ន្ធ

អ្នកតំណាងទាំងអស់គួរតែបានផ្ដល់ពេលវេលាចូលទៅកត់ត្រា និង រាយការណ៍ជូនអង្គប្រជុំនូវកម្មវត្ថុ និង វិធានការច្បាប់លើការចូលរួមរបស់គេ ។

៧.១.៧ បណ្ដាប្រទេសគួរតែបង្កើតយន្តការប្រសិទ្ធិភាពមួយដើម្បីធ្វើការឈ្លបមើលតាមដាន ត្រួតពិនិត្យ និង បង្ខំឱ្យអនុវត្តច្បាប់ជលផលដើម្បីធានានូវការយល់ព្រមជាមួយនឹងវិធានការអភិរក្ស និង គ្រប់គ្រងដោយគោរពដល់សមត្ថភាពពាក់ព័ន្ធ និង កាច់ាស៊ីតេរបស់គេដូចអ្វីដែលបានអនុម័តិដោយស្ថាប័ន និង ការរៀបចំនានានៅថ្នាក់អនុតំបន់ និង តំបន់ ។

៧.១.៨ បណ្ដាប្រទេសគួរតែមានវិធានការការពារ ឬ លុបបំបាត់ការធ្វើអាជីវកម្មលើសហួសកំរិតសមត្ថភាពនិងគួរតែធានានូវកំរិតថាមពលការធ្វើអាជីវកម្មឱ្យប្រហាក់ប្រហែលទៅនឹងការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពវិស័យជលផលជាមធ្យោបាយមួយនៃការធានានូវប្រសិទ្ធិភាពវិធានការការអភិរក្ស និង ការគ្រប់គ្រង ។

៧.១.៩ បណ្ដាប្រទេស និង ការរៀបចំគ្រប់គ្រងជលផលអនុតំបន់ ឬ តំបន់គួរតែធានានូវភាពច្បាស់លាស់ត្រឹមត្រូវក្នុងយន្តការសំរាប់ការគ្រប់គ្រង និង ពាក់ព័ន្ធដល់ដំណើរការធ្វើសេចក្ដីសំរេចចិត្តនានា ។

៧.១.១០ បណ្ដាប្រទេស និង ការរៀបចំគ្រប់គ្រងជលផលអនុតំបន់ ឬតំបន់គួរតែផ្ដល់ជាសាធារណៈនូវវិធានការអភិរក្ស និង គ្រប់គ្រងហើយធានាថាច្បាប់ បទបញ្ជា និង និតិប្បញ្ញត្តិរដ្ឋបាលផ្សេងទៀតនៃការអនុវត្តរបស់គេត្រូវបានផ្សព្វផ្សាយបែងចែកប្រកបដោយប្រសិទ្ធិភាពបណ្ដាវិធានការមូលដ្ឋានគ្រឹះ និង គោលបំណងគួរតែត្រូវបានពន្យល់ដល់អ្នកប្រើប្រាស់ធនធានទាំងអស់ដើម្បីសម្របសម្រួលការងារប្រតិបត្តិរបស់គេហើយបង្កើនការចូលរួមគាំទ្រការអនុវត្តនូវបណ្ដាវិធានការទាំងនោះ ។

### ៧.២ គោលបំណងនៃការគ្រប់គ្រង

៧.២.១ កំណត់សំគាល់ការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពយូរអង្វែងគឺជាជោគជ័យនៃគោលបំណងនៃការអភិរក្ស និង ការគ្រប់គ្រងគ្រប់ស្ថាប័ន និង ការរៀបចំ គ្រប់គ្រងជលផលប្រទេស និង អនុតំបន់ ឬ តំបន់គួរតែអនុម័តិវិធានការសមស្រប

ដោយផ្អែកលើទន្និករណីវិទ្យាសាស្ត្រល្អបំផុតដែលមានស្រាប់ ហើយអាចរកបានរៀបចំឡើង ដើម្បីថែរក្សា ឬ កសាងឡើងវិញនូវសន្និធិឱ្យមានសមត្ថភាពអាចផលិតក្នុងកំរិតអតិបរមាសមស្រប ដូចជា គុណភាពបរិស្ថានដែលពាក់ព័ន្ធកត្តាសេដ្ឋកិច្ច គិតទាំងសំណូមពរចាំបាច់ពិសេសរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍ ។

៧.២.២ បណ្តាវិធានការទាំងអស់គួរតែផ្តល់

ក) ការធ្វើអាជីវកម្មលើសហួសសមត្ថភាពផលស្តុកចម្មជាតិត្រូវតែចៀសវាង ហើយការធ្វើអាជីវកម្មលើសន្និធិនៅតែអាចសម្រេចបានសេដ្ឋកិច្ចខ្ពស់ ។

ខ) លក្ខខណ្ឌសេដ្ឋកិច្ចនានាស្ថិតក្រោមការប្រតិបត្តិឧស្សាហកម្មនេសាទលើកទឹកចិត្តភាពទទួលខុសត្រូវវិស័យផលផល ។

គ) សារៈប្រយោជន៍របស់ប្រជានេសាទរួមទាំងអ្នកទាំងឡាយដែលជាប់នៅក្នុងផលផលគ្រាន់តែចិញ្ចឹមជីវិត លក្ខណៈគ្រួសារ និង លក្ខណៈសិប្បកម្មត្រូវបានយកចិត្តទុកដាក់ ។

ឃ) ទីជំរកជីវសាស្ត្រចម្រុះរបស់វារិជាត និង ប្រព័ន្ធអេកូឡូស៊ីត្រូវបានអភិរក្សហើយប្រភេទពូជដែលកំពុងរងគ្រោះថ្នាក់ត្រូវបានការពារ ។

ង) សន្និធិដែលបានបំផ្លិចបំផ្លាញអនុញ្ញាតឱ្យកែលំអឡើងវិញ ឬ នៅទីណាដែលសមស្របត្រូវតែសកម្មក្នុងការកែលំអ ។

ច) ឥទ្ធិពលដែលបរិស្ថានមិនអំណោយផលទៅលើធនធានពីសកម្មភាពមនុស្សត្រូវបានថាំប្រមាណ និង កែតំរូវនៅពេលដែលសមស្រប ។

ឆ) ការបំពុល ការបញ្ចេញចោលកាកសំណល់ ការជ្រើសចោលផលនេសាទដែលជាប់ក្នុងខ្មោចឧបករណ៍ ផលចាប់ដែលមិនមែនមុខសញ្ញាទាំងប្រភេទត្រី និង មិនមែនត្រី និង ឥទ្ធិពលដែលជិតស្និទ្ធ ឬ ប្រភេទពឹងផ្អែកត្រូវបានកាត់បន្ថយឱ្យដល់កំរិតអប្បបរមាតាមរយៈវិធានការនានា រួមមានដើម្បីពង្រីកវិសាលភាពដែលអាចប្រតិបត្តិបាននូវការអភិវឌ្ឍ និង ការប្រើប្រាស់ជំរើសសុវត្ថិភាពបរិស្ថាន និង ប្រសិទ្ធិភាពតំលៃឧបករណ៍ និង បច្ចេកទេសនេសាទ ។

៧.២.៣ បណ្តាប្រទេសគួរតែចាប់ប្រមាណផលប៉ះពាល់បរិស្ថានទៅលើសន្និធិមុខសញ្ញា និងប្រភេទពូជដែលស្ថិតនៅក្រោមប្រព័ន្ធបរិស្ថានដូចគ្នា ឬ ជិតស្និទ្ធិជាមួយគ្នា ឬ ពឹងផ្អែកលើមុខសញ្ញាសន្និធិ ហើយចាប់ស្មានទំនាក់ទំនងចំណោមប្រជាពលក្នុងប្រព័ន្ធអេកូឡូស៊ី ។

៧.៣ គ្រោងការណ៍ និង វិធានការគ្រប់គ្រង

៧.៣.១ ដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងជលផលគួរតែមានទំនាក់ទំនងជាមួយផ្នែកនៃសន្និធិទាំងមូលដែលគ្របដណ្តប់លើតំបន់របស់អង្គភាពនៃរបាយ និង យកចិត្តទុកដាក់ដល់វិធានការគ្រប់គ្រងដែលបានរៀបចំ និង អនុម័តិកន្លងមក ហើយអនុវត្តនៅក្នុងតំបន់ដូចគ្នា គ្រប់សន្និធិដែលបានដកហូតការឯកភាពជីវសាស្ត្រ និង លក្ខណៈជីវសាស្ត្ររបស់សន្និធិផ្សេងទៀត។ ទន្និករណីវិទ្យាសាស្ត្រល្អបំផុតដែលមានស្រាប់អាចរកបានគួរតែត្រូវបានប្រើប្រាស់សំរាប់កំណត់តំលាតតំបន់នៃរបាយរបស់ធនធាន និង តាមរយៈតំបន់ដែលវាផ្លាស់ទីក្នុងរយៈពេលនៃវដ្តជីវិតរបស់វា ។

៧.៣.២ ដើម្បីអភិរក្ស និងគ្រប់គ្រងសន្និធិត្រីឆ្លងកាត់ព្រំប្រទល់សន្និធិត្រីច្រកតាវសន្និធិត្រីដែលធ្វើចរាចរឆ្ងាយ និង សន្និធិត្រីសមុទ្រក្រៅនៅក្នុងចន្លោះវិធានការអភិរក្ស និងការគ្រប់គ្រងដែលបានរៀបចំឡើងសំរាប់សន្និធិទាំងនោះដោយគោរពទៅតាមសមត្ថកិច្ចរបស់បណ្តាប្រទេសពាក់ព័ន្ធ ឬ ទីណាដែលសមរម្យតាមរយៈស្ថាប័ន និង ការរៀបចំគ្រប់គ្រងជលផលថ្នាក់អនុតំបន់ និង តំបន់គួរតែបានស្រុះស្រួលគ្នា។ ការសម្រុះសម្រួលគួរតែសំរេចបានជោគជ័យក្នុងឥរិយាបថមួយរលូនជាមួយសិទ្ធិ សមត្ថភាព និង ផលប្រយោជន៍របស់បណ្តាប្រទេសដែលជាប់ពាក់ព័ន្ធ ។

៧.៣.៣ គោលបំណងគ្រប់គ្រងយូរអង្វែងគួរតែត្រូវបានបកប្រែពន្យល់នៅក្នុងសកម្មភាពគ្រប់គ្រង រៀបចំ ដូចជា ការធ្វើផែនការគ្រប់គ្រងជលផល ឬ គ្រោងការណ៍គ្រប់គ្រងផ្សេងទៀត ។

៧.៣.៤ បណ្តាប្រទេស និង អនុតំបន់ ឬ ស្ថាប័ន និង ការរៀបចំគ្រប់គ្រងជលផលតំបន់នានាគួរតែផ្តត់ផ្តង់និងជំរុញកិច្ចសហប្រតិបត្តការអន្តរជាតិ និងសម្របសម្រួលគ្រប់ការងារ

ទាំងអស់ដែលទាក់ទងទៅនឹងជលផល រួមទាំងការប្រមូល និង ផ្លាស់ប្តូរព័ត៌មាន ការងារស្រាវជ្រាវ ការគ្រប់គ្រង និង ការអភិវឌ្ឍ ។

៧.៣.៥ បណ្តាប្រទេសកំពុងស្វែងរកការធ្វើសកម្មភាពណាមួយតាមរយៈស្ថាប័នមិនមែនជលផលដែលមានឥទ្ធិពលទៅលើវិធានការអភិរក្ស និង ការគ្រប់គ្រងជលផលដែលទទួលខុសត្រូវដោយសមត្ថកិច្ចអនុតំបន់ តំបន់ ឬការរៀបចំនានាគួរតែពិភាក្សាទៅពេលក្រោយដោយស៊ុជំរៅជលវិសាលភាពដែលអាចប្រតិបត្តិបាន និង យកមកសិក្សាលំអិតឡើងវិញ ។

## ៧.៤ ការប្រមូលទិន្នន័យ និង ដំបូន្មានគ្រប់គ្រង

៧.៤.១ នៅពេលដែលយកចិត្តទុកដាក់លើការអនុម័តវិធានការអភិរក្ស និង ការគ្រប់គ្រងទឡ្ហីករណ៍វិទ្យាសាស្ត្រល្អបំផុតដែលមានស្រាប់អាចរកបានគួរតែចាប់អារម្មណ៍ ដើម្បីវាយតំលៃស្ថានភាពបច្ចុប្បន្នរបស់ធនធានជលផល និងឥទ្ធិពលដែលអាចកើតមានពីសំណើវិធានការស្តីពីធនធាន ។

៧.៤.២ ការស្រាវជ្រាវដើម្បីគាំទ្រដល់ការអភិរក្ស និង ការគ្រប់គ្រងវិស័យជលផលគួរតែត្រូវបានជំរុញរួមបញ្ចូលទាំងការងារស្រាវជ្រាវលើធនធាន និង ឥទ្ធិពលរបស់បរិយាកាសកត្តាបរិស្ថាន និង សេដ្ឋកិច្ចសង្គម។ លទ្ធផលនៃការពិសោធន៍ ស្រាវជ្រាវទាំងនោះគួរតែត្រូវបានបែងចែក ផ្សព្វផ្សាយទៅដល់ភាគីដែលពាក់ព័ន្ធ ។

៧.៤.៣ ការសិក្សាគួរតែត្រូវបានជំរុញផ្តល់ឱ្យមានការយល់ពីតំលៃសារប្រយោជន៍ និង ឥទ្ធិពលនៃការជ្រើសរើស រៀបចំការគ្រប់គ្រងជំនួសដើម្បីធ្វើសនិទានកម្ម ការធ្វើនេសាទជាពិសេសការជ្រើសរើសដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្មលើសហួសពីសមត្ថភាព និង លើសហួសពីកំរិតថាមពលនេសាទ ។

៧.៤.៤ បណ្តាប្រទេសគួរតែធានាប្រមូល រក្សា បំពេញ និង ស្ថិតិស្តីពីការប្រមូលផល និង ថាមពលនេសាទឱ្យបានទៀងទាត់ពេលវេលាដោយអនុលោម និង អនុវត្តទៅតាមបទដ្ឋានអន្តរជាតិ ហើយបរិយាយលំអិតក្នុងការវិភាគស្ថិតិ ។ បណ្តាទិន្នន័យគួរតែត្រូវបានធ្វើឱ្យទាន់សម័យជាប្រចាំ ហើយកែលំអតាមរយៈប្រព័ន្ធដែលសមស្រប ។ បណ្តាប្រទេសគួរតែ

ប្រមូល និង បែងចែកទិន្នន័យទាំងអស់ក្នុងរបៀបរហ័សទាន់ពេលវេលាទៀងទាត់ និងប្រកបដោយសង្គតិភាព ហើយស្របតាមវិធានការរក្សាការសម្ងាត់ចាំបាច់ ដែលអាចអនុវត្តបាន ។

៧.៤.៥ ដើម្បីធានាចីរភាពគ្រប់គ្រងវិស័យជលផល ហើយដើម្បីទទួលបានជោគជ័យនៃគោលបំណងសេដ្ឋកិច្ច និង សង្គម កត្តាចំណេះដឹងសង្គម សេដ្ឋកិច្ច និង ស្ថាប័នគួរតែត្រូវបានអភិវឌ្ឍតាមរយៈការប្រមូលព័ត៌មាន ការវិភាគ និង ការស្រាវជ្រាវ ។

៧.៤.៦ បណ្តាប្រទេសគួរតែប្រមែប្រមូលទិន្នន័យវិស័យជលផលពាក់ព័ន្ធ និង ទិន្នន័យវិទ្យាសាស្ត្រពាក់ព័ន្ធនឹងទិន្នន័យសន្និធិត្រីដែលគ្រប់គ្រងដោយស្ថាប័ន និង ការរៀបចំគ្រប់គ្រងជលផលថ្នាក់អនុតំបន់ ឬ តំបន់ក្នុងទំរង់មួយឯកភាពជាលក្ខណៈអន្តរជាតិ ហើយផ្តល់ឱកាសឱ្យស្ថាប័នរៀបចំឱ្យបានទាន់ពេលវេលា ។ ក្នុងករណីធនធានកើតឡើងនៅក្នុងយុត្តាធិការដែលគ្រប់គ្រងដោយប្រទេសច្រើនជាងមួយ ហើយដែលនៅទីនោះគ្មានស្ថាប័ន ឬ ការរៀបចំណាមួយ បណ្តាប្រទេសពាក់ព័ន្ធគួរតែឯកភាពគ្នាស្តីពីយន្តការសំរាប់សហការក្នុងការប្រមូល និង ផ្លាស់ប្តូរទិន្នន័យទាំងនោះ ។

៧.៤.៧ បណ្តាស្ថាប័ន និង ការរៀបចំគ្រប់គ្រងជលផលថ្នាក់អនុតំបន់ ឬ តំបន់គួរតែប្រមែប្រមូលទិន្នន័យនិងរៀបចំឱ្យហើយស្រេចក្នុងរបៀបមួយរលូនជាមួយនឹងសំណូមពរសំងាត់ចាំបាច់ដែលអនុវត្តបានទៅតាមពេលវេលាមួយទៀងទាត់ និង នៅក្នុងទំរង់មួយឯកភាពពីគ្រប់សមាជិករបស់ស្ថាប័ន និងបណ្តាភាគីដែលចាប់អារម្មណ៍ដោយផ្អែកលើវិធានការដែលបានអនុម័ត ។

### ៧.៥ របៀបប្រុងប្រយ័ត្នការពារទុកជាមុន

៧.៥.១ បណ្តាប្រទេសគួរតែអនុវត្តឱ្យបានទូលំទូលាយនូវរបៀបប្រុងប្រយ័ត្នការពារទុកជាមុនសំរាប់ការអភិរក្ស ការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានវារីជាតិ ដើម្បីការពារវា ហើយបង្ការបរិស្ថានវារីជាតិ ។ អវត្តមាននៃព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់មិនគួរត្រូវបានប្រើប្រាស់ជាមូលហេតុសំរាប់អូសបន្លាយឬ ធ្វើឱ្យបរាជ័យក្នុងវិធានការអភិរក្ស និង ការគ្រប់គ្រង ។

៧.៥.២ នៅក្នុងការអនុវត្តរបៀបប្រុងប្រយ័ត្នការពារទុកជាមុន បណ្តាប្រទេសគួរតែយកចិត្តទុកដាក់ដល់ការពាក់ព័ន្ធដោយចៃដន្យទៅដល់ទំហំ និង ផលិតភាពរបស់សន្និធិចំណុចបង្អែក លក្ខខណ្ឌសន្និធិដែលទាក់ទងទៅនឹងបណ្តាចំណុចបង្អែក គ្រិត និង រចាយនៃការងាប់ដោយការធ្វើអាជីវកម្មនេសាទ និង ឥទ្ធិពលរបស់សកម្មភាពនេសាទរាប់បញ្ចូលទាំងការទាត់ចោលនូវពូជដែលមិនមែនជាមុខសញ្ញា និង ពូជជិតស្និទ្ធ ឬ ពូជឯករាជ្យព្រមទាំងលក្ខខណ្ឌបរិស្ថាន និង សេដ្ឋកិច្ចសង្គមនានា ។

៧.៥.៣ បណ្តាស្ថាប័ន និង ការរៀបចំគ្រប់គ្រងជលផលរបស់ប្រទេស អនុតំបន់ ឬ តំបន់គួរតែផ្អែកលើមូលដ្ឋានទទ្បីករណីវិទ្យាសាស្ត្រដែលល្អបំផុតមានស្រាប់អាចរកបានដើម្បីកំណត់:

ក) មុខសញ្ញាសន្និធិចំណុចបង្អែក នៅពេលជាមួយគ្នាត្រូវមានវិធានការ ប្រសិនបើគេធ្វើហួសលើសពីនេះ ។

ខ) ចំណុកបង្អែកសន្និធិលីមីតពិតប្រាកដ នៅពេលជាមួយគ្នាសកម្មភាពត្រូវបានចាត់វិធានការ ប្រសិនបើគេធ្វើហួសលើសពីនេះនៅពេលដែលចំណុចបង្អែកខិតជិតមកដល់ការវាស់វែងគួរតែត្រូវបានចាប់ផ្តើម ដើម្បីធានាថាវាមិនត្រូវបានធ្វើអាជីវកម្មលើសហួសកំណត់ ។

៧.៥.៤ ក្នុងករណីនៃជលផលដែលបានធ្វើ ឬ ដែលមិនទាន់ធ្វើអាជីវកម្ម បណ្តាប្រទេសគួរតែអនុម័តិវិធានការអភិរក្ស ហើយគ្រប់គ្រងដោយប្រុងប្រយ័ត្នដែលអាចធ្វើទៅបានកាន់តែរហ័សកាន់តែប្រសើរ រួមទាំងការលីមីតផលចាប់ និង លីមីតថាមពល ។ ការវាស់វែងទាំងឡាយគួរតែត្រូវបានរក្សាទុកជាធរមានរហូតដល់មានទិន្នន័យគ្រប់គ្រាន់អនុញ្ញាតឱ្យមានការវាយតំលៃកត្តាជះឥទ្ធិពលរបស់ជលផលទៅលើនិរន្តរភាពសន្និធិជលផលយូរអង្វែង ខណៈនោះវិធានការនៃការអភិរក្ស និង ការគ្រប់គ្រងដែលបានផ្អែកលើការវាយតំលៃជាន់ស្មានគួរតែត្រូវបានអនុវត្ត ។ វិធានការបន្ទាប់គួរតែអនុញ្ញាតឱ្យមានការអភិវឌ្ឍជលផលជាលំដាប់ ប្រសិនបើអាចធ្វើទៅបាន ។

៧.៥.៥ ប្រសិនបើព្រឹត្តិការណ៍ធម្មជាតិជះឥទ្ធិពលអាក្រក់ខ្លាំងទៅលើស្ថានភាពរស់នៅរបស់ធនធានវារិជាត បណ្តាប្រទេសគួរតែអនុម័តវិធានការអភិរក្សនិងគ្រប់គ្រងជាមូលដ្ឋានបន្ទាន់ ដើម្បីធានាថាសកម្មភាពធ្វើអាជីវកម្មនេសាទមិនធ្វើឱ្យកាន់តែធ្ងន់ឡើងដូចឥទ្ធិពលអាក្រក់ទាំងនោះ ។បណ្តាប្រទេសក៏គួរតែអនុម័តវិធានការមូលដ្ឋានបន្ទាន់នៅទីណាដែលវត្តមានសកម្មភាពនេសាទគំរាមកំហែងខ្លាំងដល់និរន្តរភាពធនធានជលផលទាំងនោះ ។ វិធានការដែលបានអនុវត្តលើមូលដ្ឋានបន្ទាន់មួយគួរតែមានលក្ខណៈបណ្តោះអាសន្នហើយត្រូវផ្អែកលើទិន្នន័យទឡ្ហីករណ៍វិទ្យាសាស្ត្រល្អបំផុតដែលមានស្រាប់អាចរកបាន ។

## ៧.៦ វិធានការគ្រប់គ្រង

៧.៦.១ បណ្តាប្រទេសគួរតែធានាថាកំរិតនៃការធ្វើអាជីវកម្មនេសាទដែលបានអនុញ្ញាតប្រហាក់ប្រហែលនឹងធនធានជលផលរបស់ប្រទេស ។

៧.៦.២ បណ្តាប្រទេសគួរតែទទួលយកវិធានការ ដើម្បីធានាថាគ្មាននាវានេសាទត្រូវបានអនុញ្ញាតឱ្យនេសាទទេលើកលែងតែមានការផ្ទេរសិទ្ធិក្នុងរបៀបថមួយស្របជាមួយនឹងច្បាប់អន្តរជាតិ ចំពោះសមុទ្រក្រៅ ឬ បញ្ជាក់បន្ថែមជាមួយច្បាប់ប្រទេសដែលស្ថិតនៅក្នុងតំបន់នៃយុត្តាធិការជាតិ ។

៧.៦.៣ នៅទីណាដែលកាប៉ាស៊ីតេធ្វើអាជីវកម្មនេសាទលើសហួសប្រមាណកើតឡើងយន្តការមួយគួរតែត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយការប្រើប្រាស់ឱ្យដល់កំរិតប្រហាក់ប្រហែលនឹងកាប៉ាស៊ីតេនិរន្តរភាពរបស់ធនធានជលផល ដូចជា ដើម្បីធានាថាអ្នកនេសាទប្រតិបត្តិក្រោមលក្ខខណ្ឌសេដ្ឋកិច្ចដែលលើកកំពើងភាពទទួលខុសត្រូវជលផល ។ បណ្តាយន្តការគួរតែរាប់បញ្ចូលទាំងការត្រួតពិនិត្យកាប៉ាស៊ីតេរបស់ហ្វូងនាវានេសាទ ។

៧.៦.៤ ការផលិតគ្រប់ឧបករណ៍នេសាទ វិធីសាស្ត្រ និង ការងារប្រតិបត្តិនានាគួរតែត្រូវបានត្រួតពិនិត្យហើយមានវិធានការ ដើម្បីធានាថាឧបករណ៍នេសាទ វិធីសាស្ត្រ និង ការប្រតិបត្តិដែលមិនស្របជាមួយនឹងការនេសាទដែលប្រកបដោយភាពទទួលខុសត្រូវបានកាត់បន្ថយបន្តិចម្តងៗ ហើយត្រូវបានជំនួសវិញដោយជំរើសឧបករណ៍ដែលអាចទទួលយកបាន ។

ដំណើរការនេះត្រូវយកចិត្តទុកដាក់ ជាពិសេសគួរតែត្រូវបានផ្តោតទៅលើឥទ្ធិពលនៃវិធានការទាំងឡាយស្តីពីសហគមន៍នេសាទរាប់បញ្ចូលទាំងលទ្ធភាពបំផ្លាញធនធានរបស់វាផង ។

៧.៦.៥ បណ្តាប្រទេស ស្ថាប័ន និង ការរៀបចំគ្រប់គ្រងផលផលគួរតែធ្វើឱ្យមានរបៀបរៀបរយ ការធ្វើអាជីវកម្មនេសាទក្នុងរបៀបមួយដែលជៀសវាងទំនាស់ដ៏មានគ្រោះថ្នាក់រវាងប្រជានេសាទដែលប្រើប្រាស់នាវានេសាទ ឧបករណ៍នេសាទ និង វិធីសាស្ត្រនេសាទផ្សេងគ្នា ។

៧.៦.៦ នៅពេលណាដែលសម្រេចចិត្តស្តីពីការប្រើប្រាស់ អភិរក្ស និង គ្រប់គ្រងធនធានជលផល ការកំណត់ពេលគួរតែផ្តល់ឱ្យសមស្របដោយផ្អែកលើច្បាប់ និងបទបញ្ជារបស់ប្រទេស ចំពោះការប្រតិបត្តិ ប្រពៃណី ទំនៀមទំលាប់ តម្រូវការ និង សារប្រយោជន៍របស់ប្រជាជនក្នុងស្រុក និង សហគមន៍នេសាទដែលពឹងផ្អែកទាំងស្រុងលើធនធានជលផលសម្រាប់ជីវភាពរស់នៅរបស់គាត់ ។

៧.៦.៧ ក្នុងពេលវាយតំលៃជ្រើសរើសវិធានការអភិរក្ស និង គ្រប់គ្រងតំលៃប្រសិទ្ធិភាព និង ឥទ្ធិពលសង្គមរបស់វាគួរតែត្រូវបានយកចិត្តទុកដាក់ ។

៧.៦.៨ ប្រសិទ្ធិភាពនៃវិធានការអភិរក្ស និង គ្រប់គ្រង ហើយអន្តរអំពើដែលអាចកើតមានគួរតែត្រូវបានទុកសិក្សាបន្តឱ្យបានត្រឹមត្រូវ ។ បណ្តាវិធានការគួរតែត្រូវបានកែសំរួល ឬ លប់ចោលពេលមានពត៌មានថ្មីសមស្រប ។

៧.៦.៩ បណ្តាប្រទេសគួរតែចាត់វិធានការសមស្របដើម្បីកាត់បន្ថយកាកសំណល់ការជ្រើសចោល ផលចាប់ដែលចាប់បានដោយខ្ទាចឧបករណ៍នេសាទ ឬ ឧបករណ៍នេសាទដែលបោះបង់ចោលផលចាប់មិនមែនមុខសញ្ញាទាំងពូជត្រី និងមិនមែនត្រីឥទ្ធិពលអវិជ្ជមានពីពូជជិតស្និទ្ធ ឬ ពឹងផ្អែក ជាពិសេស ពូជដែលកំពុងរងគ្រោះថ្នាក់ ។ នៅទីណាដែលអាចប្រព្រឹត្តទៅបានបណ្តាវិធានការអាចរាប់បញ្ចូលទាំងវិធានការបច្ចេកទេសពាក់ព័ន្ធដល់ទំហំត្រី ក្រឡាមង សំណាញ់ ឬ ឧបករណ៍ ការទាត់ចោល រដូវបិទនេសាទ និង សង្កាត់ និង តំបន់ដែលរក្សាសំរាប់ឧបករណ៍ ជំរើស ជាពិសេសចំពោះការនេសាទជាលក្ខណៈសិប្បកម្ម ។

បណ្តាវិធានការគួរតែត្រូវបានអនុវត្ត ដើម្បីការពារត្រីពេញវ័យ និង ត្រីមេពូជ ។ បណ្តាស្ថាប័ន និង ការរៀបចំគ្រប់គ្រងផលផលថ្នាក់អនុតំបន់ ឬ តំបន់ បើអាចធ្វើទៅបានគួរតែលើកទឹកចិត្ត បង្កើនវិសាលភាពអនុវត្តការអភិវឌ្ឍ និង ការប្រើប្រាស់របស់ជំរើស សុវត្ថិភាព បរិស្ថាន តំលៃ ប្រសិទ្ធិភាព ឧបករណ៍ និង បច្ចេកទេសនេសាទ ។

៧.៦.១០ បណ្តាស្ថាប័ន និង ការរៀបចំគ្រប់គ្រងផលផលអនុតំបន់ ឬ តំបន់ក្នុង ក្របខ័ណ្ឌនៃសមត្ថភាពរៀង១ខ្លួនគួរតែមានវិធានការណែនាំស្តារឡើងវិញនូវធនធានដែលបាន បំផ្លិចបំផ្លាញ និង ធនធានដែលកំពុងរងគ្រោះថ្នាក់ ដើម្បីរក្សានិរន្តរភាពសន្និធិទាំងនោះ ។ គេគួរតែធ្វើឱ្យអស់ពីលទ្ធភាពដើម្បីធានាថាធនធាន និងទីជំរកសំខាន់ចំពោះសុខុមាលភាពរបស់ ធនធានទាំងនោះដែលបានរងឥទ្ធិពលដោយការធ្វើអាជីវកម្ម ឬ សកម្មភាពមនុស្សផ្សេងទៀត ត្រូវបានកែលំអឡើងវិញ ។

## ៧.៧ ការអនុវត្ត

៧.៧.១ បណ្តាប្រទេសគួរតែធានាថាប្រសិទ្ធិភាពច្បាប់ និង គ្រោងការណ៍រដ្ឋបាល នៅតាមមូលដ្ឋាន និង ថ្នាក់ជាតិត្រូវបានស្ថាបនាឡើងសំរាប់ការអភិរក្ស និង ការគ្រប់គ្រងធន ធានផលផល ប្រសិនជាអាចធ្វើទៅបាន ។

៧.៧.២ បណ្តាប្រទេសគួរតែធានាថាច្បាប់ និងបទបញ្ញាផ្សេង១ដែលផ្តល់សច្ចាប័ន អាចអនុវត្តបាន ដោយគោរពទៅតាមកំរិតនៃការប្រព្រឹត្តល្មើសដែលមានប្រសិទ្ធិភាពខ្ពស់គិត ទាំងសច្ចាប័នដែលបានអនុញ្ញាតឱ្យធ្វើការបដិសេធ ដកចេញ ឬ ផ្អាកជាបណ្តោះអាសន្ន ចំពោះអាជ្ញាបណ្ណនេសាទណាដែលមិនព្រមធ្វើតាមវិធានការអភិរក្ស និង គ្រប់គ្រងដែលកំពុង មានសុពលភាព ។

៧.៧.៣ បណ្តាប្រទេសដោយមានការបញ្ជាក់ពីច្បាប់របស់ខ្លួនគួរតែអនុវត្តឱ្យមាន ប្រសិទ្ធិភាពក្នុងការគ្រប់គ្រង ត្រួតពិនិត្យ ឈ្លបមើល និង វិធានការនៃការបង្ខំឱ្យអនុវត្តច្បាប់ រួមមាន កម្មវិធីអង្កេត ផែនការធ្វើអធិការកិច្ច និង ប្រព័ន្ធត្រួតពិនិត្យនាវានេសាទ ។ បណ្តា វិធានការទាំងអស់គួរតែត្រូវបានជំរុញអនុវត្តដោយបណ្តាស្ថាប័ន និង ការរៀបចំគ្រប់គ្រងផល

ផលអនុតំបន់ ឬ តំបន់ដោយអនុលោមទៅតាមវិធានការដែលបានឯកភាពពីបណ្ដាស្ថាប័ន និង ការរៀបចំទាំងនោះ ។

៧.៧.៤ បណ្ដាស្ថាប័ន និង ការរៀបចំគ្រប់គ្រងផលផលអនុតំបន់ ឬ តំបន់គួរតែយល់ព្រមលើមធ្យោបាយដែលសកម្មភាពរបស់បណ្ដាស្ថាប័ន និងការរៀបចំនានា និងផ្ដល់ថវិកាចងចាំថាផលប្រយោជន៍និងសមត្ថភាពពាក់ព័ន្ធដែលផ្ដល់ដោយវិស័យផលផលខុសគ្នានៅក្នុងបណ្ដាប្រទេស ដើម្បីផ្ដល់ថវិកា និង វិភាគទានផ្សេងៗ ប្រសិនជាអាចធ្វើទៅបាន ។ នៅទីណាដែលអាចសមល្មម និង នៅពេលណាដែលអាចធ្វើទៅបានបណ្ដាស្ថាប័នហើយការរៀបចំនានាគួរតែធ្វើដើម្បីឱ្យបានមកវិញនូវតំលៃនៃការអភិរក្ស ការគ្រប់គ្រង និង ការស្រាវជ្រាវ ។

៧.៧.៥ បណ្ដាប្រទេសដែលជាសមាជិករបស់ឬអ្នកចូលរួមក្នុងស្ថាប័ននិងការរៀបចំគ្រប់គ្រងផលផលនានា នៅក្នុងអនុតំបន់ ឬ តំបន់គួរតែអនុវត្តវិធានការឯកភាពជាលក្ខណៈអន្តរជាតិដែលបានអនុម័តិក្នុងគ្រោងការណ៍របស់បណ្ដាស្ថាប័ន ឬការរៀបចំនានាហើយរលូនជាមួយច្បាប់អន្តរជាតិដើម្បីធ្វើការទប់ស្កាត់សកម្មភាពនាវានេសាទដែលដោតទង់ជាតិមិនមែនជាសមាជិកឬមិនបានចូលរួមដែលជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពដែលធ្វើឱ្យអន្តរាយដល់គម្លាភាពប្រសិទ្ធិភាពនៃវិធានការអភិរក្ស និងគ្រប់គ្រងដែលបានបង្កើតឡើងដោយស្ថាប័ននិងការរៀបចំនានា ។

៧.៨ ស្ថាប័នថវិកា

៧.៨.១ ដោយគ្មានការលំអៀង និងប្រកាន់ពូជសាសន៍ចំពោះទំនាក់ទំនងកិច្ចព្រមព្រៀងអន្តរជាតិនានាបណ្ដាប្រទេសគួរតែលើកទឹកចិត្តធនាគារស្ថាប័នហិរញ្ញវត្ថុដោយមិនចាំបាច់ដាក់លក្ខខណ្ឌចំពោះកម្ចី ឬ ការបញ្ចាំនាវានេសាទ ឬ នាវាគាំទ្រដែលមានដោតទង់ជាតិក្នុងយុត្តាធិការមួយជាជាងប្រទេសដែលជាម្ចាស់ទទួលផលប្រយោជន៍ជាសំណូមពរចាំបាច់មួយគួរតែមានឥទ្ធិពលលើការកើនឡើងនូវកិរិតជីវភាពនៃការមិនយល់ព្រមធ្វើតាមវិធានការអភិរក្ស និង គ្រប់គ្រង ។

## មាត្រា ៨ ការធ្វើអាជីវកម្មនេសាទ

### ៨.១ ករណីយកិច្ចរបស់បណ្ដាប្រទេស

៨.១.១ បណ្ដាប្រទេសគួរតែធានាថាមានតែការប្រតិបត្តិអាជីវកម្មនេសាទដែលបានអនុញ្ញាតប៉ុណ្ណោះដែលអាចធ្វើសកម្មភាពនៅក្នុងដែនទឹកយុត្តាធិការរបស់គេ ហើយការប្រតិបត្តិនេះប្រព្រឹត្តទៅក្នុងឥរិយាបថទទួលខុសត្រូវ ។

៨.១.២ បណ្ដាប្រទេសទាំងអស់គួរតែរក្សាទុកកំណត់ត្រាធ្វើឱ្យទាន់សម័យជាប្រចាំក្នុងចន្លោះពេលមួយលើអ្នកដែលបានផ្ដល់សិទ្ធិឱ្យធ្វើអាជីវកម្ម ។

៨.១.៣ បណ្ដាប្រទេសគួរតែថែទាំដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិ និង ការអនុវត្តទិន្នន័យ ស្ថិតិធ្វើឱ្យទាន់សម័យជាប្រចាំក្នុងចន្លោះពេលមួយលើគ្រប់ដំណើរការធ្វើអាជីវកម្មនេសាទដែលបានអនុញ្ញាត ។

៨.១.៤ បណ្ដាប្រទេសគួរតែអនុលោមទៅតាមច្បាប់អន្តរជាតិ និង គ្រោងការណ៍របស់ស្ថាប័ន និង ការរៀបចំគ្រប់គ្រងផលផលអនុតំបន់ឬតំបន់សហការគ្នា ដើម្បីបង្កើតប្រព័ន្ធសំរាប់ការគ្រប់គ្រង ត្រួតពិនិត្យ ឃ្លាំមើលនិងបង្ខំឱ្យអនុវត្តតាមវិធានការដែលអាចអនុវត្តបានដោយគោរពទៅតាមដំណើរការធ្វើអាជីវកម្មនេសាទ និង សកម្មភាពពាក់ព័ន្ធក្នុងទឹកដែលនៅក្រៅយុត្តាធិការរបស់ជាតិ ។

៨.១.៥ បណ្ដាប្រទេសគួរតែធានានូវបទដ្ឋានសុខភាព និង សុវត្ថិភាពដែលបានអនុម័តិសំរាប់អ្នកធ្វើការគ្រប់រូបក្នុងដំណើរការអាជីវកម្ម ។ បទដ្ឋានទាំងនោះមិនត្រូវទាបជាងសំណូមពរអប្បបរមារបស់លក្ខខណ្ឌការងារ និង សេវាកម្ម កិច្ចសន្យាអន្តរជាតិដែលពាក់ព័ន្ធ ។

៨.១.៦ បណ្ដាប្រទេសគួរតែរៀបចំរៀង១ខ្លួន ជាមួយគ្នាជាមួយបណ្ដាប្រទេស ឬ ជាមួយនឹងស្ថាប័នអន្តរជាតិសមស្រប ដើម្បីធ្វើសមាហរណកម្មទៅក្នុងការស្រាវជ្រាវដែលនៅជិតសមុទ្រ និង ប្រព័ន្ធសង្គ្រោះបន្ទាន់ ។

៨.១.៧ បណ្តាប្រទេសគួរតែលើកទឹកចិត្តតាមរយៈការអប់រំ និង កម្មវិធីបំពាក់បំប៉នចំណេះដឹង ទេពកោសល្យ និង បង្កើនគុណភាពវិជ្ជាជីវៈរបស់ប្រជានេសាទនៅទី ណាដែលអាចធ្វើទៅបាន ។ បណ្តាកម្មវិធីគួរតែត្រូវបានយកចិត្តទុកដាក់ឯកភាពទៅនឹងសេចក្តីណែនាំ និង បទដ្ឋានអន្តរជាតិ ។

៨.១.៨ បណ្តាប្រទេសគួរតែរក្សាកំណត់ត្រារបស់ប្រជានេសាទដែលផ្ទុកព័ត៌មានស្តីពីគុណភាព និង សេវាកម្មរបស់ពួកគេ នៅពេលណាដែលសមស្រប ហើយអាចធ្វើទៅបានរាប់បញ្ចូលទាំងវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដោយអនុលោមទៅតាមច្បាប់នានារបស់ប្រទេស ។

៨.១.៩ បណ្តាប្រទេសគួរតែធានាឱ្យអនុវត្តទៅបានដោយគោរពដល់អ្នកជំនាញ និង មន្ត្រីផ្សេងទៀតទទួលបន្ទុក ចំពោះអ្នកប្រព្រឹត្តខុសពាក់ព័ន្ធទៅនឹងដំណើរការរបស់នាវានេសាទគួរតែរាប់បញ្ចូលទាំងឧបករណ៍សំភារៈផ្សេងទៀតដែលអាចអនុញ្ញាត បដិសេធ ដកហូត ឬ បញ្ឈប់ជាបណ្តោះអាសន្ននូវសិទ្ធិបំរើដូចជា អ្នកជំនាញ ឬ មន្ត្រីរបស់នាវានេសាទ ។

៨.១.១០ បណ្តាប្រទេសដោយមានជំនួយពីស្ថាប័នអន្តរជាតិពាក់ព័ន្ធការប្រឹងប្រែងដើម្បីធានាតាមរយៈការអប់រំ និង ការបំពាក់បំប៉នដល់អ្នកទាំងឡាយណាជាប់ពាក់ព័ន្ធនៅក្នុងដំណើរការធ្វើអាជីវកម្មត្រូវតែផ្តល់ព័ត៌មានសំខាន់បំផុតរបស់ក្រមប្រតិបត្តិនេះ ព្រមជាមួយនិងកថាខណ្ឌពាក់ព័ន្ធនឹងអនុសញ្ញាអន្តរជាតិនានា និង បរិស្ថានដែលអាចអនុវត្តបាន និង បទដ្ឋានផ្សេងទៀតដែលជាមូលដ្ឋានធានាដល់ដំណើរការអាជីវកម្មនេសាទ ។

### ៨.២ ករណីយកិច្ចប្រទេសជាម្ចាស់ទង់ជាតិ

៨.២.១ បណ្តាប្រទេសជាម្ចាស់ទង់ជាតិគួរតែថែរក្សាកំណត់ត្រារបស់នាវានេសាទដែលមានសិទ្ធិដោតទង់ជាតិរបស់គេ ហើយការផ្ទេរសិទ្ធិឱ្យប្រើប្រាស់សំរាប់ធ្វើនេសាទគួរចង្អុលបង្ហាញកំណត់ហេតុលំអិតរបស់ម្ចាស់ និង ការផ្ទេរសិទ្ធិឱ្យធ្វើនេសាទនាវាទាំងនោះ ។

៨.២.២ ប្រទេសជាម្ចាស់ទង់ជាតិគួរតែធានាថា គ្មាននាវានេសាទណាមានសិទ្ធិដោតទង់ជាតិរបស់គេនេសាទនៅក្នុងសមុទ្រក្រៅ ឬ ក្នុងដែនទឹកដែលស្ថិតក្រោមយុត្តាធិការរបស់ប្រទេសផ្សេងទៀតលើកលែងតែនាវាទាំងនោះធ្លាប់បានអនុញ្ញាតដោយមានវិញ្ញាបនបត្រ

ចុះបញ្ជីហើយធ្លាប់បានផ្ទេរសិទ្ធិឱ្យធ្វើនេសាទដោយអាជ្ញាធរមានសមត្ថកិច្ច ។ បណ្តានាវានេសាទគួរតែយកភ្ជាប់ជាមួយនឹងនាវានូវវិញ្ញាបនបត្រចុះបញ្ជី និង ការផ្ទេរសិទ្ធិឱ្យធ្វើនេសាទ ។

៨.២.៣ នាវានេសាទដែលបានផ្ទេរសិទ្ធិឱ្យធ្វើនេសាទនៅក្នុងសមុទ្រក្រៅឬក្នុងដែនទឹកយុត្តាធិការរបស់ប្រទេសជាម្ចាស់ជាងទង់ជាតិដែលបង្ហូតលើនាវាគួរតែត្រូវបានអនុលោមទៅតាមឯកសណ្ឋាន និង ទទួលស្គាល់ពីប្រព័ន្ធនាវាអន្តរជាតិ ដូចជាបទដ្ឋានបច្ចេកទេស និង សេចក្តីណែនាំរបស់ FAO សំរាប់អនុវត្ត និង កត់សំគាល់នាវាអាជីវកម្ម ។

៨.២.៤ ឧបករណ៍នេសាទគួរតែត្រូវបានអនុវត្តដោយអនុលោមទៅតាមនិតិប្បញ្ញត្តិជាតិដើម្បីអាចធ្វើអត្តសញ្ញាណម្ចាស់របស់ឧបករណ៍ ។បទដ្ឋានផលិតឧបករណ៍នេសាទគួរតែយកចិត្តទុកដាក់ពីឯកសណ្ឋានហើយទទួលស្គាល់ពីប្រព័ន្ធផលិតឧបករណ៍អន្តរជាតិ ។

៨.២.៥ បណ្តាប្រទេសជាម្ចាស់ទង់ជាតិគួរតែធានាធ្វើតាមអនុសាសន៍សុវត្ថិភាពសមស្របសំរាប់នាវានេសាទ ហើយប្រជានេសាទអនុលោមទៅតាមអនុសញ្ញាអន្តរជាតិ ការអនុវត្តក្រមប្រតិបត្តិដែលបានឯកភាពដោយអន្តរជាតិ និង សេចក្តីណែនាំដោយស្ម័គ្រចិត្ត ។ បណ្តាប្រទេសគួរតែអនុម័តសំណូមពរសុវត្ថិភាពសមស្របសំរាប់នាវាតូចៗដែលមិនបានគ្របដណ្តប់ដោយអនុសញ្ញា ក្រមប្រតិបត្តិ ឬ សេចក្តីណែនាំស្ម័គ្រចិត្តផ្សេងៗ ។

៨.២.៦ បណ្តាប្រទេសដែលមិនមែនជាផ្នែកនៃកិច្ចព្រមព្រៀងក្នុងការជំរុញការអនុវត្តតាមវិធានការអភិរក្ស និង គ្រប់គ្រងអន្តរជាតិដោយនាវានេសាទនៅក្នុងសមុទ្រក្រៅគួរតែត្រូវបានលើកទឹកចិត្ត ដើម្បីឱ្យទទួលកិច្ចព្រមព្រៀង ហើយអនុម័តច្បាប់និងបទបញ្ជាផ្សេងៗឱ្យស្របជាមួយនឹងកថាខណ្ឌនានាដែលមានក្នុងកិច្ចព្រមព្រៀង ។

៨.២.៧ ប្រទេសជាម្ចាស់ទង់ជាតិគួរតែចាត់វិធានការបង្ខំឱ្យអនុវត្តតាមដោយគោរពដល់សិទ្ធិនាវានេសាទក្នុងការដោតទង់ជាតិរបស់គេដែលបានរកឃើញថាបានប្រព្រឹត្តិបទល្មើសលើវិធានការអភិរក្ស និង ការគ្រប់គ្រង រាប់បញ្ចូលទាំងការធ្វើខុសពីបណ្តាវិធានការបទល្មើសខុសឆ្គងនៅក្នុងបទបញ្ញត្តិជាតិ ។ សច្ចាប័នសំរាប់អនុវត្តបានដោយគោរពទៅលើការរំលោភបំពាននានាគួរតែមានប្រសិទ្ធិភាពគ្រប់គ្រាន់ក្នុងការត្រៀមអនុវត្ត និង បន្ថយការរំលោភបំពាន

នានានៅទីណាដែលមានកើតឡើង ហើយគួរតែដកហូតអ្នកដែលទទួលផលប្រយោជន៍ប្រមាថមើលងាយដល់សកម្មភាពល្មើសច្បាប់របស់ពួកគេ ។បណ្តាសន្ធាប័នអាចសំរាប់ការរំលោភបំពានខ្លាំងក្លានានា រួមមានការផ្តល់នានាសំរាប់ការបដិសេធ ដកហូត ឬ បញ្ឈប់បណ្តោះអាសន្ននៃការប្រគល់សិទ្ធិឱ្យធ្វើនេសាទ ។

៨.២.៨ ប្រទេសជាម្ចាស់ទង់ជាតិគួរតែជំរុញឱ្យម្ចាស់ និង អ្នកជួលនាវានេសាទចូលទៅបង់ការធានារ៉ាប់រង ។ ម្ចាស់ឬអ្នកជួលនាវានេសាទគួរតែមានការធានារ៉ាប់រងគ្រប់គ្រាន់ក្នុងការពារកម្មករនៅលើនាវានេសាទ និង ផលប្រយោជន៍របស់គេដើម្បីកំណត់ការបាត់បង់របស់អ្នកទីបី ឬ ដើម្បីការពារផលប្រយោជន៍របស់ពួកគេ ។

៨.២.៩ ប្រទេសម្ចាស់ទង់ជាតិគួរធានាថាសមាជិកទាំងអស់មានសិទ្ធិធ្វើមាតុភូមិនិវត្តន៍ ផ្អែកលើគោលការណ៍ដែលបានដាក់ចេញដោយសន្និសីទការធ្វើមាតុភូមិនិវត្តន៍របស់អ្នកដើរកប៉ាល់ (ដែលបានកែលំអ ១៩៨៧(N0. 166) ។

៨.២.១០ នៅក្នុងព្រឹត្តិការណ៍គ្រោះថ្នាក់ចៃដន្យដល់នាវានេសាទមួយ ឬនរណាម្នាក់ដែលនៅលើនាវានេសាទមួយប្រទេសដែលជាម្ចាស់ទង់ជាតិដោតលើនាវានេសាទពាក់ព័ន្ធគួរតែព័ត៌មានលំអិតនៃគ្រោះថ្នាក់នោះដល់ប្រទេសណាដែលជនជាតិបរទេសនៅលើនាវានេសាទចូលរួមក្នុងគ្រោះថ្នាក់នោះ ។ ព័ត៌មានទាំងអស់គួរតែទាក់ទងផងដែរចំពោះស្ថាប័ននាវានេសាទសមុទ្រអន្តរជាតិនៅទីណាដែលអាចធ្វើទៅបាន ។

**៨.៣ ករណីយកិច្ចរបស់ប្រទេសម្ចាស់កំពង់ផែ**

៨.៣.១ កំពង់ផែរបស់បណ្តាប្រទេសគួរតែមានវិធានការរៀបចំបង្កើតនៅក្នុងបទបញ្ញត្តិរបស់ប្រទេសខ្លួនដោយយោងទៅនឹងច្បាប់អន្តរជាតិរាប់បញ្ចូលទាំងកិច្ចព្រមព្រៀង ឬអន្តរជាតិដែលអាចអនុវត្តបាន ដើម្បីសម្រេចនូវបណ្តាវិធានការចាំបាច់ហើយដើម្បីជួយដល់បណ្តាប្រទេសឱ្យសម្រេចបានជោគជ័យនូវគោលបំណងរបស់ក្រមប្រតិបត្តិនេះហើយគួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវបទបញ្ជា និង វិធានការលំអិតដែលគេបានបង្កើតឡើងដល់ប្រទេសផ្សេងទៀតដើម្បីគោលបំណងនេះ ។នៅពេលចាត់វិធានការប្រទេសម្ចាស់កំពង់ផែមិនគួរប្រកាន់

វែកញែកក្នុងទំរង់ ឬ ការពិតប្រឆាំងនឹងនាវារបស់ប្រទេសទាំងនោះទេ ។

៨.៣.២ ប្រទេសម្ចាស់កំពង់ផែគួរតែផ្តល់ជំនួយដល់ប្រទេសម្ចាស់ទង់ជាតិឱ្យបានសមស្របដោយយោងទៅតាមច្បាប់ជាតិនៃប្រទេសម្ចាស់កំពង់ផែ និង ច្បាប់អន្តរជាតិនៅពេលណាដែលមាននាវានេសាទស្ម័គ្រចិត្តនៅក្នុងកំពង់ផែ ឬ នៅក្នុងព្រំដែនខាងក្រៅរបស់ម្ចាស់កំពង់ផែ ហើយប្រទេសជាម្ចាស់ទង់ជាតិរបស់នាវាស្នើសុំកំពង់ផែម្ចាស់ផ្ទះឱ្យជួយដោយមិនគោរពទៅតាមវិធានការអភិរក្ស និង គ្រប់គ្រងរបស់អនុតំបន់ តំបន់ ឬ ពិភពលោក ឬជាមួយនឹងបទដ្ឋានអប្បបរមាអន្តរជាតិសំរាប់ការពារ ការបំពុល និង សំរាប់សុវត្ថិភាព សុខុមាលភាព និងលក្ខខណ្ឌការងារនៅលើនាវានេសាទ ។

## ៨.៤ ដំណើរការអាជីវកម្មនេសាទ

៨.៤.១ បណ្តាប្រទេសគួរតែធានាថាការធ្វើអាជីវកម្មត្រូវបានអនុវត្តដោយគិតពីសុវត្ថិភាពជីវិតមនុស្ស និង ស្ថាប័នអាជីវកម្មសមុទ្រអន្តរជាតិ បទបញ្ជាអន្តរជាតិសំរាប់ការពារការប៉ះទង្គិចនៅក្នុងសមុទ្រព្រមជាមួយនឹងអនុសាសន៍របស់ស្ថាប័នអាជីវកម្មអន្តរជាតិពាក់ព័ន្ធទៅនឹងស្ថាប័នចរាចរក្នុងសមុទ្រ ការការពារបរិស្ថានសមុទ្រ និង ការពារការខូចខាត ឬការបាត់បង់ឧបករណ៍នេសាទ ។

៨.៤.២ បណ្តាប្រទេសគួរតែហាមឃាត់ការដាក់គ្រាប់រំសេវផ្ទុះ ការប្រើថ្នាំពុល និង ការប្រតិបត្តិអាជីវកម្មដែលធ្វើឱ្យខូចខាតប្រៀបធៀបទៅនឹងឧបករណ៍ផ្សេងទៀត ។

៨.៤.៣ បណ្តាប្រទេសគួរតែខិតខំដើម្បីធានាថាឯកសារការធ្វើអាជីវកម្មនេសាទការរក្សាទុកផលចាប់ពួជត្រី និង មិនមែនត្រីហើយចាត់ទុកដូចជាការជ្រើសចេញ ព័ត៌មានចាំបាច់សំរាប់ការប៉ាន់ស្មាន ដូចដែលបានសំរេចដោយគណៈគ្រប់គ្រងពាក់ព័ន្ធត្រូវបានជ្រើសរើសហើយបញ្ជូនតាមឋានានុក្រមជូនទៅគណៈគ្រប់គ្រងទាំងនោះ ។ បណ្តាប្រទេសគួរតែបង្កើតកម្មវិធីកាន់តែរហ័សកាន់តែល្អ ដូចជាគ្រោងការណ៍ស៊ើបអង្កេត និង ត្រួតពិនិត្យ ដើម្បីជំរុញឱ្យធ្វើតាមទៅនឹងវិធានការដែលអាចអនុវត្តបាន ។

៨.៤.៤ បណ្តាប្រទេសគួរតែជំរុញការអនុម័តិបច្ចេកទេសសមស្រប យកចិត្តទុកដាក់ទៅលើលក្ខខណ្ឌសេដ្ឋកិច្ចសំរាប់ការប្រើប្រាស់ឱ្យបានប្រសើរបំផុត ហើយយកចិត្តទុកដាក់នូវផលចាប់ដែលបានរក្សាទុក ។

៨.៤.៥ បណ្តាប្រទេសដែលពាក់ព័ន្ធជាមួយក្រុមនានាមកពីឧស្សាហកម្មគួរតែលើកទឹកចិត្តរៀបចំ អនុវត្តបច្ចេកវិទ្យា និងវិធីប្រតិបត្តិដែលកាត់បន្ថយផលទាត់ចោល ។ការប្រើប្រាស់ឧបករណ៍នេសាទ និង ប្រតិបត្តិដែលនាំឱ្យការទាត់ចោលផលចាប់គួរតែត្រូវបានជំរុញ ហើយការប្រើប្រាស់ឧបករណ៍នេសាទ និង ការអនុវត្តដែលបង្កើនអាត្រារស់នៅ និង ការគេចវេសរបស់ត្រីគួរតែត្រូវបានលើកតំកើង ។

៨.៤.៦ បណ្តាប្រទេសគួរតែសហការដើម្បីអភិវឌ្ឍ និង អនុវត្តបច្ចេកវិទ្យាវត្ថុធាតុដើម និង វិធីដំណើរការដែលកាត់បន្ថយការបាត់ឧបករណ៍នេសាទ និង ឥទ្ធិពលខ្មោចឧបករណ៍នេសាទ ឬ ឧបករណ៍នេសាទដែលបោះបង់ចោល ។

៨.៤.៧ បណ្តាប្រទេសគួរតែធានាការប៉ាន់ស្មាននូវទំនាក់ទំនងរបាយទីជំរកដែលបានអនុវត្ត មុននឹងធ្វើការផ្សព្វផ្សាយឧបករណ៍នេសាទជាលក្ខណៈឧស្សាហកម្ម វិធីសាស្ត្រ និង ការងារអនុវត្តក្នុងតំបន់ ។

៨.៤.៨ ការស្រាវជ្រាវស្តីពីឥទ្ធិពលរបស់ឧបករណ៍នេសាទលើបរិស្ថាន និង សង្គមជាពិសេសឥទ្ធិពលនៃឧបករណ៍លើជីវសាស្ត្រចំរុះ ហើយសហគមន៍នេសាទនៅតាមឆ្នេរគួរតែលើកតំកើង ។

## ៨.៥ ការជ្រើសរើសឧបករណ៍នេសាទ

៨.៥.១ បណ្តាប្រទេសគួរតែស្នើឧបករណ៍នេសាទ វិធីសាស្ត្រ និង ការអនុវត្តដើម្បីពង្រីកវិសាលភាពដែលអាចអនុវត្តបានត្រូវបានជ្រើសរើសដោយប្រសិទ្ធិភាព ដូចជាដើម្បីកាត់បន្ថយកាកសំណល់ ការជ្រើសចោលផលចាប់ដែលមិនមែនជាពូជមុខសញ្ញាទាំងត្រីនិងមិនមែនត្រីជះឥទ្ធិពលលើពូជជិតស្និទ្ធ ឬ ពូជពឹងផ្អែក ហើយចេតនានៃបទបញ្ញាពាក់ព័ន្ធមិនត្រូវបាន

ធៀបរវាងដោយបរិធានបច្ចេកទេស ។ ក្នុងន័យនេះ ប្រជានេសាទគួរតែសហការក្នុងការអភិវឌ្ឍការជ្រើសរើសឧបករណ៍នេសាទ និង វិធីសាស្ត្រ ។ បណ្ដាប្រទេសគួរតែធានាថាព័ត៌មានស្ដីពីការអភិវឌ្ឍថ្មី និង សំណូមពរចាំបាច់ត្រូវបានធ្វើឱ្យហើយស្រេចដល់គ្រប់ប្រជានេសាទ ។

៨.៥.២ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការជ្រើសរើស បណ្ដាប្រទេស នៅពេលដែលគូសវាសរៀបចំច្បាប់ និង បទបញ្ជានានាគួរតែយកចិត្តទុកដាក់ដល់តំណាតនៃការជ្រើសរើសឧបករណ៍នេសាទ វិធីសាស្ត្រ និង យុទ្ធសាស្ត្រដែលមានស្រាប់នៅក្នុងឧស្សាហកម្ម ។

៨.៥.៣ បណ្ដាប្រទេស និង ស្ថាប័នពាក់ព័ន្ធគួរតែសហការក្នុងការអភិវឌ្ឍបទដ្ឋានវិធីសាស្ត្រសំរាប់ស្រាវជ្រាវទៅក្នុងការជ្រើសរើសឧបករណ៍នេសាទ វិធីសាស្ត្រនេសាទ និង យុទ្ធសាស្ត្រនានា ។

៨.៥.៤ កិច្ចសហការអន្តរជាតិគួរតែត្រូវបានជំរុញលើកទឹកចិត្តដោយគោរពដល់កម្មវិធីស្រាវជ្រាវសំរាប់ការជ្រើសរើសឧបករណ៍នេសាទ យុទ្ធសាស្ត្រនេសាទ និង វិធីនេសាទ បែងចែកផ្សព្វផ្សាយលទ្ធផលរបស់កម្មវិធីស្រាវជ្រាវ និង ការផ្ទេរបច្ចេកវិទ្យានេសាទ ។

## ៨.៦ ថាមពលសុទិដ្ឋិនិយម

៨.៦.១ បណ្ដាប្រទេសគួរតែជំរុញការអភិវឌ្ឍឱ្យបានសមស្របទៅតាមបទដ្ឋាន និង សេចក្ដីណែនាំដែលអាចនាំដល់ប្រសិទ្ធិភាពនៃការប្រើប្រាស់ថាមពលក្នុងការប្រមូលផល និង សកម្មភាពបន្ទាប់ពីប្រមូលផលនៅក្នុងវិស័យជលផល ។

៨.៦.២ បណ្ដាប្រទេសគួរតែជំរុញការអភិវឌ្ឍ និង ផ្ទេរបច្ចេកវិទ្យាក្នុងទំនាក់ទំនងទៅនឹងថាមពលសុទិដ្ឋិនិយមវិស័យជលផល ហើយជាពិសេស ជំរុញឱ្យម្ចាស់ អ្នកជួល និង អ្នកគ្រប់គ្រងនាវានេសាទបំពាក់ថាមពល បរិធានដល់នាវានេសាទរបស់គេ ។

## ៨.៧ ការពារបរិស្ថានរបស់វារិជាត

៨.៧.១ បណ្ដាប្រទេសគួរតែណែនាំ និង បង្ខំឱ្យមានការអនុវត្តច្បាប់ និងបទបញ្ជាដោយផ្អែកលើអនុសញ្ញាអន្តរជាតិសំរាប់ការការពារការបំពុលពីនាវា ឆ្នាំ ១៩៧៣ ដូចដែលបានកែលំអដោយពិធីសារឆ្នាំ ១៩៧៨ ពាក់ព័ន្ធទៅនឹង(MARPOL 73/78) ។

៨.៧.២ ម្ចាស់ អ្នកជួល និង អ្នកគ្រប់គ្រងនាវាទេសចរណ៍ត្រូវធានាថានាវាទេសចរណ៍របស់គេបានបំពាក់ឧបករណ៍សំភារៈសមស្របដូចដែលបានស្នើដោយMARPOL73/78ហើយត្រូវតែយកចិត្តទុកដាក់ដល់ការបង្រួមនាវាឱ្យតូច ឬ ដុតរំលាយនាវាដែលពាក់ព័ន្ធដើម្បីគ្រប់គ្រងសំរាម និង កាកសំណល់ដែលបានបញ្ចេញចោលពេលនាវាធ្វើសេវាកម្មធម្មតា ។

៨.៧.៣ ម្ចាស់ អ្នកជួល និងអ្នកគ្រប់គ្រងនាវាទេសចរណ៍ត្រូវតែកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវវិសាលភាពសំរាមនៅលើនាវាតាមរយៈការអនុវត្តសមស្របនានា ។

៨.៧.៤ នាវិកនៅលើនាវាទេសចរណ៍ដែលធ្លាប់ដឹងពីវិធានការនៅលើទូកត្រូវធានាការចាក់ចោលមិនលើសពីកំរិតដែលបានកំណត់ដោយ MARPOL 73/78 ។ បណ្តាវិធានការត្រូវតែកាត់បន្ថយឱ្យដល់កំរិតអប្បបរមា រួមបញ្ចូលទាំងការយកកាកសំណល់ប្រេងទៅចោល ការថែរក្សា និង ការធ្វើសន្និធិសំរាមរបស់ទូកទេសចរណ៍ ។

៨.៨ ការការពារបរិយាកាស

៨.៨.១ បណ្តាប្រទេសត្រូវតែអនុម័តិបទដ្ឋានពាក់ព័ន្ធ និង សេចក្តីណែនាំនានាដែលត្រូវតែរាប់បញ្ចូលកថាខណ្ឌផ្សេងៗ ដើម្បីកាត់បន្ថយការបញ្ចេញចោលសមាសធាតុឧស្ម័នគ្រោះថ្នាក់ ។

៨.៨.២ ម្ចាស់ អ្នកជួល និង អ្នកគ្រប់គ្រងនាវាទេសចរណ៍ត្រូវតែធានាថានាវាទេសចរណ៍របស់គាត់ត្រូវបានបំពាក់ដោយឧបករណ៍សំភារៈ ដើម្បីកាត់បន្ថយការបំផ្លាញសមាសធាតុអូហ្សូន។ ការទទួលខុសត្រូវរបស់សមាជិកនាវិកនៃនាវាទេសចរណ៍ត្រូវតែមានភាពជិតស្និទ្ធិជាមួយនឹងដំណើរការ និង ថែរក្សាគ្រឿងយន្តនៅលើនាវា ។

៨.៨.៣ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែកាត់បន្ថយបន្តិចម្តងៗនូវការប្រើប្រាស់ក្លរូហ្វ័យអរការបូន(CFCs) និង អង្គធាតុសកម្មដូចជា អ៊ីដ្រូក្លរូហ្វ័យអរកាបូន(HCFCs)នៅក្នុងប្រព័ន្ធបរិក្ខារត្រជាក់របស់នាវាទេសចរណ៍ ហើយត្រូវតែធានាថាឧស្សាហកម្មសាងសង់នាវា និង អ្នកដែលជាប់ពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍ដែលបានរៀបចំ និង អនុវត្តទៅតាមកថាខណ្ឌនានារបស់ក្រុម ។

៨.៨.៤ ម្ចាស់ ឬ អ្នកគ្រប់គ្រងនាវានេសាទគួរតែមានសកម្មភាពសមស្របដើម្បីធ្វើឱ្យសមល្មមឡើងវិញនូវនាវានេសាទដែលមានស្រាប់ជាមួយនឹងការជ្រើសរើសអង្គធាតុរាវសកម្ម CGCs និង HCFCs ហើយជ្រើសរើស Halons បំពាក់ក្នុងការពន្លត់អគ្គីភ័យ ។ការជ្រើសរើសទាំងនោះគួរតែត្រូវបានប្រើប្រាស់នៅក្នុងបទដ្ឋានបច្ចេកទេសសំរាប់នាវានេសាទថ្មី១ ។

៨.៨.៥ បណ្តាប្រទេស ម្ចាស់ អ្នកជួល និង អ្នកគ្រប់គ្រងនាវានេសាទព្រមទាំងប្រជានេសាទគួរតែអនុវត្តតាម សេចក្តីណែនាំអន្តរជាតិក្នុងការយកសារធាតុ CGCs HCFCs និង Halons ទៅចោលឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ។

**៨.៩ ទីសំចត និង កន្លែងឡើងចំនិញសំរាប់នាវានេសាទ**

៨.៩.១ បណ្តាប្រទេសគួរតែយកចិត្តទុកដាក់ដូចខាងក្រោមក្នុងការរៀបចំ និងកសាងទីសំចត និង កន្លែងឡើងចំនិញៈ

ក) កំពង់ផែសំរាប់នាវានេសាទត្រូវមានសុវត្ថិភាព ហើយមានសេវាកម្ម ឧបករណ៍គ្រប់គ្រាន់សំរាប់នាវានេសាទ អ្នកលក់ និង អ្នកទិញ ។

ខ) ការផ្គត់ផ្គង់ទឹកសាបត្រូវតែមានគ្រប់គ្រាន់ ហើយការរៀបចំអនាម័យគួរតែបានផ្តល់ឱ្យ ។

គ) ប្រព័ន្ធប្រមូលសំរាមយកទៅចាក់ចោលគួរតែត្រូវបានណែនាំ រួមទាំងដើម្បីយកប្រេង ទឹកមានប្រេង និង ឧបករណ៍នេសាទទៅចោល ។

ឃ) ការបំពុលពីសកម្មភាពនេសាទ និង ធនធានពីខាងក្រៅគួរតែត្រូវបានកាត់បន្ថយឱ្យដល់កំរិតអប្បបរមា ។

ង) ការរៀបចំនានាគួរតែត្រូវបានធ្វើឡើងទប់ទល់នឹងឥទ្ធិពលនៃការហូរច្រោះ និងល្បាប់ ។

៨.៩.២ បណ្តាប្រទេសគួរតែកសាងនូវគ្រោងការណ៍ស្ថាប័នសំរាប់ជ្រើសរើស ឬធ្វើឱ្យប្រសើរឡើងនូវទីកន្លែងសំចតសំរាប់នាវានេសាទដែលអនុញ្ញាតឱ្យការប្រឹក្សាយោបល់ក្នុងចំណោមអាជ្ញាធរទទួលខុសត្រូវសំរាប់ការគ្រប់គ្រងតំបន់ឆ្នេរ ។

## ៨.១០ ការបោះបង់ចោលនៃរចនាសម្ព័ន្ធ និង វត្ថុធាតុដើមផ្សេងទៀត

៨.១០.១ បណ្តាប្រទេសគួរតែធានានូវបទដ្ឋាន និង សេចក្តីណែនាំនានាសំរាប់ដកហូតនូវរចនាសម្ព័ន្ធសមុទ្រក្រៅដែលលើសចេញដោយស្ថាប័នអាជីវកម្មសមុទ្រអន្តរជាតិ ។បណ្តាប្រទេសក៏គួរតែធានាថាសមត្ថភាពអាជ្ញាធរដែលផលត្រូវបានប្រឹក្សាមុននឹងធ្វើសេចក្តីសំរេចចិត្តស្តីពីរចនាសម្ព័ន្ធលើស និង វត្ថុធាតុដើមផ្សេងៗដោយអាជ្ញាធរពាក់ព័ន្ធ ។

## ៨.១១ ទីជំរកផ្កាថ្មសិប្បនិមិត្ត និង បរិធានធ្វើឱ្យត្រីកុំ

៨.១១.១ បណ្តាប្រទេស នៅទីណាដែលសមស្របគួរតែអភិវឌ្ឍគោលនយោបាយដើម្បីបង្កើនសន្និធិប្រជាពល ហើយជំរុញឱកាសធ្វើនេសាទតាមរយៈការប្រើប្រាស់រចនាសម្ព័ន្ធសិប្បនិមិត្តដាក់ដោយមានការគោរពទៅលើសុវត្ថិភាព នាវាចរណ៍លើ ឬ ខាងលើផ្ទៃបាត ឬ នៅលើបាតសមុទ្រ ឬ ទន្លេ ។ ការស្រាវជ្រាវនូវការប្រើប្រាស់នៃរចនាសម្ព័ន្ធទាំងនោះ រួមមានផលប៉ះពាល់លើធនធានសមុទ្រដែលមានជីវិត និង បរិស្ថានគួរតែត្រូវបានលើកទឹកចិត្ត ។

៨.១១.២ បណ្តាប្រទេសគួរតែយកចិត្តទុកដាក់នៅពេលណាដែលជ្រើសរើសវត្ថុធាតុដើម្បីប្រើប្រាស់ក្នុងការរៀបចំទីជំរកផ្កាថ្មសិប្បនិមិត្ត ព្រមទាំងនៅពេលដែលជ្រើសរើសស្ថានភាពទីតាំងរបស់ទីជំរកផ្កាថ្មសិប្បនិមិត្តទាំងនោះ គ្រប់កថាខណ្ឌទាំងអស់ដែលទាក់ទងនឹងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងបរិស្ថាន និង សុវត្ថិភាពរបស់នាវាចរណ៍ត្រូវតែបានអង្កេត ។

៨.១១.៣ បណ្តាប្រទេសគួរតែជាមួយនឹងគ្រោងការណ៍ ផែនការគ្រប់គ្រងតំបន់ឆ្នេរការរៀបចំប្រព័ន្ធគ្រប់គ្រងសំរាប់ទីជំរកផ្កាថ្មសិប្បនិមិត្ត និងបរិធានធ្វើឱ្យត្រីកុំ ។ប្រព័ន្ធគ្រប់គ្រងទាំងអស់គួរតែស្នើសុំសេចក្តីយល់ព្រម ដើម្បីការកសាង ការអភិវឌ្ឍនៃផ្កាថ្ម និង បរិធាន ហើយគួរតែយកចិត្តទុកដាក់ដល់ផលប្រយោជន៍របស់ប្រជានេសាទ រាប់បញ្ចូលទាំងការនេសាទជាលក្ខណៈសិប្បកម្ម និង គ្រាន់តែចិញ្ចឹមជីវិត ។

៨.១១.៤ បណ្តាប្រទេសគួរតែធានាថាអាជ្ញាធរទទួលខុសត្រូវសំរាប់ជូនដំណឹងកត់ត្រាផែនទី និង ក្រាហ្វិច ដើម្បីគោលបំណងនៃការធ្វើនាវាចរណ៍ ព្រមទាំងអាជ្ញាធរពាក់ព័ន្ធបរិស្ថានត្រូវបានជូនដំណឹងមុននឹងដាក់ ឬ ដកទីជំរកផ្កាថ្មសិប្បនិមិត្ត ឬ បរិធានធ្វើឱ្យត្រីកុំ ។

## មាត្រា ៩ ការអភិវឌ្ឍវារីវប្បកម្ម

៩.១ ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវ រួមមានការចិញ្ចឹមផ្អែកលើផលផលគ្រប់ប្រភេទនៅក្នុងតំបន់ដែលស្ថិតក្រោមយុត្តាធិការជាតិ

៩.១.១ បណ្តាប្រទេសគួរតែបង្កើតនិងអភិវឌ្ឍមូលដ្ឋានច្បាប់សមស្របនិងក្របខណ្ឌការងាររដ្ឋបាលដែលសំរបសំរួលវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវ ។

៩.១.២ បណ្តាប្រទេសគួរតែជំរុញការទទួលខុសត្រូវលើការអភិវឌ្ឍ និង គ្រប់គ្រងវារីវប្បកម្មរួមមានការវាយតំលៃស៊ីជំរៅពីផលប៉ះពាល់នៃការអភិវឌ្ឍវារីវប្បកម្មស្តីពីភាពផ្សេងគ្នានៃសេនេទិច និងបូរណភាពប្រពន្ធ័អេកូឡូស៊ីដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រល្អបំផុតដែលមានស្រាប់ ។

៩.១.៣ បណ្តាប្រទេសគួរតែផលិត និង ធ្វើឱ្យប្រសើរឡើងជាប្រចាំនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍវារីវប្បកម្មទៅតាមតំរូវការ ដើម្បីធានាថាការអភិវឌ្ឍវារីវប្បកម្មគឺធ្វើឱ្យមាននិរន្តភាពអេកូឡូស៊ី ហើយអនុញ្ញាតឱ្យចែករំលែកការប្រើប្រាស់ធនធានធម្មជាតិដោយការធ្វើវារីវប្បកម្ម និង សកម្មភាពផ្សេងៗទៀត ។

៩.១.៤ បណ្តាប្រទេសគួរតែធានាអះអាងថាជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាននិងការចូលទៅធ្វើនេសាទនៅតាមបរិវេណអាជីវកម្មមិនរងផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍវារីវប្បកម្ម ។

៩.១.៥ បណ្តាប្រទេសគួរតែបង្កើតវិធានការប្រសិទ្ធិភាពជាក់ស្តែងចំពោះវារីវប្បកម្មដើម្បីទទួលរ៉ាប់រងចាំន់ស្មានបរិស្ថានសមស្រប ហើយត្រួតពិនិត្យជាមួយគោលបំណងកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវការផ្លាស់ប្តូរអេកូឡូស៊ី និងវិបាកសង្គមជាលទ្ធផលដែលបណ្តាលមកពីការដកហូតទឹក ការប្រើប្រាស់ដី ការបញ្ចេញចោល ការប្រើប្រាស់ថ្នាំ និង សារធាតុគីមី និង សកម្មភាពផ្សេងទៀត ។

៩.២ ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវរួមមានការចិញ្ចឹមផ្អែកលើ

ផលផលជាមួយនឹងវារិជាតឆ្លងកាត់ព្រំប្រទល់ប្រព័ន្ធអេកូឡូស៊ី

៩.២.១ បណ្តាប្រទេសគួរតែការពារឱ្យបាននូវវារិជាតដែលឆ្លងកាត់ព្រំប្រទល់អេកូឡូស៊ីដោយមានការជួយគាំទ្រប្រកបដោយភាពទទួលខុសត្រូវក្នុងវារីវប្បកម្មជាមួយនឹងយុត្តាធិការជាតិ ហើយដោយសហការក្នុងការជំរុញការប្រតិបត្តិវារីវប្បកម្មប្រកបដោយនិរន្តរភាព ។

៩.២.២ បណ្តាប្រទេសគួរតែគោរពបណ្តាប្រទេសជិតខាង និង ដោយផ្អែកលើច្បាប់អន្តរជាតិ ធានាអះអាងប្រកបដោយភាពទទួលខុសត្រូវក្នុងការជ្រើសរើសពូជ រៀបចំផែនការគ្រប់គ្រងសកម្មភាពវារីវប្បកម្មដែលមិនជះឥទ្ធិពលដល់វារិជាតដែលឆ្លងកាត់ព្រំប្រទល់ប្រព័ន្ធអេកូឡូស៊ី ។

៩.២.៣ បណ្តាប្រទេសគួរតែធ្វើការពិភាក្សាជាមួយប្រទេសជិតខាងឱ្យបានសមស្របមុននឹងជ្រើសរើសប្រភេទត្រីដែលមិនមែនជាប្រភេទត្រីដែលកំពុងរងគ្រោះថ្នាក់សែងទៅក្នុងព្រំប្រទល់ប្រព័ន្ធអេកូឡូស៊ីវារិជាតិ ។

៩.២.៤ បណ្តាប្រទេសគួរតែរៀបចំយន្តការសមស្រប ដូចជាប្រពន្ធ័ទិន្នន័យមូលដ្ឋាន និង ប្រមូលបណ្តាញព័ត៌មាន ចែករំលែកព័ត៌មាន និង ផ្សព្វផ្សាយទិន្នន័យដែលទាក់ទងនឹងសកម្មភាពវារីវប្បកម្មរបស់ពួកគេ ដើម្បីសហការសំរបសំរួលស្តីពីការធ្វើផែនការសំរាប់អភិវឌ្ឍវារីវប្បកម្មនៅថ្នាក់ជាតិ អនុតំបន់ តំបន់ និង ពិភពលោក ។

៩.២.៥ បណ្តាប្រទេសគួរតែសហការគ្នា ក្នុងការបង្កើតយន្តការអភិវឌ្ឍសមស្របមួយ ពេលចាំបាច់ដើម្បីត្រួតពិនិត្យនូវផលប៉ះពាល់ដែលបណ្តាលមកពីវត្ថុធាតុដើមដែលបំរើឱ្យវារីវប្បកម្ម ។

## ៩.៣ ការប្រើប្រាស់ធនធានស៊ីនេទិចដើម្បីគោលបំណងវារីវប្បកម្មរាប់បញ្ចូលទាំងវារីវប្បកម្មផ្អែកលើផលផល

៩.៣.១ បណ្តាប្រទេសគួរតែអភិរក្សសេនេទិចចំរុះ សំខាន់គឺបូរណភាពដែនទឹករបស់សហគមន៍វារីសត្វ និង ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីសមស្រប ។ ជាពិសេស ការខិតខំត្រូវបាន

យកចិត្តទុកដាក់ ដើម្បីកាត់បន្ថយផលប៉ះពាល់ខ្លាំងដែលបណ្តាលមកពីការបញ្ចូលពូជត្រីដែលមិនមែនជាពូជក្នុងស្រុក ឬ សន្និធិដែលបានផ្លាស់ប្តូរសេនេទិចត្រូវបានប្រើប្រាស់សំរាប់វារីវប្បកម្ម រាប់បញ្ចូលទាំងវារីវប្បកម្មផ្អែកលើផលផលនៅក្នុងទឹក ជាពិសេសនៅទីណាដែលមានសក្តានុពលសំខាន់ដើម្បីពង្រីកនូវពូជក្រៅស្រុក ឬ សន្និធិដែលបានកែប្រែសេនេទិចទៅក្នុងទឹកដែលស្ថិតនៅក្រោមយុត្តាធិការរបស់បណ្តាប្រទេស ព្រមទាំងដែនទឹកនៃបណ្តាប្រទេសដើម ។ ប្រសិនជាធ្វើទៅបានបណ្តាប្រទេសគួរតែលើកទឹកចិត្តជាជំហានៗ ដើម្បីកាត់បន្ថយសេនេទិចផ្ទុយ ជំងឺ និង ឥទ្ធិពលនៃការគេចវេសរបស់ត្រីដែលចិញ្ចឹមចូលទៅក្នុងសន្និធិធម្មជាតិ ។

៩.៣.២ បណ្តាប្រទេសគួរតែសហការពិភាក្សាគ្នាយ៉ាងល្អិតល្អន់ ឯកភាព និង ដាក់ឱ្យដំណើរការនូវការប្រតិបត្តិវិធានការអន្តរជាតិ និង ការអនុវត្តការនាំចូល និង ផ្លាស់ប្តូរការដឹកជញ្ជូនសារពាង្គកាយវារីសត្វ ។

៩.៣.៣ បណ្តាប្រទេសគួរតែលើកទឹកចិត្តអនុម័តិអនុវត្តសមស្របទៅក្នុងការជំរុញធ្វើឱ្យប្រសើរឡើងនូវមេពូជ កាត់បន្ថយការឆ្លងជំងឺ និង ការចំលងដែលជះឥទ្ធិពលដល់សន្និធិធម្មជាតិ និង វារីវប្បកម្ម ។ សេចក្តីណែនាំនៃពូជក្រៅស្រុក ការផលិត លក់ ដឹកជញ្ជូនពងកូនញាស់ កូនត្រី មេពូជ ឬ វត្ថុធាតុដើមរស់ផ្សេងៗទៀត ។ បណ្តាប្រទេសគួរតែបង្កលក្ខណៈងាយស្រួលដល់ការរៀបចំ និង អនុវត្តន៍ច្បាប់ ការអនុវត្តក្រមប្រតិបត្តិអន្តរជាតិសមស្របទៅនឹងវិធានការ និង ការប្រតិបត្តិទៅលើកត្តាជះឥទ្ធិពលនេះ ។

៩.៣.៤ បណ្តាប្រទេសគួរតែយកចិត្តទុកដាក់មាននីតិវិធីការជំរុញការជ្រើសរើសត្រីមេពូជ និង ការផលិតពង កូនញាស់ និង កូនត្រីឱ្យបានសមស្រប ។

៩.៣.៥ បណ្តាប្រទេសគួរតែជំរុញការងារស្រាវជ្រាវឱ្យបានសមស្របហើយនៅពេលណាដែលអាចធ្វើទៅបានត្រូវអភិវឌ្ឍបច្ចេកទេសចិញ្ចឹមប្រភេទត្រីដែលជិតដាច់ពូជ ដើម្បីការពារ ស្តារឡើងវិញហើយបង្កើនសន្និធិធម្មជាតិរបស់វា ដោយយកចិត្តទុកដាក់លើតំរូវការចាំបាច់ដែលសំខាន់ដើម្បីឈានទៅអភិរក្សសេនេទិចចំរុះនៃប្រភេទពូជដែលបានរងគ្រោះថ្នាក់ ។

៥.៤ វារីវប្បកម្មដែលប្រកបដោយភាពខុសត្រូវនៅកំរិតផលិតកម្ម

៥.៤.១ បណ្តាប្រទេសគួរតែជំរុញការអនុវត្តវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវ ដើម្បីជួយគាំទ្រដល់សហគមន៍ជនបទ ស្ថាប័នផលិត និង វារីវប្បករ ។

៥.៤.២ បណ្តាប្រទេសគួរតែលើកទឹកចិត្តដល់សកម្មភាពចូលរួមរបស់វារីវប្បករ និងសហគមន៍របស់គេក្នុងការអភិវឌ្ឍប្រកបដោយភាពទទួលខុសត្រូវនូវការអនុវត្ត គ្រប់គ្រងវារីវប្បកម្ម ។

៥.៤.៣ បណ្តាប្រទេសគួរតែលើកទឹកចិត្តដល់ការខិតខំដែលធ្វើឱ្យប្រសើរឡើងនូវការជ្រើសរើស និង ការប្រើប្រាស់ចំណីសមស្រប ចំណីបន្ថែម និង ជីរាប់បញ្ចូលទាំងជីលាមកសត្វផង ។

៥.៤.៤ បណ្តាប្រទេសគួរតែលើកទឹកចិត្តដល់ការអនុវត្តគ្រប់គ្រងកសិដ្ឋាន និង ការគ្រប់គ្រងសុខភាពត្រីដោយវិធានអនាម័យ និង ការប្រើវ៉ាក់សាំងប្រកបដោយប្រសិទ្ធិភាព ។

សុវត្ថិភាពប្រសិទ្ធិភាព និង វិធីព្យាបាលជំងឺ ការប្រើប្រាស់អ័រម៉ូន និង ថ្នាំអង់ទីប៊ីយូទិច និងសារធាតុគីមីផ្សេងទៀតសំរាប់ទប់ស្កាត់ជំងឺគួរតែត្រូវបានធានា ។

៥.៤.៥ បណ្តាប្រទេសគួរតែដាក់កំរិតការប្រើប្រាស់សារធាតុគីមីក្នុងវារីវប្បកម្មដែលជះឥទ្ធិពលគ្រោះថ្នាក់ដល់សុខុមាលភាពមនុស្ស និង បរិស្ថាន។

៥.៤.៦ បណ្តាប្រទេសគួរតែដាក់ស្នើនូវការបញ្ចេញចោលកាកសំណល់ផ្សេងៗដូចជាទឹកសំអុយ កាកសំណល់សាច់ ត្រីងាប់ ត្រីមានជំងឺ សំណល់ថ្នាំព្យាបាលសត្វ និង កាកសំណល់គីមីដែលមានគ្រោះថ្នាក់ផ្សេងទៀតដែលប្រើប្រាស់ក្នុងវារីវប្បកម្មមិនបន្តធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស និង បរិស្ថាន ។

៥.៤.៧ បណ្តាប្រទេសគួរតែធានាឱ្យបាននូវសុវត្ថិភាពស្បៀងអាហារដែលមានប្រភព

មកពីវារីវប្បកម្ម ហើយជំរុញរក្សាគុណភាពផលិតផល និង ធ្វើឱ្យប្រសើរឡើងនូវគុណតំលៃរបស់វាតាមរយៈ ជាពិសេសការយកចិត្តទុកដាក់មុន និង ពេលប្រមូលផល និង ការកែច្នៃថែរក្សានៅនឹងកន្លែងប្រមូលផល និង ដឹកជញ្ជូនផលិតផលនោះ ។

## មាត្រា ១០ ការធ្វើសមាហរណកម្មវិស័យជលផលទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ

### ១០.១ ក្របខណ្ឌស្ថាប័ន

១០.១.១ បណ្តាប្រទេសគួរតែធានាអះអាងថាគោលនយោបាយច្បាប់ ក្របខណ្ឌស្ថាប័នសមស្របមួយត្រូវបានឯកភាពដើម្បីឆ្ពោះទៅរកនិរន្តរភាព និង ធ្វើសមាហរណកម្មការប្រើប្រាស់ធនធានធម្មជាតិ យកចិត្តទុកដាក់ដល់ការងាយស្រួយរបស់ប្រពន្ធ័អេកូឡូស៊ីសមុទ្រ និង ការកំណត់របស់ធនធានធម្មជាតិ និង តំរូវការរបស់សហគមន៍តំបន់ឆ្នេរ ។

១០.១.២ ដោយគិតពីការប្រើប្រាស់រួមគ្នានៅក្នុងតំបន់ឆ្នេរ បណ្តាប្រទេសគួរតែធានាអះអាងថាអ្នកតំណាងរបស់វិស័យជលផល និង សហគមន៍នេសាទគួរតែត្រូវបានប្រឹក្សាយោបល់នៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តហើយបញ្ចូលទៅក្នុងសកម្មភាពផ្សេងទៀតដែលទាក់ទងនឹងការធ្វើផែនការគ្រប់គ្រង និង អភិវឌ្ឍន៍តំបន់ឆ្នេរ ។

១០.១.៣ បណ្តាប្រទេសគួរតែអភិវឌ្ឍក្របខណ្ឌច្បាប់ និង ស្ថាប័នឱ្យបានសមស្របដើម្បីឈានទៅកំនត់លទ្ធភាពការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ឆ្នេរ ហើយផ្តល់សិទ្ធិឱ្យសហគមន៍នេសាទនៅតំបន់ឆ្នេរ និង ការប្រតិបត្តិដែលជាលក្ខណៈប្រពៃណីដើម្បីលាតសនឹងការសំរុះសំរួលជាមួយនឹងការអភិវឌ្ឍប្រកបដោយនិរន្តភាព ។

១០.១.៤ បណ្តាប្រទេសគួរតែជួយសំរបសំរួលការអនុម័តិការប្រតិបត្តិនេសាទដើម្បីជៀសវាងទំនាស់ក្នុងចំណោមអ្នកប្រើប្រាស់ធនធានជលផល និង អ្នកប្រើប្រាស់តំបន់ឆ្នេរផ្សេងទៀត ។

១០.១.៥ បណ្ដាប្រទេសគួរតែលើកទឹកចិត្តបង្កើតវិធានការ និង រៀបចំយន្តការនៅក្នុងក្របខ័ណ្ឌរដ្ឋបាលសមស្របមួយ ដើម្បីផ្សះផ្សារជម្លោះដែលកើតមាននៅក្នុងវិស័យជលផល និង រវាងអ្នកប្រើប្រាស់ធនធានជលផល និង អ្នកប្រើប្រាស់ក្នុងតំបន់ឆ្នេរផ្សេងទៀត ។

១០.២ វិធានគោលនយោបាយ

១០.២.១ បណ្ដាប្រទេសគួរតែជំរុញលើកទឹកចិត្តបង្កើនការយកចិត្តទុកដាក់ពីសំណាក់សាធារណជននូវតំរូវការ ដើម្បីការពារ និង គ្រប់គ្រងធនធានតំបន់ឆ្នេរ ហើយចូលរួមនៅក្នុងដំណើរការគ្រប់គ្រងដោយអ្នកដែលរងផលប៉ះពាល់ ។

១០.២.២ ដើម្បីជួយដល់ការធ្វើសេចក្ដីសំរេចចិត្តស្ដីពីការបែងចែក និង ការប្រើប្រាស់ធនធានក្នុងតំបន់ឆ្នេរ បណ្ដាប្រទេសគួរតែជំរុញលើកទឹកចិត្តឱ្យមានការស្រាវជ្រាវថ្លឹងប្រមាណនូវតំលៃធនធានដែលមាននៅក្នុងតំបន់ឆ្នេរគិតទាំងកត្តាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។

១០.២.៣ ក្នុងការកំនត់គោលនយោបាយសំរាប់ការគ្រប់គ្រងតំបន់ឆ្នេរបណ្ដាប្រទេសគួរតែទទួលស្គាល់នូវការប្រឈមមុខនានា និង ភាពចៃដន្យដែលអាចកើតមាន ។

១០.២.៤ បណ្ដាប្រទេស អនុលោមទៅតាមសមត្ថភាព និង លទ្ធភាពគួរតែបង្កើត ឬ ជំរុញលើកទឹកចិត្តបង្កើតប្រពន្ធ័ត្រួតពិនិត្យបរិស្ថានតំបន់ឆ្នេរដែលជាផ្នែកមួយនៃដំណើរការគ្រប់គ្រងប៉ារ៉ាម៉ែត្រ លក្ខណៈរូប គីមី ជីវសាស្ត្រ សេដ្ឋកិច្ច និង សង្គម ។

១០.២.៥ បណ្ដាប្រទេសគួរតែជំរុញលើកទឹកចិត្តការស្រាវជ្រាវគ្រប់ប្រភេទ ដើម្បីជំរុញការគាំទ្រការគ្រប់គ្រងតំបន់ឆ្នេរ ជាពិសេសការស្រាវជ្រាវពាក់ព័ន្ធដល់ទិដ្ឋភាពមជ្ឈដ្ឋានជីវសាស្ត្រ សេដ្ឋកិច្ច និង សង្គម ច្បាប់ និង រចនាសម្ពន្ធ័របស់ពួកវា ។

១០.៣ សហប្រតិបត្តិការក្នុងតំបន់

១០.៣.១ បណ្ដាប្រទេសដែលមានតំបន់ឆ្នេរជិតខាងគ្នាគួរតែសហការសំរបសំរួលជាមួយប្រទេសមួយផ្សេងទៀត ដើម្បីនិរន្តរភាពនៃការប្រើប្រាស់ធនធានតំបន់ឆ្នេរ និង អភិរក្សបរិស្ថាន ។

១០.៣.២ ក្នុងករណីសកម្មភាពទាំងឡាយណាដែលអាចបង្កឱ្យមានផលប៉ះពាល់បរិស្ថានឆ្លងកាត់ព្រំដែនតំបន់ឆ្នេរ បណ្តាប្រទេសគួរតែ៖

ក. មុននឹងធ្វើការកត់សំគាល់ដល់ប្រទេសដែលបានរងឥទ្ធិពលត្រូវផ្តល់ព័ត៌មានជាប្រចាំប្រសិនជាអាចធ្វើទៅបាន ។

ខ. ពិគ្រោះយោបល់ជាមួយនឹងបណ្តាប្រទេសនោះកាន់តែរហ័សកាន់តែល្អ ។

១០.៣.៣ បណ្តាប្រទេសគួរតែសហការគ្នានៅក្នុងកិច្ចអនុតំបន់ និង តំបន់ដើម្បីធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងតំបន់ឆ្នេរ ។

**១០.៤ ការអនុវត្ត**

១០.៤.១ បណ្តាប្រទេសគួរតែបង្កើតយន្តការសំរាប់សហប្រតិបត្តិការនិងសំរបសំរួលក្នុងចំណោមអាជ្ញាធរជាតិដែលចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍ អភិរក្ស និង គ្រប់គ្រងតំបន់ឆ្នេរ ។

១០.៤.២ បណ្តាប្រទេសគួរតែធានាអះអាងថាអាជ្ញាធរ ឬ សមត្ថកិច្ចតំណាងវិស័យជលផលនៅក្នុងដំណើរការគ្រប់គ្រងតំបន់ឆ្នេរមានសមត្ថភាពបច្ចេកទេស និង ប្រភពធនធានហិរញ្ញវត្ថុសមស្រប ។

**មាត្រា ១១ ការកែច្នៃបន្ទាប់ពីការប្រមូលផលនេសាទ និង ការធ្វើពាណិជ្ជកម្ម**

**១១.១ ការប្រើប្រាស់ត្រីប្រកបដោយភាពទទួលខុសត្រូវ**

១១.១.១ បណ្តាប្រទេសគួរតែប្រកាន់យកនូវវិធានការសមស្រប ដើម្បីធានាសិទ្ធិអ្នកប្រើប្រាស់ឱ្យមានសុវត្ថិភាពត្រឹមត្រូវ និង ពុំមានលាយឡំជាមួយត្រី និង ផលិតផលនេសាទផ្សេងទៀត ។

១១.១.២ បណ្តាប្រទេសគួរតែបង្កើត ហើយរក្សានូវប្រសិទ្ធិភាពសុវត្ថិភាពជាតិ និង ប្រពន្ធ័ធានារ៉ាប់រងថ្នាក់ជាតិ សំដៅការពារសុខុមាលភាពអ្នកប្រើប្រាស់និងជៀសវាងកំហុសឆ្គង

ក្នុងពាណិជ្ជកម្ម ។

១១.១.៣ បណ្ដាប្រទេសគួរតែកំនត់បទដ្ឋានអប្បបរមាដើម្បីធានាសុវត្ថិភាព និង គុណភាព ធានារ៉ាប់រងហើយបញ្ជាក់ច្បាស់ថាបទដ្ឋានត្រូវបានយកទៅអនុវត្តក្នុងឧស្សាហកម្ម ។ គេគួរតែជំរុញលើកទឹកចិត្តការអនុវត្តគុណភាពបទដ្ឋានដែលបានឯកភាពជាមួយនឹងបរិបទរបស់ FAO / WHO Codex Alimentarius Commission ស្ថាប័ន និងការរៀបចំផ្សេងទៀត ។

១១.១.៤ បណ្ដាប្រទេសគួរតែសហប្រតិបត្តិការដើម្បីឈានទៅដល់ធ្វើការសំរុះសំរួល ឬ ទទួលស្គាល់គ្នាទៅវិញទៅមក វិធានការអនាម័យជាតិ និង កម្មវិធីធ្វើវិញ្ញាបនបត្រ ហើយស្វែងរកលទ្ធភាពសមស្របណាមួយ ដើម្បីឈានទៅបង្កើតការទទួលស្គាល់លើការងារត្រួតពិនិត្យ និង វិញ្ញាបនបត្ររបស់ស្ថាប័ន ។

១១.១.៥ ពេលរៀបចំគោលនយោបាយសំរាប់ការអភិវឌ្ឍ និង ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាពថ្នាក់ជាតិ បណ្ដាប្រទេសគួរតែផ្ដោតការយកចិត្តទុកដាក់ដល់តួនាទីសេដ្ឋកិច្ច និង សង្គមនៅក្រោយការប្រមូលផលក្នុងវិស័យជលផល ។

១១.១.៦ បណ្ដាប្រទេស និង ស្ថាបន័ពាក់ព័ន្ធគួរតែធានាស្រាវជ្រាវក្នុងបច្ចេកវិទ្យាជលផលហើយធានារ៉ាប់រងគុណភាព និង គំរោងគាំទ្រដើម្បីធ្វើឱ្យប្រសើរឡើងការថែរក្សាត្រីក្រោយពេលប្រមូលផលត្រី យកចិត្តទុកដាក់ដល់សេដ្ឋកិច្ច សង្គម បរិស្ថាន និង ផលប៉ះពាល់អាហារូបត្ថម្ភរបស់គំរោងទាំងនោះ។

១១.១.៧ បណ្ដាប្រទេសគួរតែតាមរយៈកិច្ចសហការធ្លាកត់ត្រានូវវិធីផលិតខុស១គ្នា ហើយដោយធ្វើការសំរបសំរួលការអភិវឌ្ឍ និង ផ្ទេរបច្ចេកវិទ្យាសមស្រប ធានាថាការកែច្នៃ ការដឹកជញ្ជូន និង វិធីសាស្ត្រថែរក្សាត្រូវបានយកចិត្តទុកដាក់ដល់កត្តាបរិស្ថានជាមុនសិន ។

១១.១.៨ បណ្ដាប្រទេសគួរតែជំរុញលើកទឹកចិត្តដល់អ្នកដែលចូលរួមក្នុងការកែច្នៃ ការចែកចាយ និង ការលក់ដូរដើម្បី:

ក. កាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល និង កាកសំនល់ផ្សេង១ ។

ខ. ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ផលបន្ទាប់បន្សំ ដើម្បីពង្រឹងឱ្យរលូនទៅនឹងការ

ប្រតិបត្តិគ្រប់គ្រងប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល ។

គ. ការប្រើប្រាស់ធនធាន ជាពិសេសដូចជាទឹក ថាមពល ដោយឡែកអុសក្នុងវិធីយាបថមួយដែលគិតគូរដល់បរិស្ថាន ។

១១.១.៩ បណ្តាប្រទេសគួរតែជំរុញលើកទឹកចិត្តការប្រើប្រាស់ផលនេសាទសំរាប់ជាចំនីអាហាររបស់មនុស្សជាតិ និង ជំរុញការហូបចុកត្រីនៅពេលណាដែលអាចធ្វើទៅបាន ។

១១.១.១០ បណ្តាប្រទេសគួរតែសហការគ្នាដើម្បីធ្វើការសំរបសំរួលដល់ផលិតកម្មដែលបន្ថែមតំលៃទៅលើផលិតផលដោយបណ្តាប្រទេសកំពុងអភិវឌ្ឍ ។

១១.១.១១ បណ្តាប្រទេសគួរតែធានាអះអាងថា ការធ្វើពាណិជ្ជកម្មត្រីក្នុងស្រុក និង អន្តរជាតិ និង ផលិតផលជលផលដោយអនុលោមទៅតាមការប្រតិបត្តិគ្រប់គ្រងអភិរក្សសមស្របតាមរយៈធ្វើឱ្យប្រសើរឡើងនូវការធ្វើអត្តសញ្ញាណប្រភពរបស់ត្រី និងផលិតផលជលផលដែលបានធ្វើពាណិជ្ជកម្ម ។

១១.១.១២ បណ្តាប្រទេសគួរតែធានាអះអាងថាផលប៉ះពាល់ទៅលើបរិស្ថានក្រោយពេលប្រមូលផលត្រូវបានយកចិត្តទុកដាក់ដោយផ្អែកទៅលើច្បាប់ បទបញ្ជា និង គោលនយោបាយពាក់ព័ន្ធដោយមិនបង្កឧបសគ្គ និង បកស្រាយខុសក្នុងការធ្វើពាណិជ្ជកម្ម ។

**១១.២ ការធ្វើពាណិជ្ជកម្មអន្តរជាតិប្រកបដោយភាពទទួលខុសត្រូវ**

១១.២.១ កថាខណ្ឌទាំងឡាយរបស់ក្រមប្រតិបត្តិនេះគួរតែត្រូវបានបកប្រែពន្យល់ហើយអនុវត្តដោយអនុលោមទៅតាមគោលការណ៍ សិទ្ធិ និង កាតព្វកិច្ចដែលចែងក្នុងកិច្ចសន្យារបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

១១.២.២ ការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាតជាលក្ខណៈអន្តរជាតិមិនគួរត្រូវបានធ្វើការសំរបសំរួលទៅនឹងការអភិវឌ្ឍជលផលប្រកបដោយនិរន្តភាព និង ការប្រើប្រាស់ប្រកបដោយភាពទទួលខុសត្រូវនៃធនធានវារិជាត ។

១១.២.៣ បណ្តាប្រទេសគួរតែធានាអះអាងថាវិធានការដែលជះឥទ្ធិពលទៅលើការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារីជាតជាលក្ខណៈអន្តរជាតិត្រូវតែមានមូលដ្ឋានច្បាស់លាស់ទៅពេលណាដែលអាចធ្វើទៅបានគួរតែមានទទឹកការណ៍វិទ្យាសាស្ត្រ ហើយត្រូវតែអនុលោមទៅតាមវិធានកិច្ចព្រមព្រៀងអន្តរជាតិនានា ។

១១.២.៤បណ្តាវិធានការពាណិជ្ជកម្មដែលបានឯកភាពពីបណ្តាប្រទេសដើម្បីការពារជីវិតមនុស្សសត្វ ឬ សុខភាព ផលប្រយោជន៍របស់អ្នកប្រើប្រាស់ ឬ បរិស្ថានមិនត្រូវរើសអើង ហើយគួរតែអនុលោមទៅតាមគោលការណ៍ កិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ ជាពិសេសគោលការណ៍ សិទ្ធិ និង កាតព្វកិច្ចដែលបានរៀបចំឡើងក្នុងកិច្ចព្រមព្រៀងស្តីពីវិធានការប្រតិបត្តិអនាម័យ និង ភូតគាមអនាម័យ និង កិច្ចព្រមព្រៀងស្តីពីបច្ចេកទេសទប់ស្កាត់ ។

១១.២.៥ បណ្តាប្រទេសគួរតែបង្កឱ្យមានការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារីជាតដោយសេរីហើយលុបបំបាត់ការទប់ស្កាត់នានា និង ការមួលបង្កាច់ដល់ការធ្វើពាណិជ្ជកម្ម ដូចជាពន្ធនាំ កូតា និង ទប់ស្កាត់ការមិនយកពន្ធដោយអនុលោមទៅតាមគោលការណ៍ សិទ្ធិ និង កាតព្វកិច្ចពាណិជ្ជកម្មដូចជា កាតព្វកិច្ច គោលការណ៍ កិច្ចព្រមព្រៀងរបស់អង្គការស្បៀងអាហារពិភពលោក (WTO) ។

១១.២.៦ បណ្តាប្រទេសមិនគួរបង្កើតដោយផ្ទាល់ ឬ ដោយប្រយោល ឬ ដាក់ចាំងការធ្វើពាណិជ្ជកម្មមិនចាំបាច់ដែលធ្វើឱ្យបាត់បង់សេរីភាពការជ្រើសរើសរបស់អ្នកប្រើប្រាស់ ឬ រឹតបន្តឹងការចូលទៅក្នុងទីផ្សារ ។

១១.២.៧ បណ្តាប្រទេសមិនគួរដាក់លក្ខខណ្ឌដើម្បីចូលទៅក្នុងទីផ្សារប្រើប្រាស់ធនធានទេ ។ គោលការណ៍នេះ មិនរាប់បញ្ចូលទូវលទ្ធភាពនៃកិច្ចព្រមព្រៀងធ្វើអាជីវកម្មនេសាទរវាងបណ្តាប្រទេសដែលរាប់បញ្ចូលទាំងកថាខណ្ឌបង្អែកនានា ដើម្បីចូលទៅប្រើប្រាស់ធនធានធម្មជាតិ ពាណិជ្ជកម្ម ការចូលទៅក្នុងទីផ្សារ ការផ្ទេរបច្ចេកវិទ្យា ការស្រាវជ្រាវ វិទ្យាសាស្ត្រ វគ្គបំពាក់បំប៉នរយៈពេលខ្លី និង សមាសភាពពាក់ព័ន្ធផ្សេងៗទៀត ។

១១.២.៨ បណ្តាប្រទេសមិនគួរចូលទៅក្នុងទីផ្សារដើម្បីទិញផូវបច្ចេកវិទ្យាជាក់ស្តែង ឬ លក់ផលិតផលដទៃទៀតទេ ។

១១.២.៩ បណ្តាប្រទេសគួរតែសហការណ៍ដោយប្រតិបត្តិទៅតាមកិច្ចសន្យាអន្តរជាតិពាក់ព័ន្ធបែបបទធ្វើពាណិជ្ជកម្មចំពោះប្រភេទត្រីដែលជិតផុតពូជ ។

១១.២.១០ បណ្តាប្រទេសបង្កើតកិច្ចព្រមព្រៀងអន្តរជាតិសំរាប់ពាណិជ្ជកម្មដោយមានសំណាកគំរូរស់ដែលធ្វើឱ្យអន្តរាយខូចខាតបរិស្ថានការនាំចូល ឬ បណ្តាប្រទេសនាំចេញ ។

១១.២.១១ បណ្តាប្រទេសគួរតែជំរុញលើកទឹកចិត្តប្រកាន់ខ្ជាប់ និង ប្រតិបត្តិប្រកបដោយប្រសិទ្ធិភាពនូវបទដ្ឋានអន្តរជាតិពាក់ព័ន្ធចំពោះការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាត និង ការអភិរក្សធនធានវារិជាតមានជីវិត ។

១១.២.១២ បណ្តាប្រទេសមិនគួរមើលរំលងវិធានការណ៍អភិរក្សធនធានវារិជាតមានជីវិតដើម្បីកេងយកចំណេញក្នុងពាណិជ្ជកម្ម ឬ ផលប្រយោជន៍វិនិយោគនោះទេ ។

១១.២.១៣ បណ្តាប្រទេសគួរតែសហការណ៍បង្កើតគោលការណ៍មានលក្ខណៈជាអន្តរជាតិដែលអាចទទួលយកបាន ឬ បទដ្ឋានសំរាប់ធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាតដោយអនុលោមទៅតាមគោលការណ៍ សិទ្ធិនិងកាតព្វកិច្ចដែលបានបង្កើតក្នុងកិច្ចសន្យារបស់ WTO ។

១១.២.១៤ បណ្តាប្រទេសគួរតែសហការជាមួយគ្នា ហើយចូលរួមយ៉ាងសកម្មក្នុងតំបន់ពាក់ព័ន្ធ និង ពហុភាគី ដូចជា WTO ដើម្បីធានាសមធម៌មិនរើសអើងក្នុងការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាត ព្រមទាំងប្រកាន់ខ្ជាប់យ៉ាងទូលំទូលាយចំពោះកិច្ចសន្យាវិធានការអភិរក្សជលផលពហុភាគី ។

១១.២.១៥ បណ្តាប្រទេស ភ្នាក់ងារផ្តល់ជំនួយ ធនាគារពហុអភិវឌ្ឍ និង អង្គការអន្តរជាតិពាក់ព័ន្ធនានាត្រូវធានាថាគោលនយោបាយ និង ការអនុវត្តពាក់ព័ន្ធដល់ការលើកទឹកចិត្ត ការធ្វើពាណិជ្ជកម្មត្រីអន្តរជាតិ ការនាំចេញផលិតផលមិននាំទៅដល់ការតំរាមកំហែងបរិស្ថាន ឬ ជះឥទ្ធិពលអាក្រក់ដល់សិទ្ធិប្រើប្រាស់ចំនីអាហារ តំរូវការរបស់មនុស្សដែលក្នុងនោះ

ត្រីគឺជាអាហារសំខាន់សំរាប់សុខភាព និង សុខុមាលភាព ហើយចំពោះអ្នកដទៃទៀតដែលមិនអាចរកបាន ឬ អាចលៃលកទិញបាន ។

១១.៣ ច្បាប់ និង បទប្បញ្ញត្តិដែលទាក់ទងនឹងពាណិជ្ជកម្មផលនេសាទ

១១.៣.១ ប្រសិនជាអាចធ្វើទៅបាន ច្បាប់ បទបញ្ញត្តិ និង វិធានការរដ្ឋបាលដែលសមស្របទៅនឹងការធ្វើពាណិជ្ជកម្មត្រីនិងផលិតផលដែលមានដើមកំណើតពីវារិជាតជាលក្ខណៈអន្តរជាតិគួរតែមានភាពច្បាស់លាស់ ហើយកាន់តែសមញ្ញកាន់តែប្រសើរ ហើយអាចយល់បានដោយផ្អែកលើទឡ្ហីករណ៍វិទ្យាសាស្ត្រដែលមានស្រាប់ ។

១១.៣.២ បណ្តាប្រទេសដោយអនុលោមទៅតាមច្បាប់ជាតិគួរតែសំរបសំរួលប្រឹក្សាយោបល់ឱ្យបានសមស្រប ហើយការចូលរួមពីឧស្សាហកម្ម ព្រមទាំងបរិស្ថាន និង ក្រុមអ្នកប្រើប្រាស់ក្នុងការអភិវឌ្ឍអនុវត្តច្បាប់ និង បទបញ្ញាដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាត ។

១១.៣.៣ បណ្តាប្រទេសគួរតែសំរួលឱ្យបានងាយស្រួលនូវច្បាប់ បទបញ្ញា និង វិធានការរដ្ឋបាលទាំងឡាយដែលអាចអនុវត្តបានចំពោះការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាតដោយមិនធ្វើឱ្យអន្តរាយដល់ប្រសិទ្ធិភាពរបស់វា ។

១១.៣.៤ នៅពេលដែលប្រទេសណាមួយបង្ហាញពីការកែប្រែច្បាប់ចាំបាច់ដែលប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាតជាមួយប្រទេសផ្សេង ប្រទេសនោះត្រូវបញ្ជូនព័ត៌មាន និង ទុកពេលវេលាឱ្យបានគ្រប់គ្រាន់សំរាប់ប្រទេសពាក់ព័ន្ធធ្វើការផ្សព្វផ្សាយនូវវិធានការចាំបាច់និងសមស្របនៅក្នុងដំណើរការប្រែប្រួលនីតិភាពច្បាប់របស់គេ ។ ភ្ជាប់ជាមួយគ្នានេះ ការពិគ្រោះយោបល់ជាមួយប្រទេសដែលរងឥទ្ធិពលពាក់ព័ន្ធដល់ការអនុវត្តការប្រែប្រួលនេះគួរតែទទួលបាន ។ ដោយយកចិត្តទុកដាក់ហើយគួរតែត្រូវបានផ្តល់ឱ្យទៅតាមសំណើចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍ ដើម្បីដកហូតកាតព្វកិច្ចជាបណ្តោះអាសន្ន ។

១១.៣.៥ បណ្តាប្រទេសគួរតែសិក្សាពិនិត្យគោលអច្បាប់ និង បទបញ្ញាផ្សេងៗឱ្យសមស្របទៅនឹងការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីត្រីជាលក្ខណៈអន្តរជាតិ ដើម្បីកំណត់ថាតើលក្ខខណ្ឌដែលកើតឡើងនៅតែបន្តសកម្មភាពឬទេ ។

១១.៣.៦ បណ្តាប្រទេសគួរតែចុះសំរុងគ្នាកាន់តែឃ្លុរកាន់តែល្អនូវបទដ្ឋានដែលអាចអនុវត្តបាននៅក្នុងការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាតដោយអនុលោមទៅតាមកថាខណ្ឌពាក់ព័ន្ធនានាដែលបានទទួលស្គាល់ជាអន្តរជាតិ ។

១១.៣.៧ បណ្តាប្រទេសគួរតែប្រមូល បែងចែក និង ផ្លាស់ប្តូរព័ត៌មានទៅតាមពេលវេលាទៀងទាត់ ត្រឹមត្រូវ និង សមហេតុសមផលស្តីពីព័ត៌មានការធ្វើពាណិជ្ជកម្មត្រី និងផលិតផលដែលមានដើមកំណើតពីវារិជាតអន្តរជាតិ តាមរយៈស្ថាប័នជាតិ និងអង្គការអន្តរជាតិនានាដែលពាក់ពន្ធ័ ។

១១.៣.៨ បណ្តាប្រទេសគួរតែជូនដំណឹងឱ្យបានទាន់ពេលវេលាដល់ប្រទេសដែលចាប់អារម្មណ៍អង្គការពាណិជ្ជកម្មពិភពលោក និង អង្គការអន្តរជាតិនានាស្តីពីការអភិវឌ្ឍ និងការផ្លាស់ប្តូរច្បាប់ បទបញ្ញា និង វិធានការគ្រប់គ្រងរដ្ឋបាលដែលអាចអនុវត្តបានស្របទៅតាមការធ្វើពាណិជ្ជកម្មត្រី និង ផលិតផលដែលមានដើមកំណើតពីវារិជាតអន្តរជាតិ ។

## មាត្រា ១២ ការស្រាវជ្រាវជលផល

១២.១ បណ្តាប្រទេសទទួលស្គាល់ថាតំរូវការទទួលខុសត្រូវក្នុងវិស័យជលផលដោយយោងលើមូលដ្ឋានវិទ្យាសាស្ត្របច្ចេកទេសដែលមានស្រាប់ ដើម្បីជាគ្រឹះជួយដល់អ្នកគ្រប់គ្រងនិង ភាគីផ្សេងទៀតដែលចាប់អារម្មណ៍ក្នុងការធ្វើសេចក្តីសំរេចចិត្ត ។ ម្ល៉ោះហើយបណ្តាប្រទេសគួរតែធានាថាការងារស្រាវជ្រាវសមស្របត្រូវបានដំណើរការនៅគ្រប់ផ្នែកនៃវិស័យជលផលរួមមានជីវសាស្ត្រ អេកូឡូស៊ី បច្ចេកវិទ្យា វិទ្យាសាស្ត្របរិស្ថាន សេដ្ឋកិច្ច សង្គមសាស្ត្រ វារីវប្បកម្មនិងវិទ្យាសាស្ត្រចំណីអាហារ ។ បណ្តាប្រទេស គួរតែធានាឱ្យមានមូលដ្ឋានសំភារៈសំរាប់ការងារ

ស្រាវជ្រាវ និង ផ្តល់ការបណ្តុះបណ្តាលសមស្រប កសាងមន្ត្រី និង ស្ថាប័នដើម្បីធ្វើការងារស្រាវជ្រាវផ្តោតទៅលើតំរូវការពិសេសរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍ ។

១២.២ បណ្តាប្រទេសគួរតែបង្កើតក្របខណ្ឌស្ថាប័នឱ្យបានសមស្រប ដើម្បីកំណត់ប្រតិបត្តិការងារស្រាវជ្រាវដែលជាតំរូវការ ហើយសមស្របទៅនឹងការប្រើប្រាស់របស់វា ។

១២.៣ បណ្តាប្រទេសគួរតែធានាថា ទិន្នន័យដែលប្រមូលបានដោយការងារស្រាវជ្រាវត្រូវបានវិភាគ ហើយលទ្ធផលនៃការវិភាគនេះត្រូវបានបោះពុម្ពផ្សាយដោយគោរពដល់ការសំងាត់ និង ចែកចាយជាប្រចាំទៅតាមពេលវេលាមួយ ហើយងាយស្រួលយល់ដឹងឱ្យបានទាន់ពេល ដើម្បីបង្ហាញនូវទឡ្ហីករណ៍វិទ្យាសាស្ត្រដែលមានស្រាប់ព្រមទាំងចូលរួមវិភាគទានដល់ការអភិរក្សការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យជលផល ។ ពេលអវត្តមានព័ត៌មានវិទ្យាសាស្ត្រសមស្របមួយនោះ ការផ្តើមធ្វើការងារស្រាវជ្រាវត្រូវតែប្រព្រឹត្តិឡើងកាន់តែឆាប់កាន់តែល្អ ។

១២.៤ បណ្តាប្រទេសគួរតែប្រមូលទិន្នន័យដែលមានភាពសុក្រិត្យ និង ជឿជាក់បានជាតំរូវការដើម្បីដឹងពីស្ថានភាព និងប្រព័ន្ធអេកូឡូស៊ីជលផលរួមមានទិន្នន័យស្តីពីផលចាប់ដែលមិនមែនជាមុខសញ្ញាផលចាប់ដែលទាត់ចោល និង កាកសំនល់ នៅទីណាដែលទិន្នន័យសមស្របទាំងអស់ត្រូវបានផ្តល់ឱ្យក្នុងពេល និង ក៏រៀបរួមមួយទៅបណ្តាប្រទេស អនុតំបន់ តំបន់ និង ស្ថាប័នជលផលពិភពលោកពាក់ព័ន្ធ ។

១២.៥ បណ្តាប្រទេសគួរតែមានលទ្ធភាពត្រួតពិនិត្យ និង ធ្វើការប៉ាន់ប្រមាណស្ថានភាពសន្និធិដែលស្ថិតក្នុងយុត្តាធិការ រួមមានផលប៉ះពាល់ទៅលើការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីដែលបណ្តាលមកពីសំពាធនេសាទ ការបំពុល ឬ ការប្រែប្រួលទីជំរក ។ គេក៏គួរតែបង្កើនសមត្ថភាពស្រាវជ្រាវចាំបាច់ដើម្បីចូលទៅធ្វើការប៉ាន់ប្រមាណនូវឥទ្ធិពលប្រែប្រួលអាកាសធាតុ ឬ បរិស្ថានទៅលើសន្និធិត្រី និង ប្រពន្ធ័អេកូឡូស៊ីវារីជាត ។

១២.៦ បណ្តាប្រទេសគួរតែជួយគាំទ្រ និង ពង្រឹងសមត្ថភាពស្រាវជ្រាវថ្នាក់ជាតិដើម្បីឆ្លើយតបទៅនឹងបទដ្ឋានចំណេះដឹងវិទ្យាសាស្ត្រ ។

១២.៧ បណ្តាប្រទេសគួរតែសហការជាមួយស្ថាប័នអន្តរជាតិពាក់ព័ន្ធសមស្របលើក

ទឹកចិត្តជំរុញការស្រាវជ្រាវដើម្បីធានាការប្រើប្រាស់ធនធានជលផលឱ្យដល់កំរិតអតិបរមា និង លើកទឹកចិត្តដល់តំរូវការចាំបាច់ដើម្បីជួយគាំទ្រគោលនយោបាយជាតិដែលទាក់ទងដល់ត្រីជាអាហារចាំបាច់ ។

១២.៨ បណ្តាប្រទេសគួរតែធ្វើការងារស្រាវជ្រាវសង្កត់ធ្ងន់ត្រួតពិនិត្យទៅលើអាហារសំរាប់មនុស្សដែលបានមកពីធនធានវារីជាត និង មជ្ឈដ្ឋានដែលយកមកដោយធានាថាពុំមានផលប៉ះពាល់ដល់សុខុមាលភាពអ្នកប្រើប្រាស់ឡើយ ។ លទ្ធផលនៃការស្រាវជ្រាវទាំងនេះគួរតែអាចរកបានជាសាធារណៈ ។

១២.៩ បណ្តាប្រទេសគួរតែធានាថា កត្តាសេដ្ឋកិច្ច សង្គមទីផ្សារនិងស្ថាប័នជលផលត្រូវបានធ្វើការស្រាវជ្រាវឱ្យបានគ្រប់គ្រាន់ ហើយទិន្នន័យដែលប្រមូលបានសំរាប់បំរើឱ្យការគ្រប់គ្រង វិភាគ និង ការរៀបចំគោលបំណង ។

១២.១០ បណ្តាប្រទេសគួរតែអនុវត្តការសិក្សាស្រាវជ្រាវលើការជ្រើសរើសឧបករណ៍នេសាទឥទ្ធិពលរបស់ឧបករណ៍នេសាទទៅលើបរិស្ថានពូជមុខសញ្ញា និង ទៅលើចរិតនៃមុខសញ្ញាផលចាប់ និង ពូជមិនមែនមុខសញ្ញាដែលទាក់ទងទៅនឹងឧបករណ៍នេសាទទាំងនោះ ដូចជាជំនួយសំរាប់ការធ្វើសេចក្តីសំរេចចិត្តគ្រប់គ្រង ហើយជាមួយទស្សនៈក្នុងការបន្ថយឱ្យដល់កំរិតអប្បបរមាចំពោះផលចាប់ដែលមិនបានប្រើប្រាស់ព្រមទាំងរក្សាសុវត្ថិភាពជីវៈចំរុះរបស់ប្រពន្ធ័អេកូឡូស៊ី និង ទីជំរកវារីជាត ។

១២.១១ បណ្តាប្រទេសគួរតែធានាថាមុននឹងផ្សព្វផ្សាយពាណិជ្ជកម្មឧបករណ៍នេសាទប្រភេទថ្មីការវាយតំលៃតាមបែបវិទ្យាសាស្ត្រពីផលប៉ះពាល់ទៅលើវិស័យជលផល និងប្រពន្ធ័អេកូឡូស៊ីដែលឧបករណ៍ទាំងនោះនឹងត្រូវប្រើប្រាស់ ។ ប្រសិទ្ធិភាពរបស់ឧបករណ៍ដែលផ្សព្វផ្សាយថ្មីទាំងនោះគួរតែត្រូវបានតាមដានត្រួតពិនិត្យ ។

១២.១២ បណ្តាប្រទេសគួរតែធ្វើការអង្កេតតាមដាន និង ចងក្រងជាឯកសារចំនេះដឹងជាលក្ខណៈប្រពៃណី និង បច្ចេកវិទ្យាជាពិសេសឧបករណ៍ទាំងឡាយណាដែលទាក់ទង

និងផលផលជាលក្ខណៈគ្រួសារ ដើម្បីចាំប្រមាណការអនុវត្តទៅលើនិរន្តភាពនៃការអភិរក្ស គ្រប់គ្រង និង អភិវឌ្ឍវិស័យជលផល ។

១២.១៣ បណ្តាប្រទេសគួរតែជំរុញឱ្យមានការប្រើប្រាស់ទូលាយនូវលទ្ធភាព ការស្រាវជ្រាវជាមូលដ្ឋានសំរាប់រៀបចំគោលបំណងគ្រប់គ្រងចំណុចបង្អែកនិងលក្ខណៈសម្បត្តិព្រមទាំងដើម្បីធានាលើកកំពស់ទំនាក់ទំនងរវាងការអនុវត្ត ស្រាវជ្រាវ និង ការគ្រប់គ្រងជលផល ។

១២.១៤ បណ្តាប្រទេសដែលធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រក្នុងដែនទឹកដែលស្ថិតក្នុងយុត្តាធិការរបស់ប្រទេសដទៃគួរតែធានាអះអាងថានាវាទេសាចទាំងអស់គោរពតាមច្បាប់ និង បទបញ្ជារបស់ប្រទេសទាំងនោះ និង ច្បាប់អន្តរជាតិនានា ។

១២.១៥ បណ្តាប្រទេសគួរតែជំរុញលើកទឹកចិត្តឱ្យទទួលយកនូវការផ្សព្វផ្សាយជាឯកសណ្ឋានរដ្ឋបាលអនុវត្តស្រាវជ្រាវជលផលនៅក្នុងសមុទ្រក្រៅ ។

១២.១៦ នៅទីណាដែលអាចធ្វើទៅបានបណ្តាប្រទេសគួរតែជួយគាំទ្រដល់ការបង្កើតយន្តការ រួមទាំងការទទួលយកនូវឯកសណ្ឋានណែនាំ ដើម្បីសំរបសំរួលការងារស្រាវជ្រាវនៅក្នុងអនុតំបន់ និង តំបន់ហើយគួរតែលើកទឹកចិត្តដល់ការចែករំលែកលទ្ធផលស្រាវជ្រាវទៅឱ្យតំបន់ផ្សេងទៀត ។

១២.១៧ បណ្តាប្រទេស ទោះបីដោយផ្ទាល់ ឬ ដោយមានការជួយជ្រោមជ្រែងពីអង្គការអន្តរជាតិពាក់ព័ន្ធគួរតែរៀបចំសហការបច្ចេកទេស និង មានកម្មវិធីស្រាវជ្រាវដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងអំពីជីវសាស្ត្រ បរិស្ថាន និង ស្ថានភាពរបស់សន្និធិវារិជាតដែលឆ្លងកាត់ព្រំប្រទល់ ។

១២.១៨ បណ្តាប្រទេស និង បណ្តាអង្គការអន្តរជាតិគួរតែជំរុញ និង លើកទឹកចិត្តដល់សមត្ថភាពស្រាវជ្រាវរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍនៅក្នុងតំបន់នៃការប្រមូលទិន្នន័យ និង វិភាគព័ត៌មាន បច្ចេកវិទ្យា វិទ្យាសាស្ត្រ ការអភិវឌ្ឍធនធានមនុស្ស និង ផ្តល់សំភារៈស្រាវជ្រាវឱ្យពួកគេដើម្បីចូលរួមអភិរក្ស គ្រប់គ្រង និង និរន្តរភាពរបស់ធនធានវារិជាតប្រកបដោយប្រសិទ្ធិភាព ។

១២.១៩ នៅទីណាដែលសមស្រប អង្គការអន្តរជាតិដែលមានសមត្ថភាពគួរជួយទ្រទ្រង់បច្ចេកទេស និង ថវិកាចំពោះប្រទេសដែលស្នើសុំហើយជាប់កិច្ចសន្យាក្នុងការស្រាវជ្រាវស៊ើបអង្កេតសំដៅវាយតំលៃសន្និធិពុំដែលធ្វើអាជីវកម្មពីមុន ឬ បានធ្វើអាជីវកម្មតិចតួចបំផុត ។

១២.២០ បណ្តាអង្គការអន្តរជាតិដែលពាក់ព័ន្ធបច្ចេកទេស និង ហិរញ្ញវត្ថុគួរតែផ្តល់ជូនតាមការស្នើសុំរបស់ប្រទេសដែលត្រូវការថវិកាសំរាប់ការស្រាវជ្រាវផ្តល់ការយកចិត្តទុកដាក់ជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍ ដោយឡែកបណ្តាប្រទេសដែលអភិវឌ្ឍយឺតក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ និង បណ្តាប្រទេសជាកោះតូចៗកំពុងអភិវឌ្ឍ ។

**សាវតាលើប និង វិវឌ្ឍភាពរបស់ក្រមប្រតិបត្តិ**

១. ឧបសម្ព័ន្ធនេះពិពណ៌នាពីដំណើរតាក់តែងលំអិត និង ការចរចានៃក្រមប្រតិបត្តិដែលនាំទៅដល់ការដាក់ជូនដើម្បីអនុម័តនៅក្នុងសន្និសីទ FAO សម័យប្រជុំលើកទី ២៨ ។វាត្រូវបានគេចាប់អារម្មណ៍នូវសារប្រយោជន៍ប្រើប្រាស់ ចំពោះផ្នែកឧបសម្ពន្ធ័នេះទុកដូចជាប្រភពឯកសារបង្អែក និង ការអភិវឌ្ឍរបស់ក្រមប្រតិបត្តិ ហើយបានឆ្លុះបញ្ចាំងនូវផលប្រយោជន៍ដែលទទួលបាន និងគំនិតសំរុះសំរួលរបស់ភាគីទាំងអស់ដែលបានចូលរួមសហការ ។សង្ឃឹមថាក្រមប្រតិបត្តិនេះនឹងរួមវិភាគទានក្នុងការលើកទឹកចិត្ត ប្តេជ្ញាចិត្តចាំបាច់សំរាប់ការប្រតិបត្តិរបស់វា ។

២. នៅក្នុងការប្រជុំជាលក្ខណៈអន្តរជាតិបានយកចិត្តទុកដាក់ជាយូរណាស់មកហើយ ពីបញ្ហាការធ្វើអាជីវកម្មនេសាទលើសហួសកំរិតទៅលើសន្និធិដែលមានសារសំខាន់ និងគ្រោះថ្នាក់ដល់ប្រព័ន្ធអេកូឡូស៊ី កំហាតបង់សេដ្ឋកិច្ច និង បញ្ហាផ្សេងៗទៀតដែលទាក់ទិននឹងពាណិជ្ជកម្មត្រីដែលទាំងអស់នោះគំរាមកំហែងរយៈពេលយូរអង្វែងដល់និរន្តភាពជលផលហើយធ្វើឱ្យមានគ្រោះថ្នាក់ដល់ការផ្គត់ផ្គង់ស្បៀងអាហារ ។ នៅក្នុងការពិភាក្សាពីស្ថានភាពបច្ចុប្បន្ន និង ការប្រមើលមើលទិដ្ឋភាពជលផលពិភពលោក នៅសម័យប្រជុំលើកទី១៩ របស់គណៈកម្មាធិការ FAO ស្តីពីជលផល (COFI) ដែលប្រព្រឹត្តទៅនៅក្នុងខែ មីនា ឆ្នាំ ១៩៩១ បានលើកសំនូមពរឱ្យFAOគួរតែរៀបចំបង្កើតទស្សនៈស្តីពីការទទួលខុសត្រូវក្នុងវិស័យជលផលហើយអនុវត្តក្រមប្រតិបត្តិរហូតដល់ទីបញ្ចប់ ។

៣. ជាវិបាក រដ្ឋាភិបាលរបស់ម៉ិចសិកកូសហការជាមួយ FAO បានរៀបចំសន្និសីទអន្តរជាតិមួយស្តីពីភាពខុសត្រូវវិស័យជលផលនៅទីក្រុង Cancun ខែឧសភា ឆ្នាំ ១៩៩២ ។ សេចក្តីប្រកាសរបស់សន្និសីទបានយល់ព្រមថាសន្និសីទនឹងឆ្ពោះទៅរៀបចំទស្សនៈនៃភាពទទួលខុសត្រូវក្នុងវិស័យជលផលដោយចាប់ផ្តើមពីជុំវិញ ទស្សនៈនិរន្តរភាពនៃការប្រើប្រាស់ធនធានជលផលឱ្យស្រុះស្រួលគ្នាជាមួយបរិស្ថាន ការប្រតិបត្តិអាជីវកម្មនេសាទ និង វារីវប្បកម្មដែល

គ្មានគ្រោះថ្នាក់ដល់ប្រពន្ធ័អេកូឡូស៊ីរបស់ធនធាន ឬ គុណភាពរបស់វាកិច្ចសហការនៃតំលៃបន្ថែមទៅលើផលិតផលតាមរយៈដំណើរការកែច្នៃដែលឆ្លើយតបបានទៅតាមបទដ្ឋានអនាម័យការអនុវត្តការងារពាណិជ្ជកម្ម ដូចជាផ្តល់ឱ្យអ្នកប្រើប្រាស់បានប្រើប្រាស់ទំនិញដែលមានគុណភាពល្អ" ។

៤. សេចក្តីប្រកាសនៅទីក្រុង Cancun បានទាក់ទាញការចាប់អារម្មណ៍របស់កិច្ចប្រជុំកំពូល UNCED នៅទីក្រុង Rio ក្នុងខែ មិថុនា ឆ្នាំ១៩៩២ដែលបានជួយគាំទ្រការរៀបចំក្រមប្រតិបត្តិដើម្បីភាពទទួលខុសត្រូវវិស័យជលផល ។ កិច្ចប្រជុំពិគ្រោះយោបល់បច្ចេកទេសស្តីពីការនេសាទនៅក្នុងសមុទ្រក្រៅដែលរៀបចំដោយ FAO នៅខែកញ្ញា ឆ្នាំ ១៩៩២ បានស្នើសុំឱ្យជួយរៀបចំក្រមប្រតិបត្តិដោយផ្តោតទៅលើបញ្ហាទាក់ទងនឹងជលផលសមុទ្រក្រៅ ។

៥. សម័យប្រជុំក្រុមប្រឹក្សាFAO លើកទី ១០២ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៣ បានពិភាក្សាយ៉ាងល្អិតល្អន់ពីក្រមប្រតិបត្តិហើយសំនូមពរថា អត្ថិភាពត្រូវផ្តល់ទៅលើបញ្ហាសមុទ្រក្រៅ និងស្នើឱ្យលើកគំរោងសំរាប់ក្រមប្រតិបត្តិត្រូវបានបង្ហាញក្នុងកិច្ចប្រជុំគណៈកម្មាធិការជលផលនៃសម័យប្រជុំឆ្នាំ ១៩៩៣ ។

៦. សម័យប្រជុំលើកទី ២៨ របស់ COFI ខែមីនា ឆ្នាំ១៩៩៣ បានពិនិត្យជាទូទៅលើគោលការណ៍នៃក្រមប្រតិបត្តិ រួមមានសេចក្តីណែនាំលំអិត ហើយបានទទួលស្គាល់ឯកភាពលើពេលវេលាដែលត្រូវរៀបចំក្រមប្រតិបត្តិ ។ កិច្ចប្រជុំក៏បានធ្វើសំណើដល់ FAO ឱ្យរៀបចំតាមផ្លូវមួយឆាប់រហ័សផ្នែកលើផ្នែកមួយនៃក្រមប្រតិបត្តិឱ្យស្នើឡើងដើម្បីការពារការបង្ហូតទង់ជាតិឡើងវិញនៃនាវានេសាទដែលជះឥទ្ធិពលដល់វិធានការអភិរក្ស និង ការគ្រប់គ្រងនៅសមុទ្រក្រៅ ។

៧. ការរៀបចំក្រមប្រតិបត្តិដែលប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផលបានអនុវត្តដោយបានពិគ្រោះយោបល់ និង សហការជាមួយនឹងស្ថាប័ន ទីភ្នាក់ងារអង្គការសហប្រជាជាតិពាក់ព័ន្ធ និង អង្គការអន្តរជាតិនានា រាប់ទាំងអង្គការមិនមែនរដ្ឋាភិបាលផង ។

៨. ដោយមានការទាក់ទាញផ្សព្វផ្សាយរបស់អង្គរដ្ឋបាល FAO សេចក្តីព្រាងក្រម
ប្រតិបត្តិត្រូវបានបង្កើតឡើងតាមមាត្រាឱ្យស្របជាមួយនឹងអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ
១៩៨២ ស្តីពីច្បាប់សមុទ្រដោយយកចិត្តទុកដាក់ដល់សេចក្តីប្រកាសទីក្រុង Cancun
ឆ្នាំ១៩៩២ សេចក្តីប្រកាសនៅទីក្រុងRio ឆ្នាំ ១៩៩២ និង របៀបវារៈទី ២១ របស់UNCED
សេចក្តីសន្និដ្ឋាន និង សំណូមពរនៃការពិគ្រោះយោបល់បច្ចេកទេសស្តីពីការនេសាទក្នុងសមុទ្រ
ក្រៅ រៀបចំដោយ FAO ឆ្នាំ១៩៩២ យុទ្ធសាស្ត្រត្រូវបានអនុម័តយល់ព្រមនៅក្នុងឆ្នាំ ១៩៨៤
ដោយសន្និសីទរបស់ FAO ពិភពលោកស្តីពីការគ្រប់គ្រង និង អភិវឌ្ឍន៍វិស័យជលផល ហើយ
ឧបករណ៍ផ្សេងទៀតដោយរាប់បញ្ចូលទាំងលទ្ធផលរបស់សន្និសីទអង្គការសហប្រជាជាតិស្តីពី
សន្និធិត្រីច្រកតាវនិង សន្និធិត្រីដែលធ្វើចរាចរឆ្លាយដែលបានប្រព្រឹត្តទៅនៅខែសីហា ឆ្នាំ១៩៩៥
បានឯកភាពយល់ព្រមទៅលើដំណើរការអនុវត្តវិធីសាររបស់សន្និសីទអង្គការសហប្រជាជាតិស្តី
ពីច្បាប់សមុទ្រ ថ្ងៃ ទី១០ ធ្នូ ឆ្នាំ១៩៨២ ពាក់ព័ន្ធទៅនឹងសន្និធិត្រីច្រកតាវ និង សន្និធិត្រី
ដែលធ្វើចរាចរឆ្លាយ ។

៩. នៅសម័យប្រជុំលើកទី ២៧ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ សន្និសីទ FAO បានឯកភាព
អនុម័តជំរុញការប្រតិបត្តិទៅតាមវិធានការអភិរក្ស និង គ្រប់គ្រងអន្តរជាតិដោយនាវានេសាទ
នៅលើសមុទ្រក្រៅ ហើយបានស្នើថាគោលការណ៍ទូទៅរបស់ក្រមប្រតិបត្តិប្រកបដោយភាព
ទទួលខុសត្រូវជលផលត្រូវបានរៀបចំជាផ្លូវយ៉ាងរហ័សមួយ ដើម្បីផ្តោតទៅរកការរៀបចំ
មាត្រាគោលសំខាន់ៗ ។ ដោយផ្អែកលើសេចក្តីព្រាងនៃអត្ថបទគោលការណ៍ទូទៅត្រូវបាន
សិក្សាពិនិត្យឡើងវិញ ដោយក្រុមការងារដែលជាអ្នកជំនាញចាត់តាំងមកពីរដ្ឋាភិបាលហើយ
ជួបប្រជុំគ្នានៅទីក្រុងរ៉ូម ខែកុម្ភៈឆ្នាំ១៩៩៤ ។ការកែលំអសេចក្តីព្រាងត្រូវបានបញ្ជូនផ្សព្វផ្សាយ
យ៉ាងទូលាយទៅគ្រប់សមាជិកទាំងអស់របស់ FAO និង សមាជិកសមាគមទាំងអស់ ព្រមទាំង
អង្គការអន្តររដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាល។ មតិយោបល់ដែលទទួលបានពីការកែលំអ
សេចក្តីព្រាងទី ២ នៃគោលការណ៍ទូទៅត្រូវបានបញ្ចូលទៅក្នុងសេចក្តីព្រាងក្រមប្រតិបត្តិជា

មួយនឹងសំណើសំរាប់អត្ថបទឆ្លាស់គ្នា ។ ឯកសារនេះក៏ជាកម្មវត្ថុនៃការពិភាក្សាក្រៅផ្លូវការជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងឱកាសសម័យប្រជុំលើកទី ៤ របស់សន្និសីទអង្គការសហប្រជាជាតិស្តីពីសន្និធិត្រីច្រកតាវ និង សន្និធិត្រីដែលធ្វើចរាចរឆ្ងាយដែលបានប្រព្រឹត្តទៅនៅខែសីហា ឆ្នាំ ១៩៩៤ នៅទីក្រុងញូវយ៉ក ។

១០. ដើម្បីសំរបសំរួលដោយមានការយកចិត្តទុកដាក់លើអត្ថបទទាំងមូលនៃសេចក្តីព្រាងក្រមប្រតិបត្តិ លោកអគ្គនាយកបានស្នើទៅគណៈកម្មាធិការរបស់វានៅសម័យប្រជុំលើកទី ១០៦ ខែមិថុនា ឆ្នាំ ១៩៩៤ ដែលកិច្ចពិភាក្សាបច្ចេកទេសស្តីពីក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវលើការធ្វើអាជីវកម្មនេសាទបានរៀបចំឡើងបើកចំហដល់គ្រប់សមាជិក FAO អ្នកទាំងឡាយមិនមែនជាសមាជិកដែលចាប់អារម្មណ៍ អន្តររដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់ឱកាសសំរាប់ការចូលរួមឱ្យបានទូលាយដល់គ្រប់ភាគីដែលពាក់ព័ន្ធនៅក្នុងដំណាក់កាលដំបូងនៃការបរិយាយយ៉ាងល្អិតល្អន់របស់វា ។

១១. កិច្ចប្រឹក្សាយោបល់បច្ចេកទេសបានដំណើរការនៅទីក្រុងរ៉ូមពីថ្ងៃ ២៦ ខែកញ្ញា ដល់ ៥ ខែតុលា ឆ្នាំ១៩៩៤ ហើយសេចក្តីព្រាងសំរាប់ក្រមប្រតិបត្តិទាំងមូល និង សេចក្តីព្រាងទី ១ នៃសេចក្តីណែនាំបច្ចេកទេស ដើម្បីជួយគាំទ្រដល់មាត្រាទាំងអស់របស់ក្រមប្រតិបត្តិដែលបានបង្ហាញ ។ បន្ទាប់មកការសិក្សាដ៏ហ្មត់ចត់មួយទៅលើគ្រប់មាត្រាទាំងអស់នៃសេចក្តីព្រាងក្រមប្រតិបត្តិត្រូវបានដំណើរការការជ្រើសរើសសេចក្តីព្រាងក្រមបានរៀបចំដោយផ្អែកលើមូលដ្ឋានមតិយោបល់ទាំងឡាយដែលកំពុងពិភាក្សានៅក្នុងអង្គប្រជុំ និង ការផ្លាស់ប្តូរសេចក្តីព្រាងជាក់ស្តែងដែលបានដាក់ស្នើដោយលាយល័ក្ខណ៍អក្សរក្នុងពេលប្រឹក្សាយោបល់ ។

១២. ការប្រឹក្សាយោបល់ក៏បានសិក្សាល់អិតផងដែរនូវជំរើសសេចក្តីព្រាង ៣ មាត្រា ក្នុងចំណោម ៦ មាត្រារបស់ក្រមប្រតិបត្តិ គឺ មាត្រា៥ " ការធ្វើសមាហរណកម្មជលផលទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ "មាត្រា៦ " ការគ្រប់គ្រងជលផល "មាត្រា៧" ការប្រតិបត្តិអាជីវកម្មនេសាទ " លើកលែងតែគោលការណ៍ទាំងអស់ដែលអាចរងឥទ្ធិពលពីលទ្ធផលរបស់សន្និសីទអង្គការសហប្រជាជាតិដែលកំពុងដំណើរការស្តីពីសន្និធិត្រីច្រកតាវនិងសន្និធិត្រីធ្វើចរាចរឆ្ងាយ ។

របាយការណ៍រដ្ឋបាលខ្លីមួយបានរៀបចំឡើង ហើយបានបង្ហាញដល់គណៈកម្មាធិការ FAO និង COFI ។

១៣. ការប្រឹក្សាបច្ចេកទេសដែលបានស្នើឡើងទៅគណៈកម្មាធិការនៅសម័យប្រជុំលើកទី ១០៧ ដែលបានប្រព្រឹត្តិទៅកាលពីថ្ងៃទី ១៥ ដល់ ២៤ ខែវិច្ឆិកា ១៩៩៤ ពិនិត្យពាក្យពេចន៍ចុងក្រោយរបស់គោលការណ៍ទាំងនោះទាក់ទងសំខាន់ទៅនឹងបញ្ហាសមុទ្រក្រៅដែលបានដកចេញ ឬ ការផ្អាកជាបណ្តោះអាសន្នទូរលទ្ធផលរបស់សន្និសីទអង្គការសហប្រជាជាតិ ។ ជាទូទៅគណៈកម្មាធិការបានអនុម័តិយល់ព្រមតាមសំណើរវិធានការដែលបានកត់ត្រាទៅតាមកិច្ចពិភាក្សានៅក្នុងសម័យប្រជុំបន្ទាប់របស់ COFI ។

សេចក្តីព្រាងរបស់ក្រមប្រតិបត្តិបានដាក់ស្នើទៅគណៈកម្មាធិការ FAO ក្នុងឆ្នាំ ១៩៩៥ ហើយបន្ទាប់មកត្រូវបានសំរេចទៅតាមភាពចាំបាច់សំរាប់គណៈកម្មាធិការបច្ចេកទេសដែលបានជួបគ្នាស្របពេលដែលសម័យប្រជុំរបស់គណៈកម្មាធិការ ដើម្បីសហការសិក្សាលំអិតបន្ថែមទូវមាត្រារបស់ក្រមប្រតិបត្តិប្រសិនបើមានការចាំបាច់ ។

១៤. ផ្អែកលើខ្លឹមសារមតិ និង សំណើលំអិតដែលទទួលបាននៅពេលប្រឹក្សាយោបល់បច្ចេកទេស អគ្គលេខាធិការដ្ឋានតាក់តែងបានកែលំអសេចក្តីព្រាងក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវវិស័យជលផលមួយដែលបានដាក់ស្នើទៅសម័យប្រជុំលើកទី ២១របស់គណៈកម្មាធិការស្តីពីជលផលដែលបានប្រព្រឹត្តទៅពីថ្ងៃទី ១០ ដល់ ១៥ មីនា ១៩៩៥ ។

១៥. គណៈកម្មាធិការស្តីពីជលផលក៏បានជូនដំណឹងថាសន្និសីទបានរំពឹងទៅលើសេចក្តីសន្និដ្ឋានការងាររបស់ខ្លួនក្នុងខែសីហា ១៩៩៥ បានស្នើឡើងថាគោលការណ៍ទាំងឡាយណាដែលបានផ្អាកទុកក្នុងអត្ថបទសេចក្តីព្រាងរបស់ក្រមប្រតិបត្តិគួរតែសម្រុះសម្រួលជាមួយភាសាណាដែលបានឯកភាពដោយសន្និសីទអង្គការសហប្រជាជាតិដោយផ្អែកទៅតាមយន្តការដែលនឹងសំរេចដោយគណៈកម្មាធិការ និង ក្រុមប្រឹក្សាមុននឹងដាក់ស្នើក្រមប្រតិបត្តិទាំងមូល ដើម្បីទទួលការអនុម័តិនៅក្នុងសម័យប្រជុំលើកទី ២៨ នៃសន្និសីទរបស់ FAO ខែតុលា ១៩៩៥ ។

១៦.	គណៈកម្មាធិការបានជូនដំណឹងទៅអគ្គលេខាធិការដ្ឋាននូវជំហានមួយចំនួនដែលបាន និង កំពុងរៀបចំក្រមប្រតិបត្តិ ។ គណៈកម្មាធិការបានរៀបចំបង្កើតក្រុមការងារ ដើម្បីសិក្សាលំអិតឡើងវិញនូវអត្ថបទសេចក្តីព្រាងក្រមប្រតិបត្តិ។ ក្រុមការងារដែលបានជួបប្រជុំពីថ្ងៃ ១០ ដល់ ១៤ មីនា១៩៩៥ ទទួលខុសត្រូវលើការកែលំអលំអិតនៃអត្ថបទសេចក្តីព្រាងក្រមប្រតិបត្តិ បន្តការងារដោយកិច្ចពិគ្រោះយោបល់បច្ចេកទេស។ អត្ថបទនៃមាត្រា ៨ រហូតដល់មាត្រា ១០ ត្រូវបានបំពេញ និង អនុម័ត ។ ដោយសារបញ្ហាពេលវេលាក្រុមការងារបានផ្តល់ការណែនាំទៅអគ្គលេខាធិការដ្ឋានដើម្បីធ្វើសេចក្តីព្រាងមាត្រា ១ ដល់ មាត្រា ៥។ គណៈកម្មាធិការក៏បានស្នើថា សមាសធាតុស្រាវជ្រាវ និង សហប្រតិបត្តិការ ព្រមទាំងវារីវប្បកម្មបានត្រូវបញ្ចូលទៅក្នុងមាត្រា ៥គោលការណ៍ទូទៅដើម្បីឆ្លុះបញ្ចាំងនូវការអភិវឌ្ឍនៅក្នុងចំណោមជើងមាត្រានានារបស់ក្រម ។

១៧.	គណៈកម្មាធិការបានគាំទ្រសំណើដែលបានអនុម័តដោយសម័យប្រជុំលើកទី ១០៧ របស់ក្រុមប្រឹក្សាស្តីពីយន្តការដើម្បីបញ្ចប់ក្រមប្រតិបត្តិ ។ ពាក្យពេចន៍ចុងក្រោយរបស់គោលការណ៍ទាំងនោះសំខាន់ទាក់ទងទៅនឹងសន្ធិសញ្ញាក្រុកការនិងសន្ធិសញ្ញាធ្វើចរាចរឆ្លាយដែលរៀបចំឡើងជាផ្នែកមួយតូចរបស់ក្រមប្រតិបត្តិគួរតែត្រូតពិនិត្យឡើងវិញតាមស្មារតីរបស់សន្និសីទអង្គការសហប្រជាជាតិ ។ក្រុមនេះក៏បានស្នើសុំថានៅពេលដែលកិច្ចសន្យាឈានដល់ការឯកភាពលើខ្លឹមសារវាគឺជាការចាំបាច់ដើម្បីធ្វើឱ្យចុះសំរុងជាមួយច្បាប់ បច្ចេកទេស និងទិដ្ឋភាពភាសារបស់ក្រមប្រតិបត្តិ ដើម្បីសំរបសំរួលទៅនឹងសេចក្តីយល់ព្រមចុងក្រោយ ។

១៨.	របាយការណ៍នៃការបើក និង បិទ ក្រុមការងារបានបង្ហាញជូននៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីជលផលដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ១៤ ដល់ ១៥ មីនា ១៩៩៥ ដោយភ្ជាប់ជាមួយនឹងសម័យប្រជុំរបស់COFI ។ ប្រកាសប្រជាមតិពីទីក្រុងរ៉ូមស្តីពីជលផលពិភពលោកដែលទទួលបានពីកិច្ចប្រជុំនេះសង្ឃឹមថា "រដ្ឋាភិបាល និង អង្គការអន្តរជាតិត្រៀមសកម្មភាពដើម្បីបំពេញក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវជលផលជាមួយនឹងទស្សនៈ ដើម្បីដាក់អត្ថបទចុងក្រោយជូនទៅសន្និសីទ FAO ក្នុងខែតុលា ១៩៩៥" ។

១៩. សម័យប្រជុំលើកទី១០៨របស់ក្រុមប្រឹក្សាភិបាលបានបង្ហាញនូវអត្ថបទកែសំរួលរបស់ក្រមប្រតិបត្តិ។ ក្រុមប្រឹក្សាបានរៀបចំគណៈកម្មាធិការបច្ចេកទេសដែលបានប្រព្រឹត្តិទៅនៅក្នុងសម័យប្រជុំដំបូងពីថ្ងៃទី ៥ ដល់ ៩ មិថុនា ១៩៩៥ ដោយមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់អ្នកតំណាងជាសមាជិក និង អ្នកសង្កេតការ អង្គការអន្តររដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនក៏បានចូលរួមដែរ ។

២០ គណៈកម្មាធិការបច្ចេកទេសបានជម្រាបជូនទៅក្រុមប្រឹក្សាភិបាលថា វាត្រូវបានដំណើរការសិក្សាយ៉ាងហ្មត់ចត់នូវមាត្រា ១ ដល់ ៥ រាប់បញ្ចូលទាំងសេចក្តីណែនាំផង។ ក្រុមប្រឹក្សាភិបាលក៏បានជម្រាបផងដែរថា គណៈកម្មាធិការបានចាប់ផ្តើមកែសំរួលមាត្រា ៦ ហើយក្រមក៏ត្រូវបានត្រួតពិនិត្យកែសំរួល និង អនុម័តិមាត្រា ៨ ដល់ ១១ ។

២១. ក្រុមប្រឹក្សាភិបាលបានអនុម័តិលទ្ធផលការងាររបស់គណៈកម្មាធិការបច្ចេកទេស និងទទួលយកនូវអនុសាសន៏សំរាប់សម័យប្រជុំលើកទី២ ដែលបានប្រព្រឹត្តិទៅពីថ្ងៃទី ២៥ ដល់ ២៩ កញ្ញា ១៩៩៥ ដើម្បីបំពេញសេចក្តីកែតំរូវរបស់ក្រមប្រតិបត្តិនៅពេលដែលអគ្គលេខាធិការដ្ឋានបានធ្វើឱ្យស្របទៅនឹងអត្ថបទភាសា និង ដែលបានកាត់សេចក្តីដោយចាប់អារម្មណ៍ទៅនឹងលទ្ធផលរបស់សន្និសីទអង្គការសហប្រជាជាតិស្តីពីសន្និធិត្រីច្រកតាវ និង សន្និធិត្រីដែលធ្វើចរាចរឆ្ងាយ ។

២២. អត្ថបទកែសំរួលនៃក្រមប្រតិបត្តិដូចដែលបានអនុម័តិដោយគណៈកម្មាធិការបច្ចេកទេសនៅសម័យប្រជុំទី ១ (៥ ដល់ ៩ មិថុនា ១៩៩៥) ហើយអនុម័តិយល់ព្រមទៅសម័យប្រជុំលើកទី ១០៨ នៃក្រុមប្រឹក្សាភិបាលដែលបានបោះពុម្ពផ្សាយដូចជាឯកសារសន្និសីទ (C៩៥/២០) និងឯកសារការងារសំរាប់សម័យប្រជុំលើកទី ២ របស់គណៈកម្មាធិការបច្ចេកទេស។ សមាសធាតុកិច្ចសន្យាដែលមិនទាន់សំរេចត្រូវបានកំណត់យ៉ាងច្បាស់ ។

២៣. ដើម្បីសំរបសំរួលបញ្ចប់ក្រមប្រតិបត្តិ អគ្គលេខាធិការដ្ឋានបានរៀបចំឯកសារដាក់ស្នើមាត្រា ៦ ការគ្រប់គ្រងផលផល និង មាត្រា៧ ដំណើរការអាជីវកម្មនេសាទនៃក្រមប្រតិបត្តិ

ប្រកបដោយភាពទទួលខុសត្រូវជលផល ការចាប់អារម្មណ៍ ចំពោះកិច្ចសន្យាដែលពាក់ព័ន្ធទៅនឹងការអភិរក្ស និងការគ្រប់គ្រងសន្និធិត្រីច្រកតាវ និង សន្និធិត្រីធ្វើចរាចរឆ្ងាយដែលបានអនុម័តដោយសន្និសីទអង្គការសហប្រជាជាតិ ខែសីហា ១៩៩៥។

អគ្គលេខាធិការដ្ឋានក៏បានបំពេញតំរោងសំរាប់ធ្វើការសំរុះសំរួលអត្ថបទច្បាប់ និង ភាសាហើយផលិតជាស្រេចជា ៣ ភាសា( អង់គ្លេស បារាំង និង អេស្បាញ៉ុល) ដើម្បីដាក់ជូនគណៈកម្មាធិការក្នុងសម័យប្រជុំ ។

២៤. សម័យប្រជុំលើកទី ២ របស់គណៈកម្មាធិការបច្ចេកទេសរបស់ក្រុមប្រឹក្សាភិបាលបានជួបប្រជុំ ពីថ្ងៃ ២៥ ដល់ ២៩ កញ្ញា ១៩៩៥ ជាមួយនឹងការធ្វើបទបង្ហាញរបស់តំបន់ និងស្ថាប័នដែលចាប់អារម្មណ៍នានា ។ គណៈកម្មាធិការបានធ្វើសហការដោយអស់ពីចិត្តពីថ្លើមដោយសន្និដ្ឋានបញ្ចប់ និង យល់ព្រមលើមាត្រាទាំងអស់របស់ក្រមប្រតិបត្តិទាំងមូលប្រកបដោយជោគជ័យក្នុងអាណត្តិរបស់ខ្លួន ។ គណៈកម្មាធិការបច្ចេកទេសបានឯកភាពថាការចរចារបស់ក្រមប្រតិបត្តិត្រូវបានបញ្ចប់ ។ ការបើកបិទក្រៅផ្លូវការមួយរបស់ក្រុមស្ដីពីការសំរុះសំរួលភាសាបានប្រព្រឹត្តិទៅបន្ថែមលើសម័យប្រជុំជាមួយនឹងអគ្គលេខាធិការដ្ឋានបានបំពេញនូវការសំរុះសំរួលស្ដីពីមូលដ្ឋានរបស់អត្ថបទដូចដែលបានអនុម័តិនៅពេលបិទសម័យប្រជុំ។

គណៈកម្មាធិការបច្ចេកទេសបានណែនាំអគ្គលេខាធិការដ្ឋានឱ្យដាក់ជូនជាស្រេចនូវអត្ថបទដែលបានកែប្រែរួច ដើម្បីទុកជាឯកសារសំរាប់សន្និសីទសម័យប្រជុំលើកទី ១០៩ របស់ក្រុមប្រឹក្សាភិបាល ហើយដាក់ជូនទៅសម័យប្រជុំលើកទី ២៨ របស់សន្និសីទដើម្បីធ្វើការអនុម័តិ។

ក្រុមប្រឹក្សាភិបាលបានយល់ព្រមទទួលក្រមប្រតិបត្តិដូចដែលបានបញ្ចប់ដោយគណៈកម្មាធិការបច្ចេកទេស ។អគ្គលេខាធិការដ្ឋានបានសំណូមពរឱ្យរៀបចំស្នើសេចក្ដីព្រាងដំណោះស្រាយសំរាប់សន្និសីទ រាប់បញ្ចូលទាំងសេចក្ដីអំពាវនាវចំពោះបណ្ដាប្រទេសឱ្យធ្វើសច្ចានុម័តិជាបញ្ហាមួយបន្ទាន់ ការធ្វើតាមកិច្ចសន្យាដែលបានអនុម័តិនៅសម័យប្រជុំចុងក្រោយរបស់សន្និសីទ ។សម័យប្រជុំលើកទី ២៨ របស់សន្និសីទបានអនុម័តិនៅថ្ងៃទី ៣១តុលា១៩៩៥ដោយមតិភាគច្រើនក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវ និង ដំណោះស្រាយដូចបង្ហាញនៅក្នុងឧបសម្ព័ន្ធ ២ ។

**ចំណោះក្រោយ**

**សន្និសីទ**

<u>ទទួលស្គាល់</u> តួនាទីសំខាន់របស់ផលផលនៅក្នុងសុវត្ថិភាពស្បៀងអាហារ សេដ្ឋកិច្ច និង ការអភិវឌ្ឍសង្គមពិភពលោក ព្រមទាំងតំរូវការចាំបាច់ដើម្បីធានានូវនិរន្តរភាពនៃធនធានវារិជាត និង បរិស្ថានសំរាប់ជំនាន់បច្ចុប្បន្ន និង ទៅអនាគត ។

<u>រំឭកឡើងវិញ</u> គណៈកម្មាធិការស្តីពីជលផល ថ្ងៃទី ១៥ មីនា ១៩៩១បានសំណូមពរការអភិវឌ្ឍទស្សនៈការធ្វើអាជីវកម្មប្រកបដោយភាពទទួលខុសត្រូវហើយរៀបចំឧបករណ៍ស្តី ពីបញ្ហានេះ

<u>យកចិត្តទុកដាក់</u> សេចក្តីប្រកាសនៅ Cancun ដែលមានដើមកំណើតពីសន្និសីទអន្តរជាតិស្តីពីភាពទទួលខុសត្រូវជលផលខែមីនា ១៩៩២ដែលបានរៀបចំដោយរដ្ឋាភិបាលម៉ិចសិចកូសហការជាមួយនឹងFAO បានអំពាវនាវសំរាប់ការរៀបចំក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវវិស័យជលផល ។

<u>ត្រូវចងចាំជានិច្ច</u> ជាមួយនឹងការចូលជាធរមានរបស់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ និងការអនុម័តិនៃកិច្ចសន្យា ដើម្បីការអនុវត្តនូវមាត្រានានារបស់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ថ្ងៃ ១០ ធ្នូ ១៩៨២ ពាក់ព័ន្ធទៅនឹងការអភិរក្ស និងការគ្រប់គ្រងសន្និធិត្រីច្រកតាវ និង សន្និធិត្រីធ្វើចរាចរឆ្ងាយដូចដែលបានរំពឹងទុកជាមុននៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៩២ នៅRio និង នៅក្នុងរបៀបវារៈទី ២១របស់UNCEDមានតំរូវការចាំបាច់កើនឡើងសំរាប់កិច្ចសហការ អនុតំបន់ និង តំបន់ ហើយភាពទទួលខុសត្រូវសំខាន់ត្រូវបានអនុលោមទៅតាមFAO ជាមួយនឹងអាណត្តិរបស់ខ្លួន ។

<u>រំឭកឡើងវិញ</u> សន្និសីទ ១៩៩៣ ដែលបានអនុម័តិយល់ព្រមទទួលកិច្ចសន្យាFAO ដើម្បីជំរុញការប្រតិបត្តិតាមការអភិរក្សអន្តរជាតិ និង វិធានការគ្រប់គ្រងនាវានេសាទនៅសមុទ្រក្រៅ ហើយថាកិច្ចសន្យានេះគួរតែជាផ្នែកមួយនៃក្រមប្រតិបត្តិទាំងមូល ។

<u>កត់ត្រា</u> ជាមួយការពេញចិត្តដែលFAOដោយអនុលោមទៅតាមសេចក្តីសំរេចរបស់អង្គរដ្ឋបាល

បានរៀបចំកិច្ចប្រជុំបច្ចេកទេសបន្តបន្ទាប់គ្នាជាច្រើនដើម្បីរៀបចំក្រមប្រតិបត្តិហើយកិច្ចប្រជុំទាំងនេះបានទទួលលទ្ធផលដោយក្នុងកិច្ចសន្យាបានឈានទៅដល់អត្ថបទក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវវិស័យជលផល ។

ថ្លែងអំណរគុណ ការធ្វើប្រជាមតិទូទៅនៅរ៉ូមស្តីពីជលផលពិភពលោកដែលមានប្រភពពីកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីជលផល ពីថ្ងៃទី ១៤ ដល់ ១៥ មីនា១៩៩៥ជំរុញឱ្យរដ្ឋាភិបាលនិងអង្គការអន្តរជាតិនានា ដើម្បីឆ្លើយតបទៅនឹងប្រសិទ្ធិភាពស្ថានភាពជលផលបច្ចុប្បន្នដោយបំពេញក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវជលផលហើយយកចិត្តទុកដាក់អនុម័តិកិច្ចសន្យាដើម្បីជំរុញការប្រតិបត្តិទៅតាមការអភិរក្សអន្តរជាតិ និង វិធានការគ្រប់គ្រងនាវានេសាទនៅសមុទ្រក្រៅៈ

១. សម្រេច យល់ព្រមក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវជលផល ។

២.អំពាវនាវ ឱ្យបណ្តាប្រទេស អង្គការអន្តរជាតិ ទោះបីរដ្ឋាភិបាល ឬ មិនមែនរដ្ឋាភិបាល និង អ្នកទាំងឡាយណាដែលចូលរួមក្នុងជលផល ដើម្បីសហការគ្នាបំពេញ និង អនុវត្តកម្មវត្ថុ និង គោលការណ៍ដែលមាននៅក្នុងក្រមប្រតិបត្តិនេះ ។

៣.ទាមទារ សំណូមពរពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍត្រូវបានយកចិត្តទុកដាក់ក្នុងការអនុវត្តកថាខណ្ឌនានាក្នុងក្រមប្រតិបត្តិ ។

៤.ស្នើ FAO ផ្តល់កម្មវិធីការងារ និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជាជំនួលទានដល់បណ្តាប្រទេសកំពុងអភិវឌ្ឍក្នុងការអនុវត្តក្រមប្រតិបត្តិ និង ដើម្បីកិច្ចសហការរបស់កម្មវិធីជំនួយអន្តរតំបន់សំរាប់ជួយឧបត្ថម្ភមកពីខាងក្រៅក្នុងការជួយគាំទ្រការអនុវត្តក្រមប្រតិបត្តិ ។

៥.ស្នើជួយជ្រោមជ្រែងFAO នៅក្នុងកិច្ចសហការជាមួយបណ្តាសមាជិកនិងអង្គការពាក់ព័ន្ធផលប្រយោជន៍ ដើម្បីបរិយាយលំអិតឱ្យបានសមស្របសេចក្តីណែនាំបច្ចេកទេសក្នុងការជួយគាំទ្រអនុវត្តក្រមប្រតិបត្តិ ។

៦.<u>អំពាវនាវបន្ថែម</u> FAO ដើម្បីត្រួតពិនិត្យ និង រាយការណ៍ស្តីពីការអនុវត្តក្រមប្រតិបត្តិ និង ផលប៉ះពាល់របស់វា រាប់បញ្ចូលទាំងសកម្មភាពដែលស្ថិតនៅក្រោមដំណើរការរបស់ឧបករណ៍ និងដំណោះស្រាយដោយអង្គការសហប្រជាជាតិហើយជាពិសេសដំណោះស្រាយដែលបានយល់ព្រមដោយសភាទូទៅដើម្បីផ្តល់ឥទ្ធិពលទៅលើសន្និសីទសន្និធិត្រីច្រកតាវ និង សន្និធិត្រីដែលធ្វើចរាចរឆ្ងាយទាំងល់ការឯកភាពសំរាប់ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ១០ធ្នូ ១៩៨២ ពាក់ព័ន្ធទៅនឹងការអភិរក្ស និង ការគ្រប់គ្រងសន្និធិត្រីច្រកតាវ និង សន្និធិត្រីដែលធ្វើចរាចរឆ្ងាយ ។

៧.<u>ទាមទារ</u> FAO ឱ្យពង្រឹងអង្គជលផលថ្នាក់តំបន់ ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពជាមួយការអភិរក្សជលផល និង បញ្ហាគ្រប់គ្រងដោយមានការគាំទ្រពីអនុតំបន់ តំបន់ កិច្ចសហប្រតិបត្តិការពិភពលោក និង សំរបសំរួលក្នុងវិស័យជលផល ។

សៀវភៅនេះ រួមមានអត្ថបទរបស់ក្របប្រតិបត្តិប្រកបដោយភាពទទួល
ខុសត្រូវវិស័យជលផល សាវតាដើម ប្រភព ការបរិយាយលំអិតរបស់ក្រម
និង ដំណោះស្រាយ ៤/៩៥ ដែលបានអនុម័តដោយសម័យប្រជុំលើក
ទី ២៨ នៃសន្និសីទ FAO ថ្ងៃទី ៣១ តុលា ឆ្នាំ ១៩៩៥ ។